# ខ្ញុំតែងជូនអ្នក



រំឭកគម្រប់ខួបក្នុងជន្មាយុ ២៣ ឆ្នាំ

រៀបរៀងដោយ

ខ្ញុំព្រះករុណាសាមណេរ សា ចាន់រ៉ាត់

សម្រាប់ជាធម្មទានតែប៉ុណ្ណោះ!

ព.ស. ២៥៥៤

LC
895
SAC

www.elibraryofcambodia.org

PMB
895
SA

# ខ្ញុំតែងជូនអ្នក

រំឭកគម្រប់ខួបក្នុងជន្មាយុ ២៣ ឆ្នាំ

រៀបរៀងដោយ
ខ្ញុំព្រះករុណាសាមណេរ សា ចាន់រ៉ាត់

សម្រាប់ជាធម្មទានតែប៉ុណ្ណោះ!

ព្រះរាជាណាចក្រកម្ពុជា
13836/11
3/5
បណ្ណាល័យជាតិ

ព.ស. ២៥៥៤

National Library of Cambodia
www.e...org

➢ ឈ្មោះសៀវភៅ : ខ្ញុំតែងជូនអ្នក

➢ រៀបរៀងដោយ : សាមណេរ សា ចាន់រ៉ាត់

➢ ពិនិត្យផ្ទៀងផ្ទាត់ដោយ : ភិក្ខុ ធម្មិរប្បញ្ញោ ថន សុធិន ព្រមទាំងព្រះសង្ឃជាច្រើនអង្គទៀត ដែលមិនបានរៀបរាប់ឈ្មោះអស់

➢ វាយកុំព្យូទ័រដោយ : សាមណេរ សា ចាន់រ៉ាត់

➢ ឧបត្ថម្ភដោយ : ពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋានទាំងក្នុង និងក្រៅប្រទេស

➢ ទីកន្លែងធ្វើ : វត្តពោធិ៍វាល ភូមិរតនៈ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

➢ កាលបរិច្ឆេទ : ថ្ងៃពុធ ១៥កើត ខែបុស្ស ឆ្នាំខាល ទោស័ក ព.ស. ២៥៥៤។

➢ ការផ្សាយរបស់ : ក្រុមយុវសមណអ្នកនិពន្ធ

➢ បោះពុម្ពសម្រាប់ធម្មទាន: ១.១៥០ក្បាល ក្នុងតម្លៃ១ក្បាល = ០.៧៧$

➢ ទាក់ទងឧបត្ថម្ភផ្សេងៗ : ០១៧ ៨០៩ ៦៥០, ០៩៨ ៣៧០ ០៩៧ ០៥៨ ៥៣៦ ៨០៣

➢ រោងពុម្ពឈ្មោះ : ម៉េងហាវ

➢ អាសយដ្ឋាន : ផ្ទះលេខ៨១, ផ្លូវ១៧២, សង្កាត់ជ័យជំនះ, ខណ្ឌដូនពេញ, ក្រុងភ្នំពេញ (ខាងលិចវត្តឧណ្ណាលោម ចម្ងាយប្រហែល ១៥០ ម៉ែត្រ)។

➢ ទូរស័ព្ទ : ០១២ ៧១២ ៧១៥, ០១២ ៨២៦ ៩២០, ០១២ ៧៧៩ ១០០, ០៧៧ ២៧៧ ១០០

➢ អ៊ីម៉ែល : heangprint@gmail.com
khun_sokheang@yahoo.com

www.elibraryofcambodia.org

# ពាក្យផ្តើម

ឆ្លៀតក្នុងឱកាសដ៏មមាញឹកនៃការសិក្សានៅពុទ្ធិកវិទ្យាល័យ អ៊ឹង ធុង វត្តពោធិ៍វាល ខេត្តបាត់ដំបង ខ្ញុំមានបំណងសរសេរជាអត្ថបទកំណាព្យនេះឡើង ទុកជាចំណងដៃក្នុងថ្ងៃបុណ្យឆ្លងគម្ពីរព្រះត្រៃបិដក អដ្ឋកថារបស់ក្រុមព្រះសង្ឃស្ម័គ្រចិត្ត ដែលធ្វើការផ្សព្វផ្សាយព្រះធម៌តាមរយៈវិទ្យុសុវណ្ណអង្គរ FM ១០៦ MHz (ចាប់ពីម៉ោង ៨:៣០ PM-៩:៣០ PM) ជារៀងរាល់រាត្រី។

ការសរសេរសៀវភៅតូច **(ខ្ញុំតែងជូនអ្នក)** នេះឡើង មានកត្តាជាច្រើនដែលជំរុញឱ្យខ្ញុំមានកម្លាំងចិត្ត ក្នុងការសរសេរទាំងយប់ទាំងថ្ងៃ សូម្បីដល់ឆ្នាំដែលត្រូវប្រឡងនៅពុទ្ធិកមធ្យមសិក្សាបឋមភូមិ (ឱប្ងមបាលី) ក៏ដោយ ក៏ខ្ញុំនៅតែខិតខំប្រឹងប្រែងសរសេរដោយអាស្រ័យកត្តាដូចខាងក្រោម ÷

-ដោយមានការជំរុញលើកទឹកចិត្ត ពីសព្រហ្មចារីព្រះអង្គគ្រូ **អគ្គិវឌ្ឍនោ ស៊ឹម ប៊ុនវ័ត្ត** លោកម្ចាស់ **ឝបតិសោ្ស គង់ ចំនួសុភ័ត្រ្ត** ព្រមទាំងលោកម្ចាស់ **ធម្មិវប្បញ្ញោ ថន សុធិន** ដែលលោកសុទ្ធសឹងតែជាមិត្តធម៌របស់ខ្ញុំ និងជាអ្នកស្រឡាញ់អត្ថបទកំណាព្យ គួបផ្សំនឹងរូបខ្ញុំចូលចិត្តសរសេរអត្ថបទកំណាព្យស្រាប់ផង។ ម្យ៉ាងទៀត គិតឃើញថាការសរសេរក៏មិនមែនចំណាយពេលយូរប៉ុន្មានដែរ គ្រាន់តែត្រូវចំណាយពេលខ្លះពីការសិក្សា និងសម្តែងព្រះធម៌តាមវិទ្យុក្នុងរាត្រី ហើយត្រូវចំណាយពេលអស់ត្រឹមតែ ១ ខែកន្លះប៉ុណ្ណោះ ដើម្បីសរសេរអត្ថបទនេះឡើង។



www.elibraryofcambodia.org

-កាលដើមឡើយ ខ្ញុំមិនទាន់ចេះសរសេរអត្ថបទកំណាព្យអ្វីទេ ក្រោយមកខ្ញុំសាកល្បង សរសេរកំណាព្យមួយដែលឱ្យឈ្មោះថា ឃ្លាតឆ្ងាយម្តាយខ្ញុំ ហើយខ្ញុំសូមផ្ញើនឹងព្រះសង្ឃមួយអង្គ ដែលលោកពូកែសរសេរសៀវភៅមួយរូប តែពេលនោះលោកបដិសេធថា នៅក្នុងសៀវភៅរបស់លោកមិនអាចដាក់កំណាព្យនោះចូលបានទេ ព្រោះសៀវភៅនោះមានទំព័រគ្រាស់ពេក ទើបខ្ញុំគិតថា គ្រាន់តែអត្ថបទមួយទំព័រសោះដាក់ចូលមិនបានហ្ន៎! ហេតុអ្វីក៏យ៉ាប់ម្ល៉េះ? ចាប់តាំងពីពេលនោះមក (ថ្ងៃចេញព្រះវស្សាក្នុងឆ្នាំខាល ទោស័កពុទ្ធស័ករាជ ២៥៥៤ ខ្ញុំបានសរសេរអត្ថបទកំណាព្យនេះឡើង រហូតសម្រេចជាស្ថាពរ។

-ដើម្បីរំឭកដល់អាយុ របស់ខ្ញុំគម្រប់ខួប២៣ ឆ្នាំ ក្នុងព.ស.២៥៥៤នេះ ទុកជាធម្មទានដល់ ពុទ្ធមាមកជន ពុទ្ធបរិស័ទ សប្បុរសជន បងប្អូនរួមជាតិ សិស្សានុសិស្ស គ្រាន់នឹងអានកំសាន្តនៅពេលទំនេររបស់ខ្លួន ព្រោះនៅក្នុងផ្ទៃនៃអត្ថបទនេះ មានបង្កប់នូវការអប់រំកុលបុត្រ ឱ្យមានការយល់ដឹងអំពីព្រះគុណរបស់មាតាបិតា គ្រូឧបជ្ឈាយាចារ្យរបស់ខ្លួន ពិសេសនៅក្នុងអត្ថបទខ្លះមានបង្កប់នូវរឿងរ៉ាវពិតៗរបស់ខ្ញុំផ្ទាល់ដែលបានជួបប្រទះកន្លងមក ដូចជាអត្ថបទខ្លះៗមានចំណងជើងថា ជីវិតកំព្រាក្រោមដំបូលវត្ត ,ឃ្លាតឆ្ងាយម្តាយខ្ញុំ ,សាលាខ្ញុំរៀន ,ជីវិតអ្នកក្រគីយ៉ាងហ្នឹងឯង ជាដើម។

ខ្ញុំមួយអន្លើដោយសព្រហ្មចារី ពិតជាខិតខំប្រឹងប្រែងពិនិត្យផ្ទៀងផ្ទាត់អស់ពីកម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតីយ៉ាងណាក៏ដោយ ក៏គង់នៅមាន


www.elibraryofcambodia.org

កំហុសខុសឆ្គងនូវរាល់អត្ថន័យ ពាក្យពេចន៍ ព្យញ្ជនៈ អក្ខរៈ ភាសាបាលី សេចក្តីបកស្រាយ អធិប្បាយរៀបរាប់ខុសអំពីបែបបទ ឬមានភ្លាំងភ្លាត់ ជាក់ជាមិនខានដោយអចេតនា ជូនដោយចេះមិនដល់ ជូនដោយមិនយល់តែម្តង។

ម្យ៉ាងទៀតខ្លួននៅក្មេងខ្ចីនៅខ្ចីប្រាជ្ញា មិនឈ្លាសវៃក្នុងព្រះពុទ្ធវចនៈ មិនស្ទាត់ជំនាញខាងធម៌អាថ៌វិន័យ វិស័យអក្សរសាស្ត្រ ថែមទាំងរៀនបានតិច ការភ្លេចក៏កាន់តែច្រើន។

នេះគឺជាវណ្ណកម្មទីពីរហើយ បន្ទាប់អំពីសៀវភៅក្បាលទីមួយ ឈ្មោះ **ចញ្ចានៃជីវិត និង ព្រះធម៌** ។

មួយវិញទៀត ខ្ញុំសូមអភ័យទោសានុទោសទាំងប៉ុន្មាន ដែលកើតឡើងក្នុងទីនេះអំពីសំណាក់ព្រះគុណម្ចាស់ ព្រះថេរានុត្ថេរៈ បណ្ឌិតបញ្ញវន្ត កវីនិពន្ធ សប្បុរស ពិសេសលោកអ្នកអានគ្រប់មជ្ឈដ្ឋាន និងគ្រប់សម័យកាលដែលបានអានសៀវភៅនេះ និងសៀវភៅក្រោយៗទៀត ក៏សូមមេត្តាជួយកែសម្រួល ឬជួយផ្តល់ជាមតិយោបល់ដល់ខ្ញុំផង គ្រាន់នឹងបានធ្វើការកែប្រែនូវកំហុសដែលកើតមាននៅក្នុងទីនេះ និងសៀវភៅក្រោយៗទៀត ឱ្យមានភាពល្អប្រសើរឡើង ដូច្នេះសូមមេត្តា ជួយកែសម្រួលដោយកុសលចេតនាផងចុះ។

ជាចុងក្រោយនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកអ្នកសប្បុរស ព្រះករុណាព្រះគុណម្ចាស់គ្រប់ៗព្រះអង្គ ដែលបានចំណាយពេលវេលាដ៏មានតម្លៃជួយពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលអក្ខរាវិរុទ្ធ



www.elibraryofcambodia.org

ព្រមទាំងលោកអ្នក ដែលបានចំណាយថវិកាក្នុងការបោះពុម្ពសៀវភៅនេះឱ្យមានរូបរាងឡើង។ ដោយអំណាចនៃសេចក្ដីជ្រះថ្លា ជួយគាំទ្រនូវកិច្ចការធម្មទាននេះក៏ដូចជាជួយគាំទ្រនូវព្រះពុទ្ធសាសនា ឱ្យមានស្ថិរភាព គង់វង្សតរៀងមក សូមឱ្យលោកអ្នកសប្បុរសបានជួបប្រសព្វតែសេចក្ដីសុខ សូមឱ្យពុទ្ធបរិស័ទមានព្រះរតនត្រ័យជាទីពឹងមានបុណ្យកុសលជាទីរឭក ហើយក៏សូមជាប់ជាឧបនិស្ស័យនៃសន្តិបទពោល គឺព្រះនិព្វានគ្រប់ព្រះអង្គ និងគ្រប់គ្នាតរៀងទៅ។

**-សូមឱ្យព្រះពុទ្ធសាសនារុងរឿងចម្រើន។**

**-សូមឱ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសាកលលោក។**

**-សូមឱ្យលោកទាំងមូលបានប្រកបដោយសន្តិភាព។**

**ដោយបំណាងល្អពីខ្ញុំព្រះករុណា**

**សាមណេរ សា ចាន់រ៉ាត់**

វត្តពោធិវាល

ខេត្តបាត់ដំបង → ថ្ងៃពុធ ១៥កើត ខែបុស្ស ឆ្នាំខាល ទោស័ក ព.ស.២៥៥៤ ។



www.elibraryofcambodia.org

# ឧទ្ទិសកថា

ដោយអំណាចនៃសេចក្តីព្យាយាមក្នុងកុសលចេតនា ការខិតខំប្រឹងប្រែងសរសេរសៀវភៅនេះ សូមបូជាចំពោះព្រះរតនត្រ័យ ដែលជារតនៈដ៏ប្រសើរខ្ពង់ខ្ពស់ក្នុងលោក ឥតមានរតនៈដទៃស្មើបានជាទីសក្ការៈ ដោយសេចក្តីគោរពកោតក្រែងជ្រះថ្លាសព្វៗកាល។

សូមឧទ្ទិសបុណ្យថ្វាយប្រគេន និងជូនចំពោះ÷

-សម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន ណាត

-សម្តេចព្រះពោធិវង្ស ហួត តាត (វជិរប្បញ្ញោ)

-អរិយបណ្ឌិតោ ភិក្ខុ ប៉ាង ខាត់

-ភិក្ខុធម្មបាល ខៀវ ជុំ

-ព្រះតេជគុណ ប៊ុណ្យ សម្ភារជន៍

-ព្រះធម្មឃោសាចារ្យ សេខ នាង

-ក្រុមជំនុំព្រះត្រៃបិដកគ្រប់ព្រះអង្គនិងគ្រប់គ្នា ព្រមទាំងគ្រប់សម័យកាល

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈគ្រប់សម័យកាល

-លោកឪពុក ថង ផូ និង អ្នកម្តាយ សាន សឿម ព្រមទាំងញាតិមិត្ត

-លោកគ្រូ អ្នកគ្រូទាំងអស់ ព្រមទាំងសិស្សានុសិស្សគ្រប់មជ្ឈដ្ឋាន

-ព្រះគុណម្ចាស់ និងញាតិញោមដែលកំពុងកាន់សៀវភៅនេះគ្រប់គ្នា



www.elibraryofcambodia.org

-ភិក្ខុ អតិវណ្ណោ ស៊ីម ប៊ុនវណ្ណ (អ្នកមានឧបការៈ និងផ្ដល់ទឹកចិត្តដល់ខ្ញុំ)

-ភិក្ខុ ឧបតិស្សោ គង់ ច័ន្ទសុភ័ក្រ្ត (សព្រហ្មចារីជួយផ្ដល់ទឹកចិត្ត)

-ភិក្ខុ គម្ភីរបញ្ញោ ថន សុជិន (មិត្តធម៌និងជាអ្នកមានឧបការៈរបស់ខ្ញុំ)

-ភិក្ខុ វជិរបញ្ញោ សាន សុជា (ព្រះអង្គគ្រូធម្មាចារ្យខេត្តពោធិ៍សាត់)

-ភិក្ខុ អគ្គបណ្ឌិតោ យង់ សុផាត (ប្រធានសមាគមអរិយវង្ស...)

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស (ខេត្តបាត់ដំបង)

-លោកគ្រូធម្មាចារ្យ រស់ សូផាត (ខេត្តបាត់ដំបង)

-លោកគ្រូវិនយាចារ្យ គាំ អ៊ីវ (ខេត្តបាត់ដំបង)

-លោកគ្រូធម្មាចារ្យ កែវ វិមុត្ត (ខេត្តសៀមរាប)

-ឧបាសក គុយ សុធន (អ៊ំប្រុស)

-លោកគ្រូឧទ្ទេសាចារ្យ សួន ប៊ុនធឿន (ធម្មការខេត្តបាត់ដំបង)

-លោកគ្រូឧទ្ទេសាចារ្យ គីម សែល (វត្តកោះកែវអន្លង់វិល)

-អ្នកមីង ថង រីត (សហរដ្ឋអាមេរិក)

-សព្វសត្វទាំងអស់ក្នុងសង្សារវដ្ដ សូមអនុមោទនានូវបុណ្យរាសីនេះឱ្យបាន គ្រប់ព្រះអង្គ និងគ្រប់គ្នាតរៀងទៅផងចុះ។ *សូមអនុមោទនាបុណ្យ !!! សូមអនុមោទនាមហាកុសល !!! សូមអនុមោទនា !!!*



www.elibraryofcambodia.org

## នាមលោកអ្នកមានឧបការៈក្នុងការទោរធម្មទាន

-ភិក្ខុ អតិវឌ្ឍនោ ស៊ឹម ម៉ុនរ័ត្ន (ជួយលើកទឹកចិត្តក្នុងការសរសេរ)

-ភិក្ខុ ឧបតិស្សោ គង់ ចំនួនសុតំត្រា (ជួយលើកទឹកចិត្តក្នុងការសរសេរ)

-ភិក្ខុ ធម្មវិបស្សោ ថន សុធិន (ជួយលើកទឹកចិត្ត និងផ្តល់មតិយោបល់)

-លោកឪពុក ថង ផូ ឧបត្ថម្ភសម្ភារៈក្នុងការសិក្សា និងលើកទឹកចិត្ត

-អ្នកម្តាយ សាន សឿម ឧបត្ថម្ភថវិកាក្នុងការសិក្សា និងផ្តល់ទឹកចិត្ត

-អ្នកមីង ថង រីត ឧបត្ថម្ភកុំព្យូទ័រមួយគ្រឿង(៥០០$)និងថវិកាក្នុងការសិក្សា

-ញោមឧបាសិកា សិត វឌ្ឍនា និងញោមឧបាសក ចាន់ ទូច និងបុត្រ

-ញោមឧបាសិកា គួ ធារី និងស្វាមីព្រមទាំងបុត្រ (ឧបត្ថម្ភចង្ហាន់)

-ញោមឧបាសិកា កែវ សុគន្ធ និងស្វាមីព្រមទាំងបុត្រ(ឧបត្ថម្ភចង្ហាន់)

-ញោមឧបាសិកា ណាក់ ណាស់ និងស្វាមីព្រមទាំងបុត្រ(ឧបត្ថម្ភចង្ហាន់)

-ញោមឧបាសិកា ជុំ សុជាំ និងស្វាមីព្រមទាំងបុត្រ(ឧបត្ថម្ភចង្ហាន់)

-ញោមឧបាសិកា មុំ ស្រីទូច និងស្វាមីព្រមទាំងបុត្រ(ឧបត្ថម្ភចង្ហាន់)។

-ញោមឧបាសិកា អ៊ូច ម៉ុន ព្រមទាំងបុត្រនិងចៅៗ(ភូមិប្រគាប)

-ព្រមទាំងញាតិញោមជាច្រើនរូបទៀត ដែលពុំបានរៀបរាប់ឈ្មោះអស់។



www.elibraryofcambodia.org

# មាតិកា

| ល.រ -ឈ្មោះកំណាព្យ | ទំព័រ |
| --- | --- |
| ១-ជីវិតកំព្រាក្រោមជំបូលវត្ត | ១ |
| ២-ស្លាប់ឱ្យមានឈ្មោះរស់ឱ្យមានន័យ | ៣ |
| ៣-ឃ្លាតឆ្ងាយម្ដាយខ្ញុំ | ៥ |
| ៤-ជីវិតមានតិចកុំភ្លេចសាងល្អ | ៧ |
| ៥-អត្ថន័យជីវិត | ៩ |
| ៦-គុណនៃព្រះពុទ្ធទ្រង់សម្ដែងធម៌ | ១២ |
| ៧-អ្នកមានដឹងទេ? | ១៥ |
| ៨-គុណនៃព្រះធម៌ | ១៦ |
| ៩-គុណនៃព្រះសង្ឃ | ១៨ |
| ១០-បញ្ហាក្នុងជីវិត | ២០ |
| ១១-មិនគួរជឿព្រោះតែជំនឿគ្មានហេតុផល | ២២ |
| ១២-រស់នៅកុំអាង | ២៥ |
| ១៣-កូនភ្ញាក់ខ្លួនហើយ | ២៦ |
| ១៤-ដំណើរជីវិត | ២៨ |
| ១៥-អ្នកមានគុណខ្ញុំ | ៣១ |



www.elibraryofcambodia.org

១៦ -តម្លៃសិក្សាក្នុងជីវិត.......................................៣៣
១៧ -បុណ្យមិនភ្លេចអ្នកមានតែអ្នកភ្លេចបុណ្យ........................ ៣៥
១៨ -បំណុលជីវិត.............................................៣៧
១៩ -សម្លេងព្រះធម៌.........................................៣៩
២០ -ស្រណោះវប្បធម៌ជាតិខ្ញុំខ្លាំងណាស់.......................... ៤១
២១ -មិនគួរស្រវឹងទំប្រឹងសាងខ្លួន............................ ៤៣
២២ -ចូរកុំអាងលើ...........................................៤៥
២៣ -រវល់ភ្លេចស្លាប់ប្រញាប់ភ្លេចខ្លួន............................ ៤៧
២៤ -សិរីសួស្តីស្ថិតនៅឯណា?..................................៤៩
២៥ -ស្នេហ៍កប់ព្រលឹង.......................................៥៥
២៦ -មានជីវិតហើយគួរតែសិក្សា...............................៥៧
២៧ -បើសិនមានទ្រព្យកុំភ្លេចឲ្យទាន........................... ៥៩
២៨ -ជីវិតអ្នកក្រតីយ៉ាំងហ្នឹងឯង................................៦១
២៩ -រូបកាន់តែចាស់ចិត្តកាន់តែក្មេង...........................៦៣
៣០ -កុំអាងខ្លួនចាស់មិនស្តាប់គេក្មេង.......................... ៦៥
៣១ -បើសិនបានល្អជួយគេផងណា៎..............................៦៧
៣២ -រៀនចុះភាសាបរទេសកុំភ្លេចរៀនភាសាខ្មែរ.................៦៩
៣៣ -កុំភ្លេចកំណើត..........................................៧០


www.elibraryofcambodia.org

៣៤-រស់ទាល់តែក្មេងស្លាប់..........................................៧១
៣៥-ដូចខ្វះរឿងនិយាយ..........................................៧៣
៣៦-រស់សាងស្នេហ៍ភ្លេចគុណម៉ែឪ..........................................៧៥
៣៧-សាលាខ្ញុំរៀន..........................................៧៧
៣៨-ពេលជួបបញ្ហាទើបស្រែករកម៉ែ..........................................៧៩
៣៩-បើសិនចង់មានត្រូវលះបើសិនចង់ឈ្នះត្រូវចុះចាញ់..........................................៨០
៤០-កុំទាន់អាលអួត..........................................៨២
៤១-កុំស្អប់ខ្លួនឯង..........................................៨៣
៤២-សប្បាយចលក..........................................៨៤
៤៣-ខ្ញុំចេះពីអ្នក..........................................៨៦
៤៤-ស្គាល់តែមុខតែមិនស្គាល់ចិត្ត..........................................៨៨
៤៥-រៀនស្គាល់ខ្លួនឯង..........................................៩០
៤៦-ចំនួសហ្លួសញ្ញាតិ..........................................៩២
៤៧-ក្មេងទាន់សម័យ..........................................៩៤
៤៨-ទឹកស្នាមញញឹម..........................................៩៦
៤៩-ឆាកល្ខោនជីវិត..........................................៩៨
៥០-កូនឥតខាន់ស្លា..........................................១០០
៥១-ចិត្តថ្លៃកបន្ទោរ..........................................១០២



www.elibraryofcambodia.org

៥២ -មនុស្សបានតែមាត់ ........................................ ១០៣

៥៣ -ខ្ញុំសូមអង្វរ ........................................ ១០៥

៥៤ -អាណិតព្រះសង្ឃ ........................................ ១០៧

៥៥ -គ្រាន់តែប្រាប់ទេ! ........................................ ១០៩

៥៦ -ខ្ញុំគ្មានអ្វីទេ ........................................ ១១១

៥៧ -តើឱ្យពុកម៉ែពឹងលើអ្វីទៅ? ........................................ ១១២

៥៨ -ចូរស្តីថាទេចំពោះបាបកម្ម ........................................ ១១៥

៥៩ -ល្អតែគុណម៉ែម្តេចមិនល្អគុណឪ ........................................ ១១៨

៦០ -មានក៏មានទៅខ្ញុំគ្មានថាស្តី! ........................................ ១២០

៦១ -ឆ្វេងពីអ្នកថា ........................................ ១២១

៦២ -ចាស់តែអាយុ ........................................ ១២៣

៦៣ -កូនខុសហើយម៉ែ! ........................................ ១២៤

៦៤ -សិក្សាបទពិចារណា ........................................ ១២៦



www.elibraryofcambodia.org

នត្ថិ បញ្ញា សមា អត្ថា ខ

គ្មានពន្លឺអ្វីស្មើ ដោយប្រាជ្ញាឡើយ។

សៀវភៅបម្រុងនឹងចេញផ្សាយជាធម្មទានដោយ ក្រុមយុវសចណាអ្នកនិពន្ធ មានឈ្មោះដូចខាងក្រោមៈ

-បញ្ហានៃជីវិត និង ព្រះធម៌ ( ដោយសាមណេរ សា ចាន់រ៉ាត់ )

-គួរសិក្សាធម៌ ( ដោយសាមណេរ សា ចាន់រ៉ាត់ )

-ល្មមភ្ញាក់ខ្លួនហើយ ( ដោយសាមណេរ សា ចាន់រ៉ាត់ )

-គង់មានថ្ងៃមួយ ( ដោយសាមណេរ សា ចាន់រ៉ាត់ )

ព្រមទាំងសៀវភៅជាច្រើនក្បាលទៀត ដែលមិនបានរៀបរាប់ឈ្មោះអស់។



www.elibraryofcambodia.org

www.elibraryofcambodia.org

# ១.ជីវិតកំព្រាក្រោមដំបូលវត្ត

ដៃចាប់សៀវភៅផ្ដើមតែងអក្ខរា ស្រក់ទឹកនេត្រាអួលណែនដើមក
សរសេររៀបរាប់ជីវិតក្រីក្រ រស់ទាំងត្រដរតាមកម្មវេរា។
កាលនៅតូចៗរស់ក្នុងគ្រួសារ ល្ងាចហើយកាលណាហូបបាយជុំគ្នា
ពុកមកពីស្រែម៉ែថើបកូនភ្ញា រីករាយរកគ្នាសប្បាយឥតអាក់។
មិនយូរប៉ុន្មានសង្គ្រាមមកដល់ ចិត្តរីតខ្វាយខ្វល់ដល់ពេលបែកបាក់
ពុកឃ្លាតទៅឆ្ងាយម៉ែយំសស្រាក់ គ្មានទាំងមាសប្រាក់ចិញ្ចឹមកូនតូច។
មើលចុះផ្ទះស្បូវសង់ជាប់នឹងដី ម្ដាយសែនរីងរៃសតិស្មើរខូច
រស់នៅក្រៀមក្រោះទុក្ខគ្មានអ្វីដូច កូននៅតូចៗយំទារពិសា។
ធម្មតាអ្នកម្ដាយស្រណោះកូនណាស់ កាត់អស់កេរ្តិ៍ខ្មាសដើរសូមអាហារ
ឱ្យកូនបានហូបស៊ូអត់អាត្មា គាត់យំខ្លោចផ្សាបាត់ដំណឹងប្ដី។
ពុកលាម៉ែទៅទាំងកូននៅតូច ដឹងអីគាត់ខូចបែរមានស្រីថ្មី
ពេលដឹងដំណឹងម៉ែស្ទើរក្សិណក្ស័យ ព្រះគុណម្ចាស់ថ្លៃកូនៗសោកា។
ធម្មតាសត្វអកពេលដែលបាត់គូ ពិតនៅមិនយូរត្រូវស្លាប់មរណា
តែត្រង់ចិត្តម្ដាយលោកមានមេត្តា ខិតខំរក្សាថែកូនពាលពៅ។
រស់នៅជនបទពឹងស្រែចម្ការ ម៉ែខំឧស្សាហ៍ដកស្ទូងដាំស្រូវ
ស៊ីឈ្នួលគេខ្វះមិនគិតថ្ងៃក្ដៅ ឱ្យតែគេហៅគាត់ខំធ្វើការ។


www.elibraryofcambodia.org

ម៉ែនៅមេម៉ាយគាត់ខំរកប្រាក់ ថែមទាំងទុកដាក់ឱ្យកូនសិក្សា
រៀនលេខនព្វន្តនៅឯសាលា ទោះក្រម្តេចម្តាឱ្យកូនបានចេះ។
យប់ហើយនិងថ្ងៃម្តាយនឹកដល់ប្តី មិនគួរមានស្រីតឹងទ្រូងស្មើរប្រេះ
កូនគាត់រៀនឆ្លាតហើយស្អាតអ្វីម្ល៉េះ តែគាត់ចាញ់ចេះគ្មានទ្រព្យសម្បត្តិ។
ឱ!វត្តអារាមមានគុណតេជះ ម្តាយខំរូតរះក្រាបប្រណិប័តន៍
ផ្ញើកូននឹងសង្ឃក្រែងផុតវិបត្តិ រៀនធម៌បរិយត្តិក្នុងពុទ្ធសាសនា។
ពេលស្នាក់នៅវត្តសុខជាងនៅផ្ទះ ថ្វាយបង្គំព្រះស្តាប់ធម៌ទេសនា
ព្រឹករៀបចង្ហាន់ដៃកាន់សស្ត្រា ថ្ងៃឡើងកាលណាឆ្លៀតទៅមើលម៉ែ។
ពេលទៅសាលាគេសើចពេញថ្នាក់ ព្រោះអីគ្មានប្រាក់បង់គ្រូរាល់ខែ
មានតែបាយហូបគិតខ្មាសគេដែរ ខ្លួននៅស្រុកស្រែមិនដូចនៅផ្សារ។
តាំងពីតូចមករស់នៅក្នុងវត្ត ចិត្តមិនដែលភ្លាត់ពីការសិក្សា
ខំរៀនខ្លួនឯងនិងជួយគ្រួសារ ព្រមទាំងសាសនាឱ្យមានតម្លៃ។
ក្នុងពេលឥឡូវកម្សត់ទុគ៌ត ទៅអនាគតតែងនឹកស្រមៃ
ចង់កសាងខ្លួនឱ្យផុតចង្រៃ កុំឱ្យមានថ្ងៃជួបទុក្ខដូច្នេះ។
នេះគឺរឿងពិតជីវិតអ្នកក្រ រស់ទាំងត្រដរស្វែងរកចំណេះ
ក្រោមដំបូលវត្តបានសុខអ្វីម្ល៉េះ បើសិនរៀនចេះមិនភ្លេចវត្តឡើយ។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

# ២-ស្លាប់ឱ្យមានឈ្មោះរស់ឱ្យមានន័យ

កំណើតជាមនុស្សបានដោយផលល្អ	រស់បានដោយក្រនៅក្នុងលោកិយ
ក្រមានព្រះពុទ្ធពន្យល់ប្រុសស្រី	បរមត្ថវែងខ្លីឱ្យមានប្រាជ្ញា។
ការមានជីវិតទោះយូរឬឆាប់	គួរខំប្រញាប់ស្ដាប់ធម៌ទេសនា
ចម្រើនកុសលខំលះតណ្ហា	ទើបមានឈ្មោះថារស់នៅមានន័យ។
ធម្មតារូបកាយតែងចាស់ជរា	ឯឈ្មោះនានាមិនចេះចាស់អី
បើរស់សាងល្អទើបឈ្មោះប្រពៃ	ធ្វើបាបអប្រិយហៅស្អុយទាំងរស់។
បុប្ផក្នុងសួនមានពណ៌ផ្សេងគ្នា	ភមរនានាមិនដែលហើរហួស
តែងចង់ក្រេបក្លិនផ្កាមិនចំពោះ	ក៏គង់មានឈ្មោះអ្នកសាងប្រយោជន៍។
យ៉ាងណាបណ្ឌិតទោះរស់ទីណា	តែងជួយអាត្មាមិនឱ្យអសោចិ៍
ទោះស្លាប់រូបកាយក្លាយទៅជាខ្មោច	មិនលះប្រយោជន៍គឺការសាងល្អ។
ចំណែកជនពាលទោះរស់រយឆ្នាំ	ធ្វើបាបប្រចាំមិនចេះត្រេកអរ
និងការធ្វើបុណ្យសាងគុណបន្ត	រស់នៅក៏ជរចាំតែថ្ងៃស្លាប់។
ដូច្នេះសប្បុរសដែលបានដឹងហើយ	ចូរកុំកន្តើយរួសរាន់ប្រញាប់
អប់រំកាយចិត្តធ្វើគុណឱ្យឆាប់	ព្រោះពេលជិតស្លាប់បានបុណ្យជាគ្នា។
ចង់បានឈ្មោះល្អរស់នៅមានន័យ	លុះតែប្រុសស្រីគំនិតល្អជា
ព្រមស្ដាប់តាមធម៌នៃព្រះភគវា	ទោះកាយគ្រាំគ្រាតែឈ្មោះឧត្តម។



www.elibraryofcambodia.org

អ្នករស់មានសីលទោះជាប្រុសស្រី កើតក្នុងលោកិយតែងតែខិតខំ
ប្រកបការងារជួញដូរផ្សេងៗ មិនហ៊ានបន្លំពោលពាក្យមុសា។
ទោះរស់ឆ្ងាយក្រុងផ្ទះខ្ទមហូរហែ ខិតខំធ្វើស្រែព្រមទាំងចម្ការ
មិនដែលធ្វើបាបលួចឆក់នរណា ពឹងតែអាត្មារស់នៅសុខសាន្ត។
តាមពិតស្រុកស្រែប្រើគោក្របី រទេះចាស់ក្តីមិនដែលរំខាន
ពេលដែលទៅណាទោះយប់ថ្មើរម៉ាន មិនឱ្យរំខានដំណេកអ្នកណា។
បើនៅទីក្រុងទោះយប់អធ្រាត្រ ឡានម៉ូតូព្រាតលាន់ឮអស្ចារ្យ
បើកមិនសំចៃរំខានយាយតា គាត់ជេរផ្តាសាដោយពាក្យអាក្រក់។
តាមពិតរស់នៅទោះស្រែឬផ្សារ កុំតែឧស្សាហ៍ធ្វើការលួចឆក់
រស់នៅមានសីលមិនសាងអាក្រក់ ធ្វើទានតក់ៗគង់ល្អប្រពៃ។
រស់ក្នុងសង្គមសូមធ្វើតាមច្បាប់ តែបើសិនស្លាប់សូមឱ្យមានន័យ
រស់សាងគុណធម៌ជីវិតប្រពៃ ដូច្នេះប្រុសស្រីចូរសាងសុចរិត។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**

**យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។**

បុគ្គលណារស់នៅមួយរយឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃរបស់លោក ដែលមានប្រាជ្ញាប្រសើរជាង មានការពិនិត្យពិចារណាជាប្រក្រតីប្រសើរជាង។ ( សហស្សវគ្គទី៨ ចិងកលេខ ៥២)



www.elibraryofcambodia.org

# ៣.ឃ្លាតឆ្ងាយម្ដាយខ្ញុំ

យប់យន់សែនស្ងាត់ខ្យល់ផាត់ទឹកហូរ គួរឱ្យអាសូរជីវិតកំព្រា
មករស់ស្រុកគេស្រស់ស្អាតសោភា ឃ្លាតម្ដាយពុំងាចិត្តសែនអាល័យ។
ព្រាត្រត្រជាក់ពេលភ្ញាក់ឡើងម្ដង ចិត្តសែនសៅហ្មងដេកនឹកស្រមៃ
មាន់ក៏រងាវកញ្ជ្រៀវអស់ដៃ នឹកតែម្ដាយថ្លៃនិងលោកឪពុក។
ដោយនឹកម្ដាយពេកក្នុងពេលយប់ជ្រៅ ដៃចាប់សៀវភៅដែលកូនរៀបទុក
សរសេរគុណម្ដាយឱ្យស្បើយក្ដីទុក្ខ ភ្លឺហើយលុបមុខដូចជាស្រស់ស្រាយ។
ម៉ែអើយតាំងតែកូននៅក្នុងផ្ទៃ អ្នកតែងវិងវៃគ្មានដែលសប្បាយ
ដេកក៏មិនលក់ក្ដៅអស់រាងកាយ ខ្ពើមទាំងទឹកបាយនិងនំចំណី។
យប់ហើយនិងថ្ងៃពោះកាន់តែធំ ម៉ែទុក្ខប៉ុនភ្នំហួសនឹងពោលស្ដី
ពិបាកក្នុងទ្រូងបាត់អស់ស្មារតី មានតែពឹងប្ដីចិញ្ចឹមផ្លូវចិត្ត។
ពេលជិតគ្រប់ខែកាន់តែលំបាក ម្ដាយសែនតោកយ៉ាកភ័យព្រួយគំនិត
ខ្លាចកូនមាសស្ងួនក្សយសូន្យជីវិត ថ្ងៃប្រសូតពិតម៉ែរឹតសោកា។
មុនថ្ងៃប្រសូតម៉ែមិនសប្បាយ ចិត្តតែងខ្វាល់ខ្វាយបន់អស់ទេវតា
សំពះម្ចាស់ស្រុកទឹកគុណដូនតា បួងសួងប្រាថ្នាឱ្យផុតគ្រោះថ្នាក់។
កំពុងប្រសូតម៉ែឈឺពេកក្រៃ ស្ទើរដាច់សរសៃឆ្អឹងក៏ចង់បាក់
ក្ដៅឈឺសព្វប្រាណបែកញើសសស្រាក់ ម្ដាយប្រឹងឥតអាក់កូនក៏កើតភ្លាម។



www.elibraryofcambodia.org

កូនបានកើតហើយជាទារកខ្ចី ម្ដាយចាត់ស្មារតីគឺព្រោះអស់ឈាម
ពេលនោះឪពុកក៏នៅមិនស្ងៀម ដែគាត់រវាមផុសលាងកូនភ្លា។
ម្ដាយដឹងខ្លួនហើយស្រវាថ្មមបី ទឹកមុខប្រិមប្រិយចិត្តព្រហ្មវិហារ
ឱ្យកូនបៅដោះរៀងរាល់វេលា ឈាមប្រែក្លាយជាទឹកដោះល្អថ្លា។
ពីតូចដល់ធំរស់ជុំអ្នកម្ដាយ ចិត្តកូនសប្បាយជួបតែសុខា
កូនធំបន្តិចម៉ែឱ្យសិក្សា រៀនលេខអក្ខរាមិនឱ្យចន្លោះ។
កូនរៀនបានខ្ពស់រស់គាន់តែឆ្ងាយ ពីឪពុកម្ដាយចិត្តកូនក្រៀមក្រោះ
ណាមួយព្រួយចិត្តខ្លួនពេញកម្លោះ មិនបានធ្វើសោះតបគុណលោកវិញ។
ម៉ែអើយរាល់ថ្ងៃកូនខំរៀនសូត្រ នឹកអ្នករហូតទុក្ខសែនទោម្នេញ
ត្រចៀកស្ដាប់គ្រូមាត់កូនទន្ទេញ ពេលកូនវិលវិញជួយលោកមិនខាន។
ម៉ែអើយពុកអើយកូនបានសុខហើយ សូមលោកបានស្បើយពីទុក្ខក្នុងប្រាណ
ពេលកូនរៀនចប់នឹងវិលវិញថ្កាន ជួយលោកឱ្យបានសប្បាយចិន្ដា។
ជាចុងក្រោយនេះកូនជូនបុណ្យម៉ែ ឪពុកផងដែរនិងញាតិកា
បងប្អូនរួមជាតិឈ្មោះថាខេមរា សូមបានសុខាលុះនិព្វានហោង។

ដោយសាចណោរ សា ចាន់រ៉ាត់

បិយតោ ជាយតី សោកោ បិយតោ ជាយតី ភយំ
បិយតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្ដីសោកកើតអំពីសេចក្ដីស្រឡាញ់ ភ័យកើតអំពីសេចក្ដីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្ដីស្រឡាញ់ហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកពីណា។


www.elibraryofcambodia.org

# ៤. ជីវិតមានតិចកុំភ្លេចសាងល្អ

ផែនដីទាំងមូលភ្លឺដោយសូរិយា　　ឯយប់ភ្លឺថ្លាដោយដួងចន្ទ្រា
ពពកទាំងឡាយរសាត់បែកគ្នា　　ដោយសារតែវាយោបក់ផាយផាត់។

សត្វលោកទាំងអស់រស់ដោយអាហារ　　ឯហ្វូងបក្សារស់ក្នុងព្រៃស្ងាត់
ពេលជួបហើយព្រាត់ជាទុក្ខវិបត្តិ　　រស់នៅស្ងប់ស្ងាត់ទើបផុតចាកពៀរ។

កន្ទែងជួញដូរធ្វើនៅទីផ្សារ　　រីឯមច្ឆារស់ក្នុងគង្គា
ធម្មតាមានខន្ធតែងចាស់ជរា　　ឯព្រះធម្មាមិនស្លាប់ឡើយណា។

សេចក្តីស្រឡាញ់ពេញចិត្តគំនិត　　សេពគប់ញាតិមិត្តខុសក្តីប្រាថ្នា
ព្រោះទុកចិត្តគេថាពិតបានការណ៍　　គេបោកមួយក្តារព្រោះភ្លេចស្មារតី។

តាមរឿងពិតទៅអ្នកចាញ់បោកគេ　　នៅគ្រាន់បើទេកុំទុក្ខសោកអី
បើបានដឹងហើយសាងខ្លួនជាថ្មី　　កុំធ្វើហីៗប្រញាប់រួសរាន់។

បានកើតជាមនុស្សសំណាងខ្លាំងណាស់　　ចូរគិតឱ្យច្បាស់សតិដឹងទាន់
រពួករឿយៗបុណ្យជាបន្ទាន់　　សូត្រធម៌កុំភ័ន្តភាវនារាល់ថ្ងៃ។

បើអ្នករស់នៅក្រទ្រព្យមិនថា　　បើក្រប្រាជ្ញាជីវិតអស់ថ្លៃ
សូម្បីខ្លួនស្អាតមុខមាត់ជើងដៃ　　ក៏គ្មានតម្លៃស្មើបុណ្យកុសល។

មានអាយុវែងក៏វែងទៅចុះ　　តែសូមស្រីប្រុសចូរគិតឱ្យដល់
បើខ្វះបុណ្យចាស់ជាអ្នកឱ្យផល　　ម្ល៉េះសមកង្វល់ទុក្ខឥតមានស្បើយ។



www.elibraryofcambodia.org

បើសិនអ្នកចាស់សូមចាស់គំនិត បើអ្នកធំពិតសាងគុណឱ្យហើយ
ពេលដែលស្លាប់ទៅគ្មានអ្នកជួយឡើយ បុណ្យអ្នកនោះហើយជាអ្នកនាំផ្លូវ។
បើសិនមានទ្រព្យកុំភ្លេចធ្វើទាន សេពគប់គ្រឿងញៀនតែងនាំអាស្រូវ
បើខ្លួននៅល្ងង់ខំសិក្សាទៅ កុំអាងញាតិផៅឱ្យជួយអាត្មា។
សម័យឥឡូវព្រះធម៌មានហើយ ចូរកុំកន្តើយស្តាប់គិតពិចារណ៍
ទុកជាគំនិតកាត់ផ្តាច់មោហា ឱ្យជីវិតថ្លាពីអវិជ្ជា។
បើសិនរស់នៅអាងលើមានក្រ មិនខំសាងល្អពិតត្រូវគ្រាំគ្រា
ស្លាប់ទៅជាខ្មោចរងទុក្ខវេទនា ព្រោះចិត្តពាលាវឹងតឹងមានះ។
ជីវិតមានតិចកុំភ្លេចសាងល្អ សិក្សាព្រះធម៌គោរពសំពះ
ដាក់ចិត្តដាក់កាយថ្វាយបង្គំព្រះ ទើបអ្នកបានឈ្នះទុក្ខសោកនានា។
ដូច្នេះបើសិនពោលស្តីទៅខុស សូមអស់ស្រីប្រុសរួចផុតចាកពៀរ
បើខ្ញុំពោលត្រូវសុខទាំងអស់គ្នា តោះ!ស្តាប់ធម្មាទៅនិព្វានហោង។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**

**អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ**
**ទន្ធំ ហិ ករតោ បុញ្ញំ បាបស្មឹ រមតី មនោ ។**

បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប។



www.elibraryofcambodia.org

# ៥. អត្ថន័យជីវិត

ពាក្យថាជីវិតបង្កប់អត្ថន័យ បើតាមបាលីប្រែថាដំណើរ
ខ្មែរយើងនិយាយពីរោះគ្រាន់បើ លោកចេះច្នៃធ្វើខេមរភាសា។
ការប្រើភាសាបាលីសំស្ក្រឹត គួរតែរៀនគិតកុំចេះតែថា
រៀនខ្មែរឱ្យឆ្អិនកុំអួតអាត្មា ប្រយ័ត្នលោកថាអ្នកចាតែថេះ។
ការពោលយ៉ាងនេះមិនមែនមើលងាយ ថាខ្មែរទាំងឡាយមិនមានចំណេះ
នរណាក៏ដឹងថាខ្មែរលោកចេះ រៀបរាប់ប៉ុណ្ណេះព្រោះចង់ប្រាប់ថា។
ចេះមកពីរៀនមានមកពីរក បើក្រមិនរកតើមានយ៉ាងណា
បើល្ងង់ឱ្យរៀនខិតខំឧស្សាហ៍ កុំចាំវាសនាដូចចៅចាក់ស្មុគ។
រឿងរ៉ាវក្នុងលោកកើតឡើងមានហេតុ ឃើញច្បាស់ក្រឡែតម្ដេចមិនសម្រុក
ធ្វើល្អឱ្យច្រើនទើបកើនក្ដីសុខ បើចង់ទៅមុខម្ដេចក៏មិនឈាន។
នេះក៏ចង់ប្រាប់ពីពាក្យកាព្យមួយ អ្នកប្រាជ្ញលោកជួយសម្រាប់ទូន្មាន
ចូរខ្មែររាល់គ្នាកុំធ្វើបំពាន នូវច្បាប់ដែលមានលោកបន្សល់ទុក។
បើចង់ស្រណុកកុំបាច់សិក្សា ចង់បានវិជ្ជាត្រូវលះក្ដីសុខ
វិជ្ជាម្ដេចមានដល់អ្នកស្រណុក ម្ដេចមានក្ដីសុខដល់អ្នកសិក្សា។
លោកបានចងក្រងគាថាផ្ទួនៗ ឱ្យខ្មែរមាំមួនស្វែងរកប្រាជ្ញា
កម្ចាត់ភាពខ្ជិលពីក្នុងចិន្ដា ខំវាយប្រហារខ្មាំងអវិជ្ជា។



www.elibraryofcambodia.org

ជីវិតកើតមកអាស្រ័យព្រោះកម្ម    រស់ច្រើនខែឆ្នាំលំបាកវេទនា
សោយទុក្ខច្រើនជាតិព្រោះខន្ធនានា    ផ្លូវចិត្តគ្រាំគ្រាព្រោះខ្វះបារមី។
ការកើតតែងស្លាប់ជាច្បាប់ជីវិត    នេះគឺធម៌ពិតនៅក្នុងលោកិយ
បើបានដឹងហើយគួរខំឃ្នាតខ្មី    រៀនធម៌បាលីចម្រើនភាវនា។
រឿងរូបកាយនេះវាឥតខ្លឹមសារ    ស្លាប់ហើយកាលណាគេខ្លាចគ្រប់គ្នា
គេយកទៅផុតកប់ឥតរុញរា    មច្ចុទាមទារគ្រប់ៗរូបា។
ខន្ធប្រាំជាទុក្ខមារកាចពិតៗ    បែរជានែបនិត្យនាំគ្នាប្រាថ្នា
ទាំងស្ដេចសេដ្ឋីមន្ត្រីរាជការ    តូចធំកុមារប្រាថ្នាគ្រប់គ្នា។
ម្យ៉ាងទៀតព្រោះតែមិនដឹងការពិត    នូវធម៌បរមត្ថនៃព្រះភគវា
ទោះជាបណ្ឌិតល្ងង់ខ្លៅពាលា    ក្មេងចាស់មិងមាស្លាប់ចោលឥតការណ៍។
កាលនៅពីក្មេងភ្នែកភ្លឺខ្លាំងណាស់    មើលឃើញយ៉ាងច្បាស់គ្មានពាក់វ៉ែនតា
ឥឡូវនេះគ្មានមើលឃើញនរណា    សូម្បីសោតាក៏ថ្លង់អស់ហើយ។
សក់ខ្មៅរលោងរូបស្រស់សង្ហា    ធ្មេញសល្អថ្លាបាក់មិនមានស្បើយ
ដំណើរធ្លាប់ត្រង់ក៏កោងអស់ហើយ    ឱ!ម្ចាស់ថ្លៃអើយដូចព្រាយបិសាច។
បើមើលពីក្រោយដូចជារាងហំ    មើលពីមុខចំគួរឱ្យសែនខ្លាច
សក់ឡើងកន្ទ្រើងបែកចុងសស្វាច    តើពេលនេះអាចដូចមុនបានទេ។
ការឃើញរូបកាយប្រែប្រួលបែបនេះ    គួរតែត្រិះរិះទាំងយើងទាំងគេ
មិនគួរឃឹតឃូរមានចិត្តភរេ    ឱ្យបាបកើតទ្វេពេញក្នុងចិន្ដា។



www.elibraryofcambodia.org

គួរតែធ្វើបុណ្យសម្រាប់ជាយាន     សទ្ធាជាស្ពានជាន់ឆ្លងកាមា
ត្រូវខំធ្វើបុណ្យស្តាប់ធម៌ទេសនា     ទើបមានប្រាជ្ញាដឹងសព្វសេចក្តី។
ជាចុងក្រោយនេះសូមអភ័យទោស     ញាតិមិត្តស្រីប្រុសបណ្ឌិតកវី
ក្រែងមានឆ្គាំឆ្គងលើសពាក្យសម្តី     មិនសមគប្បីគ្មានន័យខ្លឹមសារ។
បើមានកំហុសទោះតូចឬធំ     សូមអស់លោកកុំប្រកាន់ទោសា
គឺជួយប្រាប់ផងកុំចាំតែថា     ថ្ងៃក្រោយភ្លឺថ្លាកែប្រែជាថ្មី។
ដោយអំណាចនៃកងបុណ្យកុសល     សូមឧទ្ទិសដល់បុព្វការី
ពិសេសអ្នកអានអ្នកស្តាប់សេចក្តី     សូមភ្ជាប់និស្ស័យនៃព្រះសម្ពុទ្ធ។
បើសិនមានកូនប្រកបដោយធម៌     បើមានចៅពសូមល្អមុះមុត
បើមានអន្តរាយសូមជៀសឱ្យផុត     បើទុក្ខស្រយុតកុំបីកើតមាន។
បើរៀនផ្លូវធម៌ជាអ្នកឈ្លាសវៃ     កើតជាសេដ្ឋីជាអ្នកឱ្យទាន
បើកើតទីណាកុំបីអត់ឃ្លាន     សូមឱ្យអ្នកមានគំនិតប្រាជ្ញា។
ពុទ្ធពរមានបួនសូមមានដល់អ្នក     កើតប្រាកដជាក់គ្រប់ៗប្រការ
បើស្តាប់ធម៌ព្រះតែមួយគាថា     និព្វានថ្ងៃថ្លាមានដល់អ្នកហោង។

**ដោយសាចណោរ សា ចាន់រ៉ាត់**

**អនុបុព្វេន មេធាវី     ថោកំ ថោកំ ខណេ ខណេ**
**កម្មារោ រជតស្សេវ     និទ្ធមេ មលមត្តនោ ។**

អ្នកមានប្រាជ្ញា គួរកម្ចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្តងៗ រាល់ខណៈ ដោយលំដាប់ ដូចជាងមាសជម្រះស្នឹម ឬច្រែះរបស់មាសដូច្នោះ។(ធម្មបទគាថាទី២៣៩ ចិងកឆេទ៥២)



www.elibraryofcambodia.org

## ៦.គុណនៃព្រះពុទ្ធទ្រង់សម្តែងធម៌

ព្រះពុទ្ធគ្រប់អង្គត្រាស់ដឹងក្នុងលោក មានជ័យមានជោគសែនប្រសើរក្រៃ
ពិតជាកម្រនៅក្នុងភពបី ក្រព្រះជិនស្រីសម្តែងទេសនា។
គ្រាត្រាស់ដំបូងនៅពុទ្ធគយា អង្គព្រះភគវាទ្រង់ព្រះសង្កា
គិតមិនសម្តែងធម៌ដល់សត្វណា ក្តៅដល់ទេវតាពួកព្រហ្មនានា។
ព្រហ្មចុះជួបព្រះសំពះទូលថា សូមព្រះសាស្តាទ្រង់អារាធនា
សម្តែងសច្ចៈគឺព្រះធម្មា ដល់សត្វនានាដែលមាននិស្ស័យ។
ព្រះពុទ្ធទទួលដោយតុណ្ហីភាព ទៅតាមសភាពនៃពុទ្ធវិស័យ
ធ្វើឱ្យសត្វលោកនៅក្នុងភពត្រៃ បានស្តាប់ធម៌ថ្លៃរួចផុតទុក្ខា។
ដោយសារព្រះពុទ្ធទ្រង់បានត្រាស់ដឹង ទើបឥឡូវហ្នឹងយើងបានសិក្សា
បរិស័ទម៉ឺនសែនមានចិត្តជ្រះថ្លា ខ្ពស់ទាបថ្នាក់ណាស្តាប់បានគ្រប់គ្នា។
អន្លង់ទាំងបួនជ្រៅហួសការស្មាន សត្វឆ្លងទៅបានដោយសារសទ្ធា
ម្យ៉ាងមិនប្រមាទរាល់កិច្ចការងារ ព្យាយាមគ្រប់គ្រាព្រមដោយបញ្ញា។
ធម៌ព្រះអរហន្តត្រាស់ដឹងក្នុងលោក បុគ្គលចូលមកធ្វើការសិក្សា
ស្តាប់ហើយត្រិះរិះគិតពិចារណា តែងបានប្រាជ្ញាព្រោះស្តាប់ដោយល្អ។
យើងរៀនបិដកធម៌ព្រះសម្ពុទ្ធ ខ្ពង់ខ្ពស់បំផុតហៅសែនកម្រ
កំណើតជាមនុស្សបានដោយផលល្អ គួរសិក្សាធម៌ព្រះពុទ្ធសាសនា។



www.elibraryofcambodia.org

បុគ្គលណាល្ងង់លង់ក្នុងគំនិត    កិលេសរួបរឹតគ្មានថ្ងៃភ្លឺថ្លា
ពេលស្ដាប់ធម៌ព្រះតែមួយគាថា    កាត់វដ្ដសង្សារឃ្លាងពីអបាយ។
វិជ្ជាក្នុងលោកមានច្រើនអនេក    តាមការបែងចែកពួកគ្រូទាំងឡាយ
មានមន្តអាគមស្ដោះផ្លុំរូបកាយ    ព្រះពុទ្ធទាំងឡាយត្រាស់ថាធម៌ថោក។
ធម៌ទាំងឡាយណារបស់អ្នកស្រុក    សិក្សាគ្រប់មុខមិនផុតទុក្ខសោក
មិនមានប្រយោជន៍អ្នកប្រញាប់ក្រោក    វិជ្ជានោះថោកត្រូវគិតរិះរេ។
នៅក្នុងលោកនេះមានជនពួកខ្លះ    ខ្វះយល់មិនច្បាស់ខំដឹកនាំគេ
ធម៌ព្រះមិនរៀនខ្ជិលដេកលើគ្រែ    អាគមមន្តស្នេហ៍ខំរៀនឆ្វេឆ្វា។
ចំណែកមនុស្សខ្លះគេមាននិស្ស័យ    គំនិតថ្លាថ្លៃរៀនត្រៃសិក្ខា
វិជ្ជាខ្ពង់ខ្ពស់នៅក្នុងលោកា    សីលនិងបញ្ញាសមាធិថ្លៃ។
ឯជនពួកខ្លះសទ្ធាខ្ជាប់ខ្ជួន    ប្រាជ្ញាមាំមួនក្នុងធម៌វិន័យ
ខិតខំចម្រើនភាវនារាល់ថ្ងៃ    តាមព្រះជិនស្រីទ្រង់បង្ហាញផ្លូវ។
ធម៌ជាត្រៃលក្ខណ៍មានគ្រប់រូបា    ទាំងមនុស្សទេវតាតែងតែត្រាច់ទៅ
សរីរៈនេះជាស្ថានជង្គ្រូវ    ក្លិនស្អុយអាស្រូវគួរឱ្យភ័យខ្លាច។
ក្នុងខ្លួនគ្មានខ្លឹមដៃជើងគ្មានន័យ    ឆ្អឹងសាច់សរសៃក៏គ្មានអំណាច
ចុងក្រោយបែកធ្លាយពិតជាមិនអាច    មច្ចុកំណាចពិតមកប្រហារ។
រូបកាយទាំងមូលផ្គុំឡើងយ៉ាងហ្នឹង    គួរតែសញ្ជឹងសង្វេគចិន្ដា
មិនគួរជាប់ស្អិតព្រោះគ្មានបានការណ៍    ឈាមក្រហមថ្លាក៏គ្មានតម្លៃ។



www.elibraryofcambodia.org

កាយសត្វគ្រប់រូបចាស់ទៅៗ ពិតជាគ្មានផ្លូវធ្វើការតែថ្ងៃ
ចុងក្រោយគង់ក្លាយទៅជាចំណី ភ្លើងខ្យល់ទឹកដីរូបធាតុទាំងឡាយ។
សង្ខារទាំងឡាយកើតហើយវិនាស បើរៀនធម៌ព្រះទើបខ្នើមជិនណាយ
ខំធ្វើកុសលទើបសុខសប្បាយ កាយស្លាប់ខ្ចាត់ខ្ចាយតែបុណ្យរក្សា។
រីអស់ស្រីប្រុសអ្នកទាំងឡាយអើយ ព្រះធម៌មានហើយគួរតែសិក្សា
សំណាងខ្លាំងណាស់កើតទាន់សាសនា វិន័យធម៌អាថ៌មានអ្នកសម្តែង។
វិន័យព្រះសូត្រព្រះពុទ្ធផ្សំផ្គុំ ឯអភិធម្មភ្ជិលចិញ្ចែង
ពេលសិក្សាយល់ឃើញច្បាស់ខ្លួនឯង មិនបាច់ថ្វាថ្លែងរៀបរាប់សេចក្តី។
បើសិនមិនរៀនចម្រើនប្រាជ្ញា រស់រាយវស្សាពិតជាគ្មានន័យ
អាយុត្រូវអស់គុណធម៌ត្រូវក្ស័យ គេរស់មួយថ្ងៃមានជ័យជំនះ។
ឈ្មោះថាប្រសើរដោយសារប្រាជ្ញា ធ្លាប់បានសិក្សាអប់រំជម្រះ
យើងដឹងបរមត្ថដូចបានជួបព្រះ យើងលែងសំពះបួងសួងខាងក្រៅ។
គួររកទីពឹងលំនឹងក្នុងចិត្ត មិនគួរនៃបនិត្យពឹងលើញាតិផៅ
អាងទ្រព្យសម្បត្តិពឹងលើកូនចៅ អ្នកប្រាជ្ញលោកហៅទីពឹងនោះខុស។
ជនជាសប្បុរសគេមិនស៊ីយស៊ុន គេខំធ្វើបុណ្យសីលទានចម្រុះ
គេទៅវត្តអារាមទាំងស្រីទាំងប្រុស គេខំដាំដុះសន្សំផលា។
ចំណែកជនពាលទានសីលមិនសាង អង្គុយក្តែងក្តាងអួតផឹកតែស្រា
មើលងាយគេឯងស្អប់អ្នកធម៌អាថ៌ ព្រះសង្ឃទេសនាពួកគេមិនស្តាប់។


www.elibraryofcambodia.org

បើរក្សាសីលថាសីលអំបី ឃើញក្បួនគម្ពីរពួកគេមិនចាប់
ថាលំបាកណាស់បាលីសារស័ព្ទ តោះយើងប្រញាប់ទៅធីកឱ្យឆ្ងាយ។
ការពោលយ៉ាងនេះមិនមានចេតនា បៀតបៀនផ្ទៃផ្កាអស់លោករាល់កាយ
គឺចង់ឱ្យល្អគ្មានក្តីអន្តរាយ មិនបាច់បកស្រាយខ្វីប៉ុណ្ណឹងចុះ។
បុណ្យទាំងប៉ុន្មានខ្ញុំបានធ្វើហើយ ខ្ញុំមិនកន្តើយសូមជូនស្រីប្រុស
ញាតិមិត្តបងប្អូនអស់លោកសប្បុរស ក្មេងចាស់ទាំងអស់សូមបានគ្រប់គ្នា។
ទោះនៅឆ្ងាយជិតមិនស្គាល់យ៉ាងណា សត្វក្នុងសង្សារមិនអាចគណនា
ពេលបានដឹងហើយសូមរួចចាកពៀរ ដោយសារសទ្ធាជឿលើកម្មផល។
បើសិនបានកើតទោះមនុស្សទេវតា ខ្ពស់ទាបថ្នាក់ណាសូមឱ្យបានដល់
សូមសុខសប្បាយកុំមានកង្វល់ មានតែតម្កល់ចិត្តក្នុងព្រះធម៌។

ដោយសាចណោរ សា ចាន់រ៉ាត់

## ៧-អ្នកមានដឹងទេ?

បើសិនជាចង់ដល់គោលដៅមួយ អស់លោកកុំព្រួយផ្តើមពីលេខសូន្យ
ចង់ដល់ត្រើយនាយត្រូវសាងទូកក្បូន ចង់សុខបងប្អូនកុំភ្លេចពាក្យម៉ែ។
ចង់បានចំណេះកុំខ្ជិលឱ្យសោះ ចង់បានភាពស្មោះកុំបីគេចកែ
ចង់បានផលល្អត្រូវខំមើលថៃ ចង់សុខឥតល្ហែសាងសុចរិតកម្ម។

ដោយសាចណោរ សា ចាន់រ៉ាត់


www.elibraryofcambodia.org

# ៨-គុណនៃព្រះធម៌

ផ្ទៃមេឃស្រឡះពីងពីត    មានព្រះអាទិត្យបំភ្លឺដី
ខិតខំបញ្ចេញដួងរស្មី    ជួយឱ្យប្រុសស្រីធ្វើការងារ។
នៅពេលរាត្រីមានដួងចន្ទ    រះខ្ពស់ឡើងកាន់ផ្ទៃមេឃា
ធ្វើឱ្យលោកនេះល្អសោភា    តារានានារះលម្អ។
ពន្លឺក្នុងលោកមានច្រើនណាស់    ប្រុសស្រីឃើញច្បាស់ទើបត្រាច់ចរ
កាន់ទីឆ្ងាយជិតធ្វើរបរ    បានដោយផលល្អពន្លឺគ្រប់។
ព្រះអាទិត្យបំភ្លឺពេលថ្ងៃ    ឯដួងចន្ទថ្ងៃភ្លឺពេលយប់
ក៏គង់ពេលខ្លះមិនអាចសព្វ    មានប្រុសស្រីស្អប់ជាធម្មតា។
អ្វីៗក្នុងលោកមិនអាចផ្គាប់    នេះជាទម្លាប់នៃអ្នកថា
កុំថាឡើយមនុស្សទោះទេវតា    ធ្វើល្អយ៉ាងណាតែងនិន្ទា។
ចំណែកព្រះធម៌ព្រះសម្តែង    ភ្លឺល្អចិញ្ចែងសព្វវេលា
គង់តែទាស់ចិត្តជនពាលា    អ្នកមានសទ្ធាតែងជ្រះថ្លា។
អ្នកណាស្តាប់ធម៌ដោយផ្ចិតផ្ចង់    បានអានិសង្សប្រាំប្រការ
បុគ្គលតាំងចិត្តប្រុងសោតា    ស្តាប់យកធម៌អាថ៌មិនធ្លាប់ឮ។
ធម៌ណាស្តាប់ហើយមិនចូលចិត្ត    ខិតខំរិះគិតរឹតតែភ្លឺ
កម្ចាត់សង្ស័យដូចជម្ងឺ    ប្រែមានពន្លឺថ្លាត្រចង់។



www.elibraryofcambodia.org

អ្នកណាស្តាប់ធម៌ដោយគោរព
ត្រិះរិះសព្វគ្រប់ទិដ្ឋិត្រង់
បុគ្គលញុំាងចិត្តល្អផូរផង់
ផលានិសង្សជួយបំភ្លឺ។
ព្រះពុទ្ធប្រៀបដូចព្រះអាទិត្យ
ឯព្រះធម៌ពិតល្បីរន្ទឺ
ប្រៀបដូចឱសថជួយអ្នកឈឺ
ព្យាបាលជម្ងឺជនប្រុសស្រី។
រីឯសត្វលោកដូចអ្នកឈឺ
ជាពីជម្ងឺផុតទុក្ខភ័យ
ដោយសារមានថ្នាំព្រះជិនស្រី
ត្រាស់ព្រះធម៌ថ្លៃផុតវិយោគ។
ចំណែកព្រះសង្ឃអង្គសាវ័ក
បួសតាមឥតអាក់ព្រះមានជោគ
សិក្សាសង្រួមបាតិមោក្ខ
ពិតផុតទុក្ខសោកជាស្រែបុណ្យ។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**

**ន តាវតា ធម្មធរោ យាវតា ពហុ ភាសតិ**
**យោ ច អប្បម្បិ សុត្វាន ធម្មំ កាយេន បស្សតិ**
**ស វេ ធម្មធរោ ហោតិ យោ ធម្មំ នប្បមជ្ជតិ ។**

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា ឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះមិនទាន់បានទេ លុះត្រាតែបុគ្គលណាស្តាប់ពុទ្ធវចនៈ សូម្បីមានប្រមាណតិច ហើយឃើញធម៌ដោយនាមកាយ គឺចិត្តបាន បុគ្គលនោះទើបឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ បុគ្គលណាមិនមើលងាយធម៌ បុគ្គលនោះឯងឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌។


www.elibraryofcambodia.org

# ៩.គុណនៃព្រះសង្ឃ

សង្ឃជាសាវ័កនៃព្រះពុទ្ធ ខ្ពង់ខ្ពស់បំផុតពីរប្រការ
ដែលជាស្រែបុណ្យជនជ្រះថ្លា បួសហើយកាលណាស្អាតផ្លូវផង។
ព្រះសង្ឃបួសហើយក្នុងសាសនា រៀនត្រៃសិក្ខាដោយផ្ចិតផ្ចង់
លោកប្រតិបត្តិដៅផ្ដោះត្រង់ តាមផ្លូវពុទ្ធអង្គទាំងប្រាំបី។
សម្មតិសង្ឃជាសាវ័ក មិនទាន់ប្រច័ក្សធម៌ប្រពៃ
តែលោកខំណាស់ទាំងយប់ថ្ងៃ រៀនធម៌វិន័យព្រះសម្ពុទ្ធ។
អរិយសង្ឃមានប្រាំបី ទោះបួសចាស់ថ្មីថ្លៃវិសុទ្ធ
លោកបានឃើញហើយទីបំផុត អាស្រ័យព្រះពុទ្ធបង្ហាញផ្លូវ។
ព្រះសង្ឃឈ្មោះថាអ្នកបួសតាម វិន័យជាស្នាមព្រះយាងទៅ
កាន់ទីត្រជាក់ផុតផ្សាក្ដៅ ទីនោះលោកហៅព្រះនិព្វាន។
ព្រះសង្ឃលោកបួសផុតស្រឡះ ដើម្បីឃើញច្បាស់ព្រះទ្រង់ញាណ
ឡើងជិះព្រះធម៌ជាធម្មយាន សទ្ធាជាស្ពានទានជាស្បៀង។
ព្រះសង្ឃបួសហើយសង្រួមណាស់ បាបធំក្រៃក្រាស់លោកជៀសវាង
លោកធម៌ប្រាំបីមិនដែលទៀង អគតិលំអៀងលោកមិនខ្វល់។
សង្ឃជាស្រែបុណ្យពុទ្ធបរិស័ទ ធ្វើទានមិនបាត់តែងបានផល
អាស្រ័យព្រះគុណជួយតម្កល់ ធ្វើឱ្យមគ្គផលរីតតែល្អ។


www.elibraryofcambodia.org

ព្រះសង្ឃមកពីទីផ្សេងគ្នា ចូលមកបព្វជ្ជាដោយស្មោះស
មិនដែលប្រកាន់មានឬក្រ ទោះអាក្រក់ល្អក៏ជាសង្ឃ។
សីលសមាធិនិងបញ្ញា ព្រះសង្ឃឧស្សាហ៍គិតតម្រង់
មិនបានយឺតយូរឬបង្អង់ ខិតខំគ្រប់អង្គគួរជ្រះថ្លា។
ព្រះសង្ឃលោកប្រឹងរៀនខ្លួនឯង រួចទើបសម្តែងធម៌ទេសនា
ពន្យល់ប្រាប់ផ្លូវព្រះសម្មា ដល់ជនជ្រះថ្លាជាខាងក្រោយ។
ព្រះសង្ឃលោកថែធម៌វិន័យ បិដកប្រពៃមិនបណ្តោយ
សង្គាយនាមានមុនក្រោយ យ៉ាងនេះក៏ដោយមិនខុសគ្នា។
បើពោលរៀបរាប់គុណព្រះសង្ឃ រក្សាសីលត្រង់ល្អសោភា
លោកជួយច្រើនណាស់យើងរាល់គ្នា គួរក្រាបវន្ទាដោយគោរព។

ដោយសាមណេរ សា ចាន់រ៉ាត់

**ន មុណ្ឌកេន សមណោ អព្វតោ អលិកំ ភណំ**
**ឥច្ឆាលោភសមាបន្នោ សមណោ កឹ ភវិស្សតិ ។**
**យោ ច សមេតិ បាបានិ អណុំថូលានិ សព្វសោ**
**សមិតត្តា ហិ បាបានំ សមណោតិ បវុច្ចតិ ។**

បុគ្គល មិនបានឈ្មោះជាសមណៈ ដោយភាពជាអ្នកមានក្បាលត្រងោលទេ បុគ្គលអ្នកមិនមានសីលវត្តនិងធុតង្គ ពោលតែពាក្យឡេះឡោះ ប្រកបដោយសេចក្តីប្រាថ្នានិង លោភៈ ឈ្មោះថា ជាសមណៈដូចម្តេចបាន។ លុះត្រាតែបុគ្គលណា រម្ងាប់បាបទាំងឡាយ ទាំងតូចទាំងធំដោយប្រការទាំងពួងបាន ទើបហៅថា សមណៈ ព្រោះបាបទាំងឡាយដែលបុគ្គលនោះរម្ងាប់បានហើយ។ ( **ធម្មបទវគ្គទី១៩ បិដកលេខ៥១**)



www.elibraryofcambodia.org

# ១០.បញ្ហាក្នុងជីវិត

ជីវិតទាំងអស់តែងមានបញ្ហា កើតឡើងកាលណាទុក្ខឥតមានល្ហែ
ចាប់ផ្តើមតាំងពីអាស្រ័យផ្ទៃម៉ែ អស់ច្រើនថ្ងៃខែទុក្ខមិនស្រាកស្រាន្ត។
រូបកូនកើតមកបានជាទារក ខំបៅជញ្ជក់ដោះម្តាយកល្យាណ
សេចក្តីស្រេកឃ្លានដុតរោលខ្លួនប្រាណ កូនរស់ឡើងបានដោយអ្នកម្តាយថ្លៃ។
យប់ថ្ងៃកន្លងរឿងរ៉ាវតូចធំ ទុក្ខក្តៅរងំគ្មានដែលលោះថ្ងៃ
ពីព្រឹកដល់ល្ងាចជួបតែព្រួយភ័យ ឱ!សុខសិរីស្ថិតនៅឯណា។
គ្រប់ៗជីវិតវិចិត្រព្រោះកម្ម សប្បុរសលោកផ្តាំឱ្យប្រឹងឧស្សាហ៍
លះបង់កម្មខ្មៅសម្អាតចិន្តា កម្មនោះហើយណាជាសុខសួស្តី។
ជីវិតកើតមកទោះមានឬក្រ មិនថាខ្មៅសទាំងប្រុសទាំងស្រី
តែងជួបបញ្ហាទុក្ខសោករីងរៃ ហើយតែងភិតភ័យនឹងសេចក្តីស្លាប់។
បញ្ហាមានច្រើននៅក្នុងជីវិត អ្នកដឹងការពិតរួតរះប្រញាប់
រកដំណោះស្រាយដោយប្រឹងខំស្តាប់ ព្រះធម៌ជាច្បាប់ផុតក្តីអន្តរាយ។
ការឈឺចុកចាប់ខ្ពស់ទាបស្គមធាត់ មិនអាចទៀងទាត់ជារឿងរូបកាយ
តែងតែប្រែប្រួលសុខហើយសប្បាយ ចុងក្រោយក៏ក្លាយទៅជាធាតុបួន។
ការព្រួយលំបាករីករាយមែនពិត ជារឿងផ្លូវចិត្តក៏មិនមាំមួន
មិនស្តាប់បញ្ជាបង្គាប់តាមខ្លួន ទុក្ខកើតផ្ទួនៗតាមអំណាចកម្ម។



www.elibraryofcambodia.org

កាលមានជីវិតត្រូវធ្វើការងារ ស្វែងរកទ្រព្យធ្វើបុណ្យប្រចាំ
បើសិនជាខ្ជិលពិតជារងកម្ម ទោះរស់រយឆ្នាំក៏គ្មានន័យដែរ។
ជីវិតរស់នៅទីក្រុងឬផ្សារ សប្បាយហ៊ឺហាខុសពីស្រុកស្រែ
ជនបទធ្វើស្រូវខំដាំបន្លែ លក់ជាហូរហែធៀតធ្វើបុណ្យខ្លះ។
ជីវិតមន្ត្រីគេពឹងប្រាក់ខែ ឯពួកថៅកែគេមិនដែលខ្វះ
ជីវិតកម្មករប្រយ័ត្នខ្លាំងណាស់ មិនចាយផ្តេសផ្តាសខំជួយគ្រួសារ។
ចំណែកព្រះសង្ឃគង់ក្នុងអារាម ខំប្រព្រឹត្តតាមវិន័យធម៌អាថ៌
បរិស័ទធ្វើទានមានចិត្តជ្រះថ្លា ខំលះតណ្ហាចម្រើនកុសល។
យើងកើតទាន់ធម៌ព្រះពុទ្ធសម្តែង គួរខំប្រឹងប្រែងគិតឱ្យបានដល់
ចម្រើនប្រាជ្ញាទើបអស់ចម្ងល់ សិក្សាឱ្យយល់ទើបប្រព្រឹត្តត្រូវ។
សត្វលោកកើតមកប្រាថ្នាចង់សុខ តែរឿងស្មាញស្មុគនាំឱ្យអាស្រូវ
មិនចង់ជួបសោះចាប់ពីឥឡូវ ចង់ជួបតែផ្លូវសុខចម្រើនពិត។
បើសិនជាចង់ជួបសេចក្តីសុខ គួរខំសម្រុកប្រព្រឹត្តសុចរិត
ទើបអស់បញ្ហារឿងរ៉ាវក្នុងចិត្ត បានដល់សុខពិតគឺនិព្វានហោង។

ដោយសាមណេរ សា ចាន់រ៉ាត់

**ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ**
**ទីឃោ ពាលាន សំសារោ សទ្ធម្មំ អវិជានតំ ឡ**

រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឭក (អ្នកដេកមិនលក់)យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង ចំពោះតែបុគ្គលពាល មិនដឹងច្បាស់នូវព្រះសទ្ធម្ម។


www.elibraryofcambodia.org

# ១១. មិនគួរជឿព្រោះតែជំនឿគ្មានហេតុផល

អ្នកនិយាយតាមគំនិតគេយល់ | រឿងរ៉ាវអំពល់គឺអ្នកស្តាប់ទេ
គួររៀនគិតកុំចេះតែជឿគេ | គួរតែរិះរេឱ្យបានហ្មត់ចត់។
សម្តីមានខុសត្រូវជាធម្មតា | តាមតែវោហារមិនអាចប្រាកដ
គេថាគេស្តីត្រូវមានអំណត់ | អ្នកថាតែងហត់យើងតែងបានផល។
សម្តីគ្រាន់តែជាខ្យល់មាត់សោះ | អ្នកស្តាប់ទាំងអស់តែងមានចម្ងល់
អ្នកខ្លះស្តាប់ហើយគិតមិនដល់ | មិនដឹងឫសគល់ថារឿងយ៉ាងណា។
សម្តីគ្មានពណ៌រូបរាងស្គមធាត់ | កើតពីខ្យល់មាត់អ្នកដែលប្រើការ
បើស្តាប់ដោយល្អតែងកើតប្រាជ្ញា | ស្តាប់មិនពិចារណ៍ពិតលង់គំនិត។
អ្នកខ្លះជឿគេគ្រាន់តែឮតគ្នា | ចុងក្រោយគ្រាំគ្រាព្រោះរឿងមិនពិត
ខ្លួនមិនដែលឃើញឬបានទៅជិត | ប្រកាន់ថាមិត្តក៏គួរជឿបាន។
ការជឿតគ្នាពីមួយទៅពីរ | ជាប្រពៃណីមានពីបុរាណ
រឿងខ្លះក៏ល្អគួរកាន់យកបាន | រឿងយល់ស្មានៗគួរតែលះបង់។
សម្តីជនពាលគេតែងតែពោល | បញ្ចុះបញ្ចូលទៅទីគ្មានប្លង់
ដូច្នេះអ្នកស្តាប់គួរតែផ្ចិតផ្ចង់ | ព្រះពុទ្ធគ្រប់អង្គទ្រង់ឱ្យពិចារណ៍។
អ្នកខ្លះជឿគ្រូយ៉ាងមាំស៊ុបសូន | អាងលើគ្រូខ្លួនអាងក្បួនតម្រា
ពេលទុក្ខកើតឡើងខំរត់ឆ្វេឆ្វា | ទុក្ខកើតដោយសារជឿអរូបី។


www.elibraryofcambodia.org

ព្រះពុទ្ធសម្តែងព្រះធម៌យ៉ាងល្អិត បង្ហាញការពិតនៅក្នុងលោកិយ
អ្នកគ្មានសទ្ធាស្តាប់ហើយធ្វើហី ព្រោះគ្មាននិស្ស័យអត់បុណ្យបារមី។
ជំនឿសាសនាមានជាច្រើនផ្នែក តាមការបែងចែកនៃមនុស្សប្រុសស្រី
គោរពបូជាទាំងយប់ទាំងថ្ងៃ ខិតខំកែច្នៃតាមតែខ្លួនយល់។
ចំណែកនៅក្នុងព្រះពុទ្ធសាសនា ប្រាប់ឱ្យសិក្សាអំពីឫសគល់
មិនចេះតែជឿព្រោះនាំអំពល់ ពេលស្តាប់បានយល់សឹមជឿរហូត។
ព្រះពុទ្ធសម្តែងធម៌វិនិច្ឆ័យ ត្រាស់ព្រះធម៌ថ្លៃកាលាមសូត្រ
ប្រាប់ឱ្យមនុស្សលោកធ្វើការពិសោធន៍ ហេតុដប់នោះសោតជួយបានគ្រប់គ្រា។
ទីមួយ **មា អនុស្សវេន** កុំជឿអាងជាក់ព្រោះឮតគ្នា
ហើយចេះតែជឿវាទៈនានា ដឹងគ្រប់អង្គាហើយប្រុងស្មារតី។
ទីពីរ **មា បរម្បរាយ** កុំជឿស្មើរស្មាក់ពាក្យអ្នកដទៃ
អាងថាត្រឹមត្រូវហើយគ្មានសង្ស័យ មិនគិតរំពៃស្វែងរកផ្លូវល្អ។
ទីបី **មា ឥតិករាយ** កុំជឿលើអ្នកនិទានថាល្អ
ឃើញឱ្យបានជាក់ហើយស្តាប់បន្ត កុំជឿតៗតាមប្រពៃណី។
បួន **មា បិដក សម្បទា-** **នេន** គ្រប់គ្នាកុំអាងគម្ពីរ
ប្រកាន់ថាត្រូវមិនខំសំភី ជឿស្លុងគ្មានពីរនៅក្នុងសាសនា។
ទីប្រាំគឺ **មា តក្កហេតុ** កុំជឿផ្តាប់មុខត្រូវពិចារណា
រៀនស្តាប់ឱ្យច្បាស់អំពីហេតុការណ៍ កុំប្រកាន់ថាហេតុនោះវាសម។


www.elibraryofcambodia.org

ទីប្រាំមួយ មា នយហេតុ ពូកជនគ្រប់ស្រុកកុំជឿផ្សេងៗ
កាត់តាមតំរុយប្រកាន់បន្ទំ ហេតុនោះមិនសមគួរកាន់យកបាន។
មា អាការបរិវិត- តេន កុំដាក់ជឿតាមការស្មាន
ដោយអាការៈតាមអនុមាណ ជឿតាមសន្តានបងប្អូនញាតិមិត្ត។
ប្រាំបីនោះ មា ទិដ្ឋិនិជ្ឈា- នក្ខន្តិយា កុំជឿគំនិត
តាមការយល់ឃើញថាសមពិតៗ ដោយការពេញចិត្តក្នុងរឿងនោះផង។
ប្រាំបួននោះគឺ មា ភព្វ រូ- បតា ជាគ្រូប្រកាន់ទ្វេដង
បើបានស្តាប់ហើយជឿស៊ុបតែម្តង ហេតុនោះឯងហោងមិនគួរជឿឡើយ។
ដប់ មា សមណោ ន គរូតិ ត្រូវមានសតិកុំបីកន្តើយ
ប្រកាន់មាំថាសមណៈនេះហើយ អាចនាំដល់ត្រើយផុតក្តីកង្វល់។
សេចក្តីប្រកាន់ដោយមិនបានគិត បានត្រឹមខកចិត្តព្រោះគិតមិនដល់
ប្រាជ្ញាទន់ខ្សោយមិនបានតម្កល់ រៀនពីហេតុផលថាវាយ៉ាងហ្នឹង។
ព្រះពុទ្ធទ្រង់ត្រាស់ពន្យល់សេចក្តី ប្រាប់ជនប្រុសស្រីឱ្យអ្នកបានដឹង
នេះជាកុសលអ្នកត្រូវខំប្រឹង អកុសលហ្នឹងអ្នកត្រូវខំលះ។
ធម៌ទាំងឡាយនេះអ្នកប្រាជ្ញសរសើរ ទៅតាមដំណើរប្រញាប់រួតរះ
ព្រោះមានប្រយោជន៍ដោយបានជួបព្រះ រៀនឱ្យជ្រៅជ្រះទើបជួបសុខពិត។
តាមពិតជំនឿជឿក៏ជឿចុះ តែសូមស្រីប្រុសឱ្យច្បាស់ក្នុងចិត្ត
ប្រយ័ត្នជឿហើយនាំទុក្ខវិបរិត ព្រោះតែគំនិតគិតខ្វះប្រាជ្ញា។


www.elibraryofcambodia.org

ខ្ញុំពោលប៉ុណ្ណេះហាក់ដូចជាធ្ងន់ សូមអស់មហាជនអភ័យទោសា
បើមានកំហុសសូមទានមេត្តា ជួយប្រាប់ផងណាំខ្ញុំនឹងកែប្រែ។
ការពោលយ៉ាងនេះព្រោះចង់ឱ្យល្អ ខ្មៅទៅជាសទេណាំពុកម៉ែ
បើស្តាប់រួចហើយសូមឱ្យបានល្អៃ កូនជូនបុណ្យម៉ែនិងលោកឪពុក។
ដោយអំណាចនៃបុណ្យទាំងប៉ុន្មាន ដែលរូបកូនបានធ្វើហើយសព្វមុខ
សូមជូនបងប្អូនជាតិខ្មែរចាំទុក តទៅជាតិមុខដល់និព្វានហោង។

*សូមអនុមោទនា !!!*

**ដោយសាចណោរ សា ចាន់រ៉ាត់**

☛ អ្នកល្ងង់ជួបនឹងអ្វីភ្លាមក៏ជឿថាអញ្ចេះឬអញ្ចុះភ្លាមៗ ដោយមិនចាំបាច់ពិគ្រោះឬស្តាប់អ្នកណាឡើយ។ The foolish believe in their first perception, Leaving no space for another.

## ១២_ រស់នៅកុំអោច

អ្នកល្ងង់រឹតតែល្ងង់ព្រោះធ្វើចេះ អ្នកចេះរឹតតែចេះព្រោះសិក្សា
រៀនអានរៀនគិតមិនចេះតែថា មិនអួតអាត្មាតែយល់ប្រយោជន៍។
អ្នកក្រវឹតតែក្រព្រោះធ្វើមាន មិនខំធ្វើទានសាងកម្មអសោចិ៍
រស់នៅជាមនុស្សចិត្តស្លាប់ជាខ្មោច មុនស្លាប់យ៉ាងហោចត្រូវមានសីលប្រាំ។
អាយុមានតិចតែបានសាងល្អ ធ្វើបុណ្យបន្តសាងគុណប្រចាំ
នេះហៅមានជោគខ្ញុំសូមផ្តែផ្តាំ សាងសុចរិតកម្មទើបអ្នកបានសុខ។

**ដោយសាចណោរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

# ១៣.កូនក្បាក់ខ្លួនហើយ

វិប្បដិសារីដូចទឹកជំនន់ កំហុសយ៉ាងធ្ងន់ពេលធ្វើកន្លង
មិនស្ដាប់ម៉ែឪគោរពរៀមច្បង លេងល្បែងស៊ីសងស្រីស្រាគ្រឿងញៀន។
ខ្លួននៅឯផ្ទះមិនខំសិក្សា ពេលទៅសាលាមិនគិតខំរៀន
មិនគិតវែងឆ្ងាយធ្វើតាមស្រេកឃ្លាន ហ៊ានធ្វើបំពានដោយឥតអៀនខ្មាស។
រដូវខែបុណ្យគេទៅវត្តវ៉ា ខ្លួននៅផឹកស្រាទៅរាំធុងបាស
ខារ៉ាអូខេច្រៀងរាំផ្ដេសផ្ដាស ពូកែខ្លាំងណាស់ខាងផ្លូវអបាយ។
បើទៅបុណ្យទានថាអស់ប្រាក់មាស លេងល្បែងនៅផ្ទះអួតថាសប្បាយ
តែងស្រវឹងជ្រប់មិនគិតខ្វល់ខ្វាយ ជួយឪពុកម្ដាយប្រកបការងារ។
ពីព្រឹកដល់ល្ងាចដើរគ្មានចូលផ្ទះ ដេកដល់ថ្ងៃរះគំនិតពាលា
មិនអាណិតម្ដាយដែលចាស់ជរា ឪពុកគ្រាំគ្រាព្រួយពេញចិន្ដា។
បើទៅជិតឆ្ងាយគេមើលមិនបាន ចិត្តខ្មៅសាមាន្យកាចដូចសត្វខ្លា
ខ្លួននៅស្រុកស្រែចិត្តជាអ្នកផ្សារ សប្បាយនឹងស្រាសង្ហានឹងស្រី។
កំហុសតូចធំព្រោះភ្លេចគំនិត ហើយទៅគប់មិត្តមានចិត្តអប្រិយ
មិនដឹងសខ្មៅបាបបុណ្យទោសពៃរ៍ ស្រវឹងនឹងវ័យភ្លេចកសាងខ្លួន។
ឱ!អ្នកម្ដាយអើយនិងលោកឪពុក លោកតែងរងទុក្ខតែគ្មានគុំកួន
នៅតែស្រឡាញ់កូនស្រស់នឹមនួន ហើយជួយផ្ដួនៗលោកត្រាប្រណី។



www.elibraryofcambodia.org

ពេលកំពុងធ្វើខ្លួនកូនមិនដឹង
ជិតនឹងធ្លាក់ជ្រោះនរកលោកិយ
ឱ!អ្នកម្តាយអើយកូនស្តាយណាស់
តែកូនសន្យាតទៅថ្ងៃមុខ
ឱ!អ្នកមានគុណលោកឪពុកម្តាយ
ព្យាយាមកែខ្លួនស្វែងរកប្រាជ្ញា
កូននឹងធ្វើបុណ្យខំរក្សាសីល
គឺធ្វើការងារទោះយប់ឬថ្ងៃ
កូននឹងស្តាប់ធម៌ព្រះសង្ឃសម្តែង
មិនឱ្យម្តាយព្រួយឪពុកគ្រាំគ្រា
កំហុសម្នាក់ៗមានជាធម្មតា
គឺកែកំហុសមិនឱ្យមកជិត
ដូច្នេះប្រុសស្រីទាំងឡាយអើយ
ចូរដឹងគុណម្តាយឪពុកប្រពៃ
លោកមានជីវិតរស់នៅសព្វថ្ងៃ
លោកទទួលហើយមានចិត្តជ្រះថ្លា

តែឥឡូវហ្នឹងកូនភ្ញាក់ស្មារតី
ទឹកដោះម្តាយថ្លៃជួយកូនផុតទុក្ខ។
ប្រព្រឹត្តផ្តេសផ្តាសលើលោកឪពុក
មិនឱ្យម៉ែពុកលំបាកកាយា។
កូននឹងខំខ្វល់ខ្វាយក្នុងការសិក្សា
លើកស្ទួយគ្រួសារឱ្យសុខសួស្តី។
រូបកូនមិនខ្ជិលដូចកាលក្មេងវ័យ
សន្សំសំចៃមិនចាយខ្ជីខ្ជា។
ត្រិះរិះប្រឹងប្រែងរៀនរាល់វេលា
កូននឹងក្លាយជាមនុស្សមានគំនិត។
តែរឿងអស្ចារ្យហើយគួរឱ្យគិត
ហើយលែងប្រព្រឹត្តធ្វើសារជាថ្មី។
ខ្ញុំប្រាប់ឱ្យហើយមិនលាក់បាំងអី
បើគាត់ក្សិណក្ស័យបានអីពិសា។
ជូននំចំណីនិងម្ហូបអាហារ
សុខគ្រប់ប្រការមានដល់អ្នកហោង។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

# ១៤. ដំណើរជីវិត

ជីវិតអ្នកក្រុងគេហ៊ឺហា ផ្ទះថ្មីឡានរថយន្តថ្មី
អ្នកស្រែផ្ទះស្បូវសង់ជាប់ដី ខោអាវថ្មីៗក៏គ្មានដែរ។
ដងផ្លូវទីក្រុងឡានម៉ូតូ កង់ឬស៊ីក្លូមិនដូចស្រែ
រស់នៅឆ្ងាយស្រុកនឹកពុកម៉ែ កើតទុក្ខឥតល្ហែគ្រប់វេលា។
ឱ!ពុកម៉ែអើយអ្នកដឹងទេ កូននៅស្រុកគេសែនវេទនា
នឹកបងនឹកប្អូនគ្រប់ៗគ្នា នឹកឃើញកាលគ្រានៅក្មេងវ័យ។
ដីស្រែចម្ការកេរ្តិ៍ពុកម៉ែ គិតរាល់ថ្ងៃខែមិត្តប្រុសស្រី
ក្តុកក្តួលក្នុងចិត្តហួសពោលស្តី ពិបាកយកន័យមកពណ៌នា។
នេះគ្រាន់តែជារឿងខ្លួនផ្ទាល់ អស់លោកកុំឆ្ងល់គ្រប់អង្គា
រឿងនេះគឺមានគ្រប់ៗគ្នា មានរាល់វេលាកុំសង្ស័យ។
ជាក់ស្តែងសត្វលោកកើតតែងស្លាប់ ទោះយូរឬឆាប់ត្រូវតែក្ស័យ
មច្ចុកំណាចចិត្តអប្រិយ មិនគិតប្រណីសត្វលោកឡើយ។
ទោះជនណាៗចាស់ក្មេងខ្ចី បណ្ឌិតពាលក្តីស្លាប់ឥតស្បើយ
ជរាព្យាធិខិតជិតហើយ អ្នកមានក្រអើយចាំគ្រប់គ្នា។
អ្នកបើករថយន្តពឹងផ្លូវថ្នល់ សត្វក្នុងសាកលពឹងធម្មា
បើរស់ខ្វះសីលសែនកំព្រា បើខ្វះធម្មាគ្មាននិស្ស័យ។



www.elibraryofcambodia.org

ពិតណាស់ភាជន៍ដីស្ងួនឆ្នាំងធ្វើ តូចធំជម្ដើឆ្អិនឆៅក្ដី
តែងតែបែកធ្លាយទៅជាដី សត្វក្នុងលោកិយក៏ដូចគ្នា។
រឿងសង្សារវដ្ដដឹងមិនបាន វាក់ជ្រៅប៉ុន្មានហួសគណនា
ហើយវែងចំពោះជនពាលា មិនដឹងធម្មាព្រះសម្ដែង។
ដំណើរជីវិតសែនគ្រោះថ្នាក់ រឿងរ៉ាវឧបសគ្គគ្រប់កន្លែង
មានតែតួកម្មអ្នកចាត់ចែង ថៅកែទាបខ្លួនឯងជាអ្នកធ្វើ។
បើសិនបានរស់មួយរយឆ្នាំ សីលទានមិនចាំល្ងង់ល្ងីល្ងើ
មិនដឹងបាបបុណ្យចេះតែធ្វើ អាស្រ័យទង្វើនោះនាំផ្លូវ។
ជីវិតរស់នៅខ្វះព្យាយាម ភាពខ្ជិលរវាមក៏នាំទៅ
គឺនាំសត្វលោកគ្មានគោលដៅ ធ្លាក់អបាយជ្រៅច្រើនខែឆ្នាំ។
ចំណែកសត្វលោករស់មួយថ្ងៃ គំនិតថ្លាថ្លៃជាប្រចាំ
ខិតខំធ្វើតែកុសលកម្ម ទោះតិចខែឆ្នាំតែមានន័យ។
បើបានដឹងច្បាស់ពីដំណើរ គួរខិតខំធ្វើល្អរាល់ថ្ងៃ
អប់រំកាយចិត្តវាចាថ្លៃ ជីវិតប្រពៃព្រោះតែស្ងប់។
ម្យ៉ាងទៀតជីវិតដូចឆាកល្ខោន ប្រសើរអាប់ឱនមានសាយសព្វ
តួឯកតួរងគេគ្រប់ជប់ តួយក្សឡប់ៗគួរមុខមាត់។
ពេលដែលសម្ដែងស្ដេចសេដ្ឋី អាមាត្យប្រុសស្រីមានស្គមធាត់
មានអ្នកបម្រើឆ្វេងស្ដាំគាត់ នោះស្ដែងប្រាកដតែលើឆាក។

យ៉ាងណាជីវិតក៏ដូចគ្នា មានក្រលួជាទុក្ខឥតស្រាក
មានតែតួកម្មជាវិបាក មិននៅឆ្ងាយចាកពីសត្វលោក។
កម្មអ្នកតែងខ្លួនពួនតែងរៀង វិចិត្រគ្រប់គ្រឿងដើរទៅមក
ហើយឱ្យសម្ដែងយំទូញសោក សប្បាយវិយោគតាមតែចិត្ត។
អ្នកស្ដាប់ធម៌ព្រះមានប្រាថ្នា យល់ដឹងធម៌អាថ៌មិនវិបរិត
ខំដុសសម្អាតខាងផ្លូវចិត្ត គង់ជួបធម៌ពិតឥតក្លែងក្លាយ។
ព្រះធម៌ជាយានមានតម្លៃ ព្រះសង្ឃថ្លាថ្លៃនៅមិនឆ្ងាយ
ឱ្យតែសត្វលោករាល់រូបកាយ មានចិត្តជិនណាយក្នុងលោកនេះ។
ត្រៃយានល្អស្រស់ជារតនៈ ខ្ពង់ខ្ពស់ហួសថ្នាក់គួរត្រិះរិះ
យាននាំដល់ត្រើយគួរឱ្យជិះ ជាយានជំនិះឆ្លងលោកា។
ខ្ញុំពោលប៉ុណ្ណេះទោះត្រូវខុស អស់លោកស្រីប្រុសអត់ទោសា
ទុកជាគំនិតពិចារណា មាគ៌ាថ្ងៃថ្លាឆ្ពោះនិព្វាន។

**ដោយសាមណេរ សា មាន់រ៉ាត់**

**បរិជិណ្ណមិទំ រូបំ រោគនិឌ្ឌំ បភង្គុណំ**
**ភិជ្ជតិ បូតិ សន្ទេហោ មរណន្តំ ហិ ជីវិតំ ។**

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសំណាក់នៃរោគ ជារបស់ពុកផុយរាងកាយជារបស់ស្អុយ (នេះ) តែងបែកធ្លាយទៅវិញ ព្រោះថា ជីវិតមានសេចក្ដីស្លាប់ជាទីបំផុត។


www.elibraryofcambodia.org

# ១៥-អ្នកមានគុណខ្ញុំ

បក្សីទាំងឡាយរស់ក្នុងព្រៃក្បា ឯងហ្វូងមច្ឆារស់ក្នុងគង្គា
ពពកទាំងឡាយស្ថិតក្នុងមេឃា ច្រើនហួសគណនាត្រារាប់ពុំបាន។
មហាសមុទ្រធំឥតកោះត្រើយ មើលមិនឃើញឡើយរាក់ជ្រៅប៉ុន្មាន
ផែនដីទាំងមូលគង់ដឹងប្រមាណ ស្រាវជ្រាវយល់បានដឹងពីទំហំ។
ការធ្វើដំណើរទៅមកជិតឆ្ងាយ គង់ដឹងចម្ងាយគេវាស់ផ្សំផ្គុំ
ភ្នំព្រះសុមេរុខ្ពស់ហើយសែនធំ ចាញ់គុណម្តាយខ្ញុំនិងលោកឪពុក។
ព្រៃភ្នំក្រមថ្មទឹកជ្រោះសែនជ្រៅ មានសត្វរស់នៅយ៉ាងច្រើនសព្វមុខ
គឺជាជម្រកសត្វតែងបានសុខ មិនដូចនៅស្រុកគេកាប់ប្រហារ។
យ៉ាងណាអ្នកម្តាយទាំងអស់ក្នុងលោក គឺជាជម្រកប្រសើរអស្ចារ្យ
ចិញ្ចឹមថៃកូនដោយចិត្តមេត្តា ហើយតែងប្រាថ្នាឱ្យកូនបានល្អ។
នាទីជាម្តាយលោកមិនដែលភ្លេច ចងចាំជានិច្ចទឹកចិត្តស្មោះស
មិនឱ្យធ្វើបាបឱ្យកូនធ្វើល្អ ឱ្យកូនព្រេកអរក្នុងការសិក្សា។
ពេលកូនធំឡើងក្រមុំកម្លោះ សុខមាត់ស្រស់បស់ឱ្យមានគ្រួសារ
ចែកទ្រព្យឱ្យកូនមិនស្តាយឡើយណា ទោះតិចម្តេចម្តាមិនឱ្យមានហ្មង។
មាតាបិតាមានធម៌ក្នុងខ្លួន ព្រហ្មវិហារបួនដ៏ល្អច្បាស់ច្បង
ជាព្រះអរហន្តគុណល្អឥតហ្មង កុំធ្វើកន្ទងមានទោសធ្ងន់ណាស់។
កូនខ្លះគ្រោះថ្នាក់គេបន់ទេវតា សំពះអ្នកតាខ្មោចព្រៃផ្តេសផ្តាស



www.elibraryofcambodia.org

ឯម្ដាយមានគុណឪពុកខ្លួនចាស់ មិនតបគុណខ្លះបែរជាធ្វើហី។
មានកូនពួកខ្លះថាព្រហ្មលិខិត អាយុជីវិតមនុស្សក្នុងលោកិយ
នឹកគុណមិនដល់ទឹកដោះម្ដាយថ្លៃ ចិញ្ចឹមរាល់ថ្ងៃព្រហ្មណាមកជួយ។
តាំងពីកូនមកអាស្រ័យក្នុងផ្ទៃ ម្ដាយតែងរំពៃពេញដោយក្ដីព្រួយ
បើម្ដាយគ្រោះថ្នាក់កូនម្ដាយតែមួយ ពិតគ្មានជំនួយតក្ស័យជីវិត។
កុលបុត្រក្នុងលោកទាំងស្រីទាំងប្រុស ចូរគិតមើលចុះស្វែងរកការពិត
កុំចេះតែពោលដោយមិនបានគិត កុំបីប្រឌិតគុណអ្នកម្ដាយថ្លៃ។
បើម្ដាយនៅរស់អ្នកត្រូវតបគុណ ចូរខំធ្វើបុណ្យឱ្យគាត់រាល់ថ្ងៃ
កុំចាំម្ដាយឈឺទើបនឹកស្រមៃ ជូនចំណីឱ្យគាត់ពិសា។
ចំណែកឪពុកអ្នកត្រូវមើលថែ រៀងរាល់ថ្ងៃខែកុំភ្លេចឡើយណា
ទឹកក្ដៅត្រជាក់ខោអាវអាហារ ចូរអ្នកឧស្សាហ៍បុណ្យកើតរាល់ថ្ងៃ។
បើបានយល់ហើយចូរអ្នកខំប្រឹង ពីឥឡូវហ្នឹងកុំបីសង្ស័យ
ម្ដាយអ្នកបានហួបឪអ្នកអរក្រៃ គាត់ជូនពរជ័យឱ្យអ្នកសុខហោង។

**ដោយសាមណេរ សា ចាន់រ៉ាត់**

**អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ**
**តិណ្ណំ អញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។**

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឱ្យល្អ គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំងបី វ័យណាមួយ។


www.elibraryofcambodia.org

# ១៦.តម្លៃសិក្សាក្នុងជីវិត

វិជ្ជាទាំងឡាយបានព្រោះឧស្សាហ៍ ជីវិតភ្លឺថ្លាដោយសារគំនិត
រស់នៅបានយូរច្រើនឆ្នាំមែនពិត រស់សាងទុច្ចរិតហៅគ្មានតម្លៃ។
ជីវិតមានតិចតែបានសាងល្អ រស់បានដោយក្រសូម្បីមួយថ្ងៃ
ទោះអាយុអស់គុណធម៌មិនក្ស័យ ឯចាបចង្រៃលះចេញឱ្យបាន។
យប់១៥រោចងងឹតខ្លាំងណាស់ មើលអ្វីមិនច្បាស់ទៅមកស្មានៗ
គង់ចាញ់ភាពល្ងង់ក្នុងចិត្តសន្តាន នាំឱ្យវិនាសក្នុងវដ្តសង្សារ។
ជីវិតប្រសើរបានសុខស្ងប់ពិត លុះត្រាញាតិមិត្តចិត្តល្អភ្លឺថ្លា
ដឹងថាខ្លួនល្ងង់ហើយខំសិក្សា នឹងអាចបានការណ៍ទៅជាបណ្ឌិត។
ចំណែកជនណាអួតថាចេះដឹង មិនគិតខំប្រឹងចម្រើនគំនិត
មានៈដូចខ្លាកោងកាចមែនពិត ល្ងង់មួយជីវិតព្រោះមិនស្តាប់គេ។
វិជ្ជាជាទ្រព្យគាប់ចិត្តប្រុសស្រី ឱ្យតែឃ្លាតខ្ជីរៀនគិតរិះរេ
បើសិនជាខ្ជិលពឹងចំណេះគេ មិនបានសុខទេជួបតែបញ្ហា។
ចំណេះទាំងឡាយដូចប្រទីបធំ ភ្លឺគ្រប់និគមមិនថាទីណា
ឱ្យតែប្រើត្រូវពិតជាបានការណ៍ ប្រើមិនពិចារណ៍ពិតជាចំបែង។
វិជ្ជាប្រៀបដូចអាវុធមុខពីរ ម្ចាស់កាន់គ្រវីជូនមុតខ្លួនឯង
កុំថាឡើយម្ចាស់ទោះជាអ្នកផ្សេង មុតឥតកោតក្រែងមិនយល់មុខឡើយ។


www.elibraryofcambodia.org

តាមពិតរៀនអ្វីក៏រៀនទៅចុះ តែសូមស្រីប្រុសគិតទុកឱ្យហើយ
រៀនមិនផុតទុក្ខមិនជួបកោះត្រើយ ការរៀននោះហើយមិនផុតវិបរិត។
ការឆ្លងដោយទូកពឹងលើច្រវ៉ា ជីវិតស្រស់ថ្លាពឹងលើគំនិត
បើរៀនខ្ពស់ហើយរឹតតែល្ងង់ពិត ចូរអ្នករិះគិតប្រើឱ្យបានការណ៍។
តាមពិតរៀនអ្វីគឺរៀនឱ្យចេះ ហើយប្រើចំណេះដែលធ្លាប់សិក្សា
ប្រកបអាជីពស្វែងរកខ្លឹមសារ កុំឱ្យគេថារៀនណាស់ល្ងង់ណាស់។
ជីវិតមនុស្សល្ងង់ប្រើកម្លាំងបាយ ធ្វើការទាំងឡាយពីក្មេងដល់ចាស់
ដោយសារតែល្ងង់ប្រាជ្ញាមិនក្រាស់ ធ្វើអ្វីផ្តេសផ្តាសតាមតែខ្លួនយល់។
ចំណែកអ្នកចេះគេប្រើប្រាជ្ញា រស់នៅហ៊ឺហាមិនដែលអំពល់
ជួលមនុស្សធ្វើការខ្លួនមិនរវល់ មិនបាច់ជីកគល់កាប់គាស់លីសែង។
ម្យ៉ាងទៀតបើល្ងង់រកស៊ីធ្វើការ គ្មានពឹងនរណាក្រៅពីខ្លួនឯង
រកស៊ីលំបាកជីវិតដូចផ្សែង រស់ទាំងចំបែងទុក្ខឥតមានស្បើយ។
បើសិនមិនបានខិតខំសិក្សា ចម្រើនប្រាជ្ញាត្រៀមទុកឱ្យហើយ
ពេលជួបបញ្ហាដោះមិនរួចឡើយ គឺគ្មានចម្លើយប្រាប់ផ្លូវអ្នកទេ។
ដូច្នេះសរុបសេចក្តីមកចុះ អស់លោកស្រីប្រុសចូរគិតរិះរេ
បើមានឱកាសគួររៀននឹងគេ ចំណេះកើតទ្វេទើបអ្នកសុខហោង។

*សូមអនុមោទនា !!!*

**ដោយសាចណោរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ១៧_បុណ្យមិនភ្លេចអ្នក មានតែអ្នកភ្លេចបុណ្យ

ទ្រព្យបុណ្យយសសក្តិ មុខមាត់ឋានៈ និងម្ហូបអាហារ
យានយន្តទំនើប ដីស្រែចម្ការ លុយចាយហ៊ុហា
មិនដែលមានខ្វះ។

ជីវិតបានខ្ពស់ ប្រសើរដោយយស ពីក្មេងដល់ចាស់
មានតែជោគជ័យ គ្រប់វ័យល្អល្អះ បានសុខខ្លាំងណាស់
បុណ្យចាស់ឱ្យផល។

គ្រប់រូបប្រុសស្រី កើតក្នុងលោកិយ ចូរគិតឱ្យដល់
តាំងចិត្តសាងល្អ សន្សំកុសល ទុកដូចជាថ្នល់
ក្នុងវដ្តសង្សារ។

ម្យ៉ាងកុសលកម្ម ប្រុសស្រីត្រូវចាំ កុំភ្លេចឡើយណា
បានរស់ជួបជុំ ឥតមានប្រេះឆា បុណ្យពិតអស្ចារ្យ
ដោយសារអ្នកសាង។

អាយុវែងពិត ព្រោះកម្មវិចិត្រ រស់នៅកុំអាង
លើទ្រព្យញាតិមិត្ត រស់នៅជិតខាង ហើយអួតក្អេងក្អាង
ថាខ្លួនមិនស្លាប់។


www.elibraryofcambodia.org

រស់ត្រូវសាងបុណ្យ បន្តធ្វើគុណ ហើយគោរពច្បាប់
ទោះជាក្រីក្រ លំបាកយ៉ាកយ៉ាប់ កុំឱ្យតែស្លាប់
ប្រាជ្ញាស្មារតី។
បើគំនិតល្ងង់ ពិតជាត្រូវលង់ នរកលោកិយ
មិនមានក្ដីសុខ ជួបតែព្រួយភ័យ មិនស្គាល់សិរី
ព្រោះមិនសាងទុក។
បើរស់សប្បាយ រិះគិតខ្វល់ខ្វាយ ធ្វើបុណ្យទៅមុខ
បើសាងទុច្ចរិត រស់ដូចជាប់គុក រស់នៅជាទុក្ខ
វិលវល់ដូចផ្សេង។
អស់លោកសប្បុរស ក្មេងចាស់ទាំងអស់ ចូរជួយខ្លួនឯង
រកទីពឹងពិត កុំឱ្យចំបែង ហើយខំប្រឹងប្រែង
ធ្វើបុណ្យចុះណា។
បើមិនដូច្នោះ បងប្អូនស្រីប្រុស ពិតជាសោកា
គឺនឹកស្ដាយក្រោយ ពេលជួបទុក្ខា ទុក្ខកើតដោយសារ
រស់ហើយភ្លេចបុណ្យ។
*សូមអនុមោទនា !!!*
**ដោយសាមណេរ សា ចាន់រ៉ាត់**


www.elibraryofcambodia.org

# ១៨-បំណុលជីវិត

អ្នកក្រុងហ៊ីហាទិញចូលលក់ចេញ ជនបទនោះវិញធ្វើស្រែចម្ការ
ពីរដូវប្រាំងទល់ខែវស្សា ខិតខំឧស្សាហ៍សន្សំទ្រព្យធន។
ជីវិតកម្មករធ្វើការជូនគេ ពុំស្វេទំនេរការងារស្រាលធ្ងន់
ធ្វើទាំងយប់ថ្ងៃមិនដែលទម្រន់ មិនដែលល្មួចប្លន់គំនិតស្មោះស។
ទាហ៊ានកងទ័ពការពារទឹកដី ឯពួកមន្ត្រីជួយជាតិបន្ត
ធ្វើគ្រូបង្រៀនចង់ឱ្យសិស្សល្អ អ្នកភ័យខ្លាចក្រទើបខំធ្វើការ។
យប់ហើយនិងថ្ងៃខ្លួនកាន់តែចាស់ ម្នាក់ៗខំណាស់លើកស្ទួយអាត្មា
ចង់ឱ្យខ្លួនល្អរស់បានសុខា លំបាកម្ដេចម្ដាឱ្យតែបានរស់។
ពេលខ្លះខ្លួនមានភ្លេចគិតដល់ក្រ មិនសាងធម៌សធ្វើតែបាបគ្រោះ
ស្រវឹងនឹងទ្រព្យជាប់គ្រឿងសក្តិយស ខ្លួនជិតធ្លាក់ជ្រោះទើបភ្ញាក់ស្មារតី។
ធម្មតាមានទ្រព្យក៏មានទៅចុះ កុំភ្លេចស្រីប្រុសសាងទានបារមី
បើអត់សីលទេវិះវេឃ្លាតខ្ចី សីលប្រាំប្រាំបីកាន់យកឱ្យបាន។
ជីវិតប្រៀបដូចជាការដើរផ្លូវ ជួបទឹកសែនជ្រៅឆ្ងាយហួសការស្មាន
បើសិនគ្មានទូកពិតជាខកប្រាណ ឆ្លងទៅមិនបានដល់ត្រើយនាយឡើយ។
ម្យ៉ាងជីវិតនេះដូចខ្ចីពីគេ នៅមិនយូរទេគេទារវិញហើយ
គួរខំប្រញាប់កុំបីកន្តើយ សាងគុណឱ្យហើយទុកជាទីពឹង។



www.elibraryofcambodia.org

សុខភាពរឹងប៉ឹងរូបកាយស្គមធាត់ ពិតមិនទៀងទាត់រឿងនេះត្រូវដឹង
មិនយូរប៉ុន្មានដេកស្លាប់ស្តូកស្តឹង កាយនេះឯងរឹងដូចអង្កត់ឧស។
មែនហើយបានរស់គួររៀនធម៌អាថ៌ ទើបមានប្រាជ្ញាគេចផុតពីខុស
ដោយសារយល់ត្រូវចេះគិតសន្តោស ទានសីលចម្រុះសងបំណុលចាស់។
ដូច្នេះសប្បុរសដែលបានដឹងហើយ ចូរកុំកន្តើយគិតឱ្យបានច្បាស់
ធ្វើការរកស៊ីឆ្លៀតស្តាប់ធម៌ខ្លះ កុំប្រែក្រឡាស់ពីបុណ្យកុសល។
គួរតែរិះរេទៅវត្តទៅវ៉ា កុំជាប់ស្រីស្រាគ្រឿងនាំខ្វាយខ្វល់
គួររៀនធម៌ព្រះចម្រើនមគ្គផល កម្ចាត់ចម្ងល់សម្អាតចិន្តា។
គួរសាងបុណ្យថ្មីប្រល័យបាបចាស់ គំនិតផ្តេសផ្តាសកុំមានឡើយណា
ផុសខាត់ភាពខ្ជិលខិតខំឧស្សាហ៍ សាងធម៌មេត្តាកុំបីរុញរា។
ម្យ៉ាងទៀតរស់នៅជួបជុំញាតិមិត្ត ត្រូវតែអាណិតកុំបៀតបៀនគ្នា
ចង់ឱ្យខ្លួនល្អចូរកុំនិន្ទា នាំពៀរវេរាទុក្ខសោកវែងឆ្ងាយ។
ប៉ុណ្ណឹងសិនចុះអស់លោកប្រុសស្រី សូមបញ្ចប់ខ្ចីឃ្លាតទាំងសោកស្តាយ
សូមជូនបុណ្យអ្នកកុំមានអន្តរាយ ជួបតែសប្បាយក្នុងក្រុមគ្រួសារ។
ម្យ៉ាងទៀតបើមានភពជាតិកំណើត សូមឱ្យបានកើតជួបនឹងសាសនា
នៃព្រះសម្ពុទ្ធបរិសុទ្ធអស្ចារ្យ ឆ្លងវដ្តសង្សារលុះនិព្វានហោង។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

# ១៩.សម្លេងព្រះធម៌

សម្លេងបក្សីលម្អព្រឹក្សា
ខិតខំពន្យល់បាលីសារសព្ទ
សម្លេងចម្រៀងអាចលង់អារម្មណ៍
សម្លេងអ្នកម្ដាយពីរោះអស្ចារ្យ
សម្លេងព្រះធម៌ព្រះពុទ្ធទេសនា
ពេលបានស្ដាប់ហើយគ្រប់សត្តនិករ
ធម៌ព្រះសម្ពុទ្ធប្រសើរអនេក
ធម៌ដូចយានធំឆ្លងផុតមរណា
ពាក្យថាព្រះធម៌មានតម្លៃណាស់
ព្យាយាមរឿយៗត្រិះរិះអំណត់
ធ្វើការស្រាលធ្ងន់ពិបាកកាយពិត
ទោះជីវិតអស់កាយត្រូវជរា
ដូច្នេះអស់លោកសប្បុរសប្រុសស្រី
លះកាត់ចិត្តបាបទិដ្ឋិមានះ
ពេលនេះព្រះធម៌កំពុងរះហើយ
កុំឱ្យភាពល្ងង់ដឹកនាំសន្ដាន

សម្លេងទេសនាជួយដល់អ្នកស្ដាប់
ព្រះធម៌ជាច្បាប់គួរឱ្យសិក្សា។
ឯព្រះសទ្ធម្មនាំឱ្យជ្រះថ្លា
បំពេកាលណាកូនតែងត្រេកអរ។
មានហេតុអស្ចារ្យហៅសែនកម្រ
តែងមានអំណររួចផុតទុក្ខា។
គួរមានចិត្តត្រេកស្ដាប់គិតពិចារណ៍
ដល់ទីថ្ងៃថ្លានិព្វានប្រាកដ។
តូចធំក្មេងចាស់ស្ដាប់ឱ្យហ្មត់ចត់
ទោះកាយនឿយហត់កុំឆ្ងាយធម្មា។
កុំឱ្យតែចិត្តមានអវិជ្ជា
ធ្វើចិត្តឱ្យជាអាស្រ័យធម៌ព្រះ។
ចូរខំឃ្លាតខ្ចីអប់រំជម្រះ
ព្យាយាមយកឈ្នះកិលេសឱ្យបាន។
ចូរកុំកន្ដើយធ្វេសស្ដាប់គ្រប់ប្រាណ
អាចឱ្យរំខានក្នុងវដ្ដសង្សារ។



www.elibraryofcambodia.org

សង្ខារទាំងឡាយកើតហើយវិនាស    បើស្ដាប់ធម៌ព្រះទើបមានប្រាជ្ញា
បើសិនជាខ្ជិលល្ងង់លុះមរណា    បើសិនឧស្សាហ៍ជីវិតឧត្ដម។
ការស្ដាប់ព្រះធម៌លំបាកមែនពិត    លុះត្រារិះគិតប្រឹងប្រែងសន្សំ
ស្ដាប់ហើយស្ដាប់ទៀតកុំធ្វើបន្ទំ    តាំងខ្លួនឱ្យសមទទួលធម៌ថ្លៃ។
សម័យឥឡូវមានធម៌គ្រប់ទី    ចូរខំសំភីស្ដាប់ឱ្យរាល់ថ្ងៃ
កុំខ្ជិលច្រអូសជាហេតុចង្រៃ    គុណធម៌ក្បៀណក្ស័យព្រោះខ្ជិលពាលា។
ធម៌តាមវិទ្យុចូរខំស្ដាប់ទៅ    ឬអានសៀវភៅធម៌អាថ៌នានា
កុំពេលទំនេរនិយាយដើមគ្នា    សិក្សាធម្មាទើបចិត្តបានសុខ។
ពិតណាស់បើសិនចង់ឱ្យខ្លួនល្អ    ចូរកុំត្រដររធ្វើបាបសព្វមុខ
បើសិនចង់ឱ្យខ្លួនផុតចាកទុក្ខ    ចូរខំសម្រុកលះធម៌អបាយ។
បើសិនជាចង់ជួបនូវសុខពិត    ចូរខំរិះគិតស្ដាប់ធម៌រាល់កាយ
បើសិនជាចង់ឱ្យខ្លួនសប្បាយ    ចូរខំខ្វល់ខ្វាយសាងសុចរិតកម្ម។
ដោយសារអាយុឥឡូវមានខ្លី    ចូរប្រុងស្មារតីភាវនាប្រចាំ
ស្ដាប់ធម៌ទេសនាព្រះពុទ្ធទ្រង់ផ្ដាំ    យើងត្រូវចងចាំធម៌មិនប្រមាទ។
យប់ហើយនិងថ្ងៃពិតមិនយូរឡើយ    ខ្ញុំសូមលាហើយដោយចិត្តល្អស្អាត
ពេលបានស្ដាប់ហើយចូរខំសង្វាត    ធ្វើបុណ្យដាក់បាត្រស្ដាប់ធម៌ព្រះអើយ។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ២០. ស្រណោះទំនៀមជាតិខ្ញុំខ្លាំងណាស់

សម័យឥឡូវជឿនលឿនខ្លាំងណាស់ ក្មេងធំជាងចាស់ប្អូនធំជាងបង
វាយទាត់កាប់ចាក់អ្នកណាចម្លង ច្រៀងរាំឆ្លើយឆ្លងគ្មានខ្មាសមេបា។
បងតូចបងធំជួបគ្នាមិនបាន ចិត្តកាចសាមាន្យព្រោះជាតិសុភា
ពេលដែលស្រវឹងគ្មានខ្លាចនរណា ពេលដែលស្វាងស្រាថាមិនដឹងទេ។
ទៅលេងជិតឆ្ងាយគេជិះម៉ូតូ ជិះហើយស្រែកហោមិនគិតខ្មាសគេ
ទៅលេងសួនហើយហួសទៅទន្លេ ជិះម៉ូតូជ្រេជិតធ្លាក់ខុសថ្នល់។
មើលទៅគេធ្វើបូកដូចសេដ្ឋី មិត្តភក្តិប្រុសស្រីគ្មានអ្នកណាដល់
ម្ដាយឪរកលុយពួកនេះមិនខ្វល់ ចិត្តស្រាលជាងខ្យល់គំនិតពាលា។
ឪរកលុយបានឱ្យយកទៅរៀន ចិត្តខ្មៅដូចព្រានយកទៅលេងបៀ
បើមិនដូច្នោះស៊ីផឹកគ្នាវា គ្រួសារគ្រាំគ្រាព្រោះកូនអប្រិយ។
សម្លៀកបំពាក់ស្ដើរឃើញស្ដើរបាត់ ដូចខ្វះក្រណាត់ម៉ូដទាន់សម័យ
ខើចមុខខើចក្រោយព្រោះគេកែច្នៃ ស្ដើងឃើញសរសៃព្រមទាំងសាច់ខ្ចី។
ពីដើមគេស្លៀកបិទបាំងយ៉ាងជិត មិនបង្ហាញផ្ចិតព្រោះស្លៀកខើចខ្ចី
ធ្វើអ្វីតែងគិតខ្លាចញាតិគេស្ដី ខ្លួនឯងជាស្រីត្រូវស្ដាប់មេបា។
ក្មេងៗពីដើមធ្វើអ្វីស្ដាប់ចាស់ ក្មេងឥឡូវផ្លាសគ្មានស្ដាប់នរណា
ធ្វើតាមស្រែកឃ្លានឥតពិចារណា យល់ថាសង្ហាសប្បាយលីលា។



www.elibraryofcambodia.org

ឱ្យតែមានបុណ្យជួបជុំគីកកង ស្រីញីអូនបងដឹងធ្វើអីគ្នា
ដើរលេងដល់យប់ងប់ផឹកស្រាបៀរ គំនិតពាលាព្រោះខ្លួនមិនយល់។
បើសិនជារៀនគេចពីសាលា កុហកម៉ែថាគ្រូជាប់រវល់
ទៅលេងសួនស្នេហ៍ញ៉ាំនំគោជល់ កុំគិតអំពល់រៀនមិនអីទេ។
ម្យ៉ាងទៀតមានការបុណ្យទានម្តងៗ បងប្អូនមីងបងឃើញទៅមុនគេ
ដើរគ្មានចូលផ្ទះគ្មានគិតរិះរេ ឪពុកម្តាយជេរខឹងគាត់ខ្លាំងណាស់។
នេះហើយគេហៅសម័យលោតផ្លោះ បងប្អូនទាំងអស់ស្តាប់ឱ្យបានច្បាស់
វប្បធម៌បរទេសចូលមកច្រើនណាស់ បើសិនប្រែផ្លាស់ចូរគិតខ្មែរផង។
ពេលខ្លះនិយាយសុទ្ធតែអង់គ្លេស រៀនខ្មែរមិនចេះនិយាយខុសឆ្គង
និយាយឯងជើងន័យទៅឯត្បូង មិនត្រូវគន្លងពាក្យខ្មែរសោះឡើយ។
សម័យទំនើបដូចជឿនលឿនណាស់ អ្វីៗប្រែផ្លាស់ខុសពីមុនហើយ
ទាំងការពោលស្តីសរសេរតោះតើយ មិនបានគិតឡើយឱ្យតែអានបាន។
តាមពិតអក្សរលេខនព្វន្តខ្មែរ មិនចេះតែកែពិតមានមូលដ្ឋាន
បើសិនមិនច្បាស់កុំធ្វើស្មានៗ អស់ញាតិសន្តានស្រណោះខេមរា។
តាមពិតពោលនេះចង់ឱ្យភ្ញាក់ខ្លួន ចូរកុំគុំក្ងួនគិតចុះឃាយតា
បងប្អូនរួមជាតិជាទីស្នេហា សូមបានភ្ញីថ្លាក្នុងជីវិតអើយ។

*សូមអនុមោទនា !!!*

**ដោយសាចណោរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

# ២១.មិនគួរស្រវឹងខំប្រឹងសាងខ្លួន

សម្លេងចម្រៀងបំពេអ្នកស្តាប់ រៀបរាប់សាវស័ព្ទពីរឿងស្នេហា
អ្នកខ្លះស្តាប់ហើយសប្បាយចិន្តា ខ្លះក៏សោកាអួលណែនដើមក។
ផ្ទះថ្មហើយធំទ្រនុំអ្នកមាន ខ្ទមតូចកៀនៗលំនៅអ្នកក្រ
ជិះរថយន្តគេពឹងអ្នកបើកបរ រស់នៅបានល្អព្រោះបុណ្យឱ្យផល។
ពពករសាត់ស្ថិតលើវេហាស៍ សមុទ្រទឹកថ្លារលកព្រោះខ្យល់
បើសិនជាទាបត្រូវការកំណល់ ចិត្តដែលខ្វាយខ្វល់ព្រោះមានបញ្ហា។
អ្នកស្រឡាញ់រូបខិតខំតែងខ្លួន អ្នកឆ្លាតមាំមួនកសាងប្រាជ្ញា
អ្នកសាងទុច្ចរិតពិតជាសោកា អ្នកសាងធម៌អាចីជីវិតឧត្តម។
រស់នៅមានទ្រព្យមិនភ័យអត់ឃ្លាន អ្នកខ្វះធនធានប្រឹងប្រែងខិតខំ
រកស៊ីយប់ថ្ងៃគិតតែសន្សំ ជីវិតក្រៀមក្រំព្រោះខ្វះបុណ្យចាស់។
ព្រៃភ្នំល្អស្រស់លំនៅបក្សា ទឹកជ្រៅហើយថ្លាត្រីនៅមិនខ្វះ
បើសិននៅក្មេងកុំភ្លេចខ្លួនចាស់ ទោះរូបល្អល្អះមិនផុតជរា។
សង្ខារទាំងឡាយកើតហើយរលត់ មានតែមួយគត់គឺស្លាប់គ្រប់គ្នា
ទោះជាបណ្ឌិតមានក្រល្អជា តូចធំនានាពិតក្ស័យមរណា។
គិតទៅជីវិតប្រៀបដូចឆាកល្ខោន ប្រសើរអាប់ឱនលើកម្មអ្នកចារ
គ្មានព្រះកំណត់រឿងព្រេងវាសនា គ្មានពួកទេវតាណាជួយខ្លួនឡើយ។


www.elibraryofcambodia.org

វណ្ណៈមានក្រអាស្រ័យទ្រព្យធន ប្តីក្បត់ប្រពន្ធមានស្រីថ្មីហើយ
បើកើតជាមនុស្សកុំបីកន្តើយ ធ្វើបុណ្យឱ្យហើយកុំចាំខ្លួនចាស់។
បើសិនរស់នៅស្រវឹងនឹងទ្រព្យ ធ្វើទានមិនជាប់ចាយវាយផ្តេសផ្តាស
បើសិនស្នេហាដីស្រែប្រាក់កាស ចុងក្រោយពិតណាស់គ្មានទីពឹងទេ។
ម្យ៉ាងទៀតរស់នៅគប់រកស្រីស្រា អាភៀនកញ្ឆាល្បែងគ្រប់កាំភ្លេ
ក្បត់ប្រពន្ធខ្លួនស្នេហ៍ប្រពន្ធគេ ធ្លាក់ទៅនិរយេរងទុក្ខមិនខាន។
តាមពិតមនុស្សយើងត្រូវចេះថ្លែងថ្លឹង ត្រិះរិះឱ្យដឹងហើយប្រឹងគ្រប់ប្រាណ
កុំឱ្យតណ្ហាដឹងនាំរុញច្រាន គ្រោះកាចសាមាន្យនាំទៅអវិចី។
មនុស្សលោកឥឡូវសប្បាយនឹងល្បែង មិនខំប្រឹងប្រែងសាងបុណ្យបារមី
ស្រវឹងនឹងខ្លួនគិតថាមិនអី ចុងក្រោយវឹងវៃព្រោះទោសប្រមាទ។
ជាចុងក្រោយនេះសូមអភ័យទោស ក្រែងមានលើសលោះឬមួយខ្វះខាត
ស្តាប់ឬអានហើយតាំងចិត្តឱ្យស្អាត បុណ្យល្អសុទ្ធសាធខ្ញុំជូនអ្នកហោង។

*សូមអនុមោទនា !!!*

ដោយសាមណេរ សា ចាន់រ៉ាត់

ន ហិ បុត្តោ បតិ ទាបិ បិយោ ទុក្ខា បមោចយេ
យថា សទ្ធម្មស្សវនំ ទុក្ខា មោចេតិ បាណិនំ ។

កូនក្តី ប្តីក្តី ដែលជាទីស្រឡាញ់ មិនមែនរំដោះខ្លួនឱ្យរួចចាកទុក្ខបានទេ មានតែការស្តាប់នូវព្រះធម៌ ទើបរំដោះសត្វទាំងឡាយឱ្យរួចចាកទុក្ខបាន។



www.elibraryofcambodia.org

## ២២.ចូរកុំអាងលើ...

ធំអាងកម្លាំង ប្រគួតតតាំង គ្មានខ្លាចនរណា
អ្នកតូចគ្នាខ្លាច មិនហ៊ានតវ៉ា សូមតែសុខា
មិនតបវិញឡើយ។

ជីវិតកើតមក តាំងនៅក្នុងលោក ទុក្ខឥតស្រាកស្បើយ
មិនគួរធ្វើបាប អួតអាងសោះឡើយ ចិត្តគិតកន្តើយ
ពីបុណ្យកុសល។

រស់នៅកុំអាង ញាតិមិត្តជិតខាង ចូរគិតឱ្យដល់
គួរធ្វើទានសីល សាងស្ពានមគ្គផល កុំសាងកង្វល់
នាំពៀរវេរា។

កុំអាងទ្រព្យធន អាងប្តីប្រពន្ធ អាងជននានា
កុំអាងលាភយស គួរសង្គ្រោះគ្នា មិនគួរនិន្ទា
លើកទោសស្រដី។

អ្នកខ្លះកើតមក នាំចង្អៀតលោក សាងទោសអប្រិយ
គុណមានសន្ធឹក មិនចេះលកលៃ ពោលតែទោសពៃរ៍
អ្នកផ្សេងស្មុះសាយ។


www.elibraryofcambodia.org

ខ្លះអាងខ្លួនធំ មើលងាយចាស់ទុំ ពោលស្តីឡៃបខាយ
មិនឱ្យតម្លៃ ជូនញាតិទាំងឡាយ សាងផ្លូវអបាយ
ដោយអាងបុណ្យសក្តិ។

អ្នកអើយរស់នៅ កុំសាងអាស្រូវ អាងលើមាសប្រាក់
ពោលពាក្យញុះញង់ ជាហេតុបែកបាក់ ពោលពាក្យសច្ចៈ
ឈ្មោះថាមិនស្លាប់។

បើសិនចង់ល្អ ត្រូវសាងធម៌ស រស់គោរពច្បាប់
កុំអាងផ្តេសផ្តាស នាំឱ្យយ៉ាកយ៉ាប់ រស់នៅដូចស្លាប់
ព្រោះអាងផ្លូវខុស។

*សូមអនុមោទនា !!!*

ដោយសាមណេរ សា ចាន់រ៉ាត់

ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ
ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។

បុគ្គលអ្នកឈ្នះ តែងរងនូវពៀរ បុគ្គលអ្នកចាញ់តែងដេកជាទុក្ខ ចំណែកបុគ្គលលះបង់ការឈ្នះ និងការចាញ់ចេញហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ។


www.elibraryofcambodia.org

## ២៣-វេលត្លែចស្លាប់ប្រញាប់ត្លែចខ្លួន

---

វ័យកាន់តែជ្រុលជិតដល់កំណត់ រៀបរាប់អត្ថបទជូនញាតិប្រុសស្រី
ស្តាប់ឬអានហើយក្រែងសៀយទុក្ខភ័យ ខិតខំលកលៃទាន់ខ្លួនមិនស្លាប់។
តាមពិតជីវិតទាំងអស់ក្នុងលោក ដែលបានកើតមកផ្លាស់ប្តូរយ៉ាងឆាប់
កើតហើយតែងព្រាត់នេះគឺជាច្បាប់ ទោះយូរឬឆាប់ត្រូវក្ស័យមិនខាន។
ភារៈជាមនុស្សកើតឡើងកាលណា ត្រូវតែធ្វើការចិញ្ចឹមខ្លួនប្រាណ
កុំថាឡើយមនុស្សទោះសត្វតិរច្ឆាន មិនដែលសោះខានពីរឿងនេះទេ។
ឈប់ស្នេះប៉ុណ្ណេះមិនពោលវែងឆ្ងាយ នឹងអធិប្បាយពីរឿងយើងគេ
គឺរឿងរវល់គ្មានពេលទំនេរ ចូរគិតរិះរេអស់ញាតិសន្តាន។
និយាយអំពីជនជំពូកខ្លះ រវល់ខ្លាំងណាស់ទៅវត្តមិនបាន
បើរក្សាសីលថាកូនរំខាន កូនធំច្រើនម៉ានទើបមិនហ្មងសៅ។
អ្នកខ្លះថាយី!កូនខ្ញុំនៅតូច អ្នកខ្លះថាខូចតែខ្ញុំមានចៅ
បើសិនទំនេរមិនបាច់គេហៅ ខ្លះថាខ្ញុំខ្លៅមិនចេះអក្សរ។
មានយាយម្នាក់នោះរវល់ឥតល្ហែ ធ្វើចម្ការស្រែគ្មានស្រូវអង្ករ
ពេលធ្វើបុណ្យទានមិនចេះត្រេកអរ កំណាញ់ដល់កអ្នកណាក៏ដឹង។
ចំណែកតាម្នាក់មានឧធំដំបង ធ្វើបុណ្យម្តងៗភ្នែកគាត់សំឡឹង
ក្រែងលោអស់ទ្រព្យដែលគាត់ខំប្រឹង ថាធ្វើម្តីងៗពិតក្រហើយខ្ញុំ។


www.elibraryofcambodia.org

មានមីងម្នាក់ទៀតខំឆ្លៀតពោលថា ខ្ញុំមិនចាញ់តាកាលនៅក្រមុំ
ទាស់តែឥឡូវកូនមិនទាន់ធំ ចាំមើលបុណ្យភ្ជុំលេងឱ្យអស់ដៃ។
នេះហើយរវល់ភ្លេចគិតដល់ស្លាប់ អ្នកខ្លះប្រញាប់ភ្លេចខ្លួនរាល់ថ្ងៃ
មិនសាងបុណ្យទុកដេកនឹកស្រមៃ ពឹងលើបុត្រថ្លៃឱ្យជួយអាត្មា។
បុណ្យគឺជាទ្រព្យគាប់ចិត្តស្រីប្រុស ចូរគិតមើលចុះអស់ញាតិកា
ហេតុមកពីល្ងង់មិនបានសិក្សា ស្តាប់ធម៌ទេសនាព្រះពុទ្ធទ្រង់ញាណ។
អ្នកខ្លះរស់នៅមិនរក្សាសីល ហើយថែមទាំងខ្ជិលធ្វើបុណ្យដាក់ទាន
កំណាញ់ទ្រព្យធនតាំងខ្លួនអ្នកមាន នេះហៅសាងស្ពានពូជក្រទុកហើយ។
តាមពិតនរណាក៏រវល់ដែរ រៀងរាល់ថ្ងៃខែគ្មានពេលសោះឡើយ
មានតែឆ្លៀតខ្លះទើបយើងបានស្បើយ ពេលស្លាប់ទៅហើយបានបុណ្យជាគ្នា។
តាមពិតស្រីប្រុសអ្នកទាំងឡាយអើយ ខ្ញុំប្រាប់ឱ្យហើយគ្មានពាក្យនិន្ទា
គឺប្រាប់ដោយត្រង់សូមកុំមានពៀរ ចង់ឱ្យល្អជាទើបពោលស្រដី។
ជាទីបញ្ចប់ជូនបុណ្យឱ្យហើយ សូមលោកបានស្បើយពីបាបអប្រិយ
បើមានកំណើតសូមសុខប្រពៃ ខ្ញុំសូមលើកដៃជំរាបលាហើយ។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

# ២៤-សិរីសួស្តីស្ថិតនៅឯណា ?

បឋមវន្ទាសូមនមស្ការ គុណត្រ័យរតនាប្រសើរបី
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃប្រពៃ ដែលមានគុណថ្លៃត្រារាប់ពុំបាន។
បង្គំផ្តោះត្រង់អង្គព្រះសម្ពុទ្ធ ប្រាជ្ញាមុះមុតដឹងសព្វទីស្ថាន
ត្រាស់ដឹងក្នុងលោកពិតសុខក្សេមក្សាន្ត អាស្រ័យព្រះញាណទើបរួចវិបត្តិ។
ព្រះធម៌ឧត្តមយានល្អកន្លង ដឹកនាំសត្វឆ្លងហើយអាចកម្ចាត់
មន្ទិលសង្ស័យបរមត្ថបញ្ញត្តិ ឱ្យពួកមនុស្សសត្វបានឃើញសច្ចៈ។
បង្គំព្រះសង្ឃគួរឱ្យជ្រះថ្លា បួសហើយកាលណាប្រព្រឹត្តឥតអាក់
ជាស្រែបុណ្យល្អទាយកទុកដាក់ ធ្វើទានគ្រប់ថ្នាក់បន្តសាសនា។
បង្គំរួចហើយខ្ញុំសូមលើកយក ព្រះសូត្រមួយមកទុកពិចារណា
សិក្សារួចហើយកើតក្តីអស្ចារ្យ ព្រះពុទ្ធត្រាស់ថាជាមង្គលសូត្រ។
នៅសម័យមួយក្នុងជម្ពូទ្វីប មនុស្សគ្រប់ជន្មជីពរស់នៅស្ងួតបួត
កើតក្តីសង្ស័យនៅឆ្ងល់រហូត អំពីព្រះសូត្រព្រោះតែមិនយល់។
ពេលប្រជុំគ្នាក៏បានសាកសួរ ថាអ្វីដែលគួរហៅថាមង្គល
រូបឬសម្លេងអារម្មណ៍វិលវល់ បើនរណាយល់សូមប្រាប់ផងណា៎។
កាលនោះទិដ្ឋមង្គិកៈ ជាបុរសម្នាក់បានពោលឡើងថា
គឺរូបហ្នឹងហើយឃើញគ្រប់នេត្រា ចាំរកឯណាយើងឃើញយ៉ាងច្បាស់។



www.elibraryofcambodia.org

ពេលព្រឹកព្រលឹមបុគ្គលឃើញហើយ សត្វស្លាបគៀកកើយហើរក្នុងអាកាស
ព្នៅខ្ចីកូនក្មេងរត់លេងផ្តេសផ្តាស ត្រីផ្អិនល្អលួះគោសេះគ្រប់ថ្នាក់។
ធម្មតាមើលឃើញស្រីមានផ្ទៃពោះ មេគោខ្ពស់ៗនេះគឺទស្សនៈ
ម្យ៉ាងគេសន្មតថាល្អឥតអាក់ សូមជនគ្រប់ថ្នាក់ជឿខ្ញុំចុះណា។
បុរសម្នាក់ទៀតខំផ្ទៀតស្តាប់ជាក់ ឮហើយគាត់ភ្ញាក់បដិសេធថា
អ្នកដ៏ចម្រើនពោលខុសសច្ចា ភ្នែកឃើញរូបាមិនល្អទាំងអស់។
គាប់ជួនពេលខ្លះល្អឥតមានខ្ចោះ សម្លេងប៉ុណ្ណោះទើបល្អឥតទាស់
ឥឡូវស្តាប់ខ្ញុំរៀបរាប់សេចក្តី ចូរប្រុងស្មារតីគិតតាមប្រាថ្នា។
តាមពិតសម្លេងដែលឮនោះហើយ ចូរកុំភ្លេចឡើយលោកយាយលោកតា
ព្រោះក្នុងលោកនេះឮហើយកាលណា ទើបដឹងសាច់ការណ៍ជួបសុខសួស្តី។
ឫក្សល្អយាមល្អកម្រក្នុងលោក គឺមនុស្សបានមកពីការពោលស្តី
ឮថាចម្រើនគ្មានឡើយគ្រោះភ័យ ទើបខ្ញុំលកលៃពោលថាមង្គល។
ពេលនោះមុតមង្គលិកៈ ស្តាប់ហើយស្ទើរស្ទាក់ថាពិតពុំយល់
គាត់ថាស្តាប់ហើយខ្ញុំរឹតអំពល់ ព្រោះអ្នកពន្យល់ថាឮប្រពៃ។
បើសិនសម្លេងដែលបានឮនោះ ស្តាប់ហើយចាក់ធ្លុះយល់អត្ថសេចក្តី
ខ្លះក៏ពីរោះខ្លះក៏គ្មានន័យ ថាជាសិរីដូចមិនសមសោះ។
អារម្មណ៍មួយៗបុគ្គលបានដឹង ចូរស្តាប់ពាក្យហ្នឹងប្រឹងឱ្យបានអស់
តាមពិតក្លិនរសនោះទើបឥតខ្ចោះ ហិតទំពារអស់ទើបដឹងរសឆ្ងាញ់។
ក្លិនផ្កាបទុមចេញពីប្រឹថពី ភមរមូលមីនែបនិត្យស្រឡាញ់


www.elibraryofcambodia.org

នាំគ្នាក្រេបក្លិនយកឈ្នះយកចាញ់ ដេញជើងត្រចាញ់ព្រោះឃើញសម្រស់។
ឯផៅវ្ជព្វៈម្នាក់ៗចង់ពាល់ ចាប់កាន់ឱ្យស្គាល់រសជាតិទាំងអស់
គឺខ្ញុំពោលនេះដោយចិត្តស្ម័គ្រស្មោះ លោកអ្នកទាំងអស់នេះហើយល្អជា។
បុរសទាំងបីមិនយល់ព្រមសោះ អ្នកស្តាប់ទាំងអស់ជឿប្លែកពីគ្នា
ខ្លះប្រកាន់ថាឃើញរូបនានា ជឿស៊ប់តាមគ្នាទាំងខ្លួនមិនយល់។
ឯជនពួកខ្លះគំនិតរឹងត្អឹង ថាសម្លេងហ្នឹងទើបជាមង្គល
ខ្លះថាអារម្មណ៍ដែលខ្លួនបានយល់ រឿងនោះអំពល់ពេញទ្វីបហើយណា។
នៅគ្រានោះឯងពួកមនុស្សទាំងឡាយ នាំគ្នាខ្វល់ខ្វាយព្រមទាំងទេវតា
ខំសាកសួរគ្នាក្រែងបានដឹងការណ៍ ដំណឹងនោះណារឹតតែរាលដាល។
មិនតែប៉ុណ្ណោះទោះមនុស្សទេវតា ចេះតែសង្កាអស់ម៉ឺនចក្រវាឡ
ចិត្តមិនបានស្ងប់សង្ស័យបណ្តាល ពេលនោះដល់កាលត្រូវដឹងការពិត។
កាលនោះទេវតាជាន់សុទ្ធាវាស ចិត្តលោកថ្លាជ្រះយល់ពីទឹកចិត្ត
របស់មនុស្សលោកមានទុក្ខវិបរិត ដប់ពីរឆ្នាំពិតព្រះពុទ្ធសម្តែង។
ពេលកន្លងមកដប់ពីរឆ្នាំហើយ លោកមិនភ្លេចឡើយនាំគ្នាប្រឹងប្រែង
នៅជាន់តាវតឹង្សជុំអស់គម្តែង ជួបជុំគ្នាឯងចូលគាល់សក្កៈ។
ពេលនោះទេវរាជទ្រង់ត្រាស់សួរថា អស់លោកទេវតាច្រើនជាអន័ត្ស
ដឹងរឿងរ៉ាវហើយយកចិត្តទុកដាក់ ទេវតាគ្រប់ថ្នាក់សួរព្រះរូសរាន់។
នាគ្រានោះឯងគណៈទេវបុត្រ នាំគ្នាចុះផុតដល់វត្តជេតពន
ទេវតាមួយអង្គឱនកាយបន្ទន់ ទឹកចិត្តលោកធ្ងន់សាកសួរបញ្ហា។



www.elibraryofcambodia.org

នាពេលអគ្រាត្រព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់ព្រះធម៌ទេសនា
ព្រះសូត្រសាមសិបប្រាំបីប្រការ ពីរោះពិស្តារមានដូចតទៅ។
មួយគឺមិនសេពគប់ពាលទាំងឡាយ នាំឱ្យខ្វល់ខ្វាយជួបរឿងអាស្រូវ
ពីរគប់បណ្ឌិតលោកតែងនាំទៅ ក្តីសុខនោះកូវមានរាល់វេលា។
ចំណែកទីបីត្រូវដឹងកុំខាន ញាតិគ្រប់សន្តានត្រូវតែបូជា
មាតាបិតាសមណៈនានា ហេតុនោះហើយជាមង្គលឧត្តម។
រីឯទីបួនជួនទីកន្លែង ប្រទេសនោះឯងរស់នៅបានសម
ទីប្រាំខ្លួនបានធ្វើបុណ្យសន្សំ ប្រាំមួយខិតខំតម្កល់ខ្លួនល្អ។
ប្រាំពីរបានស្តាប់បានរៀនច្រើនមួយ អស់លោកមិនព្រួយពិតជាត្រេកអរ
ប្រាំបីសិប្បៈហត្ថកម្មកម្រ ចេះកែលំអរហើយច្នៃប្រឌិត។
ប្រាំបួនវិន័យដែលអ្នកសិក្សា ខំពិចារណាទៅតាមការពិត
ដប់ពាក្យអ្នកពោលជាសុភាសិត ល្អិតល្អក្នុងចិត្តពិតជាសុខា។
ដប់មួយល្អជាក់អ្នកស្តាប់ឱ្យច្បាស់ កុំប្រែក្រឡាស់បម្រើមាតា
លោកអ្នកមានគុណកុំភ្លេចឡើយណា ព្រះនោះហើយណាជាព្រះកន្លោង។
ដប់ពីរបម្រើបិតាក្នុងផ្ទះ ហើយក្រាបសំពះគុណល្អឥតហ្មង
បប្អូលញាតិមិត្តមីងមាប្អូនបង កុំឱ្យសៅហ្មងស្លាប់ទើបម្នីម្នា។
ដប់បីត្រូវតែប្រយ័ត្នបំផុត សង្គ្រោះដល់បុត្រព្រមទាំងភរិយា
ដប់បួនបន្តប្រកបការងារ មិនលាយឡំគ្នាច្របូកច្របល់។


www.elibraryofcambodia.org

ដប់ប្រាំធ្វើទានទោះតិចម្តេចម្តា កុំខានឡើយណាធ្វើទុកជាថ្នល់
ពេលដែលស្លាប់ទៅមិនមានខ្វាយខ្វល់ នឹកស្តាយទ្រព្យសល់ពិតជាវិណ្ណក។
ដប់ប្រាំមួយការប្រព្រឹត្តធម៌ពិត រស់សាងសុចរិតស្រឡាញ់ធម៌ស
ឮថាពាក្យបាបមិនដែលត្រេអរ ហើយប្រព្រឹត្តល្អជៀសបាបឱ្យឆ្ងាយ។
ដប់ប្រាំពីរអ្នកត្រូវធ្វើកុំលោះ គឺជួយសង្គ្រោះដល់ញាតិទាំងឡាយ
ឱ្យលោកបានសុខផ្លូវចិត្តរាងកាយ ជួបសុខសប្បាយទាំងស្រីទាំងប្រុស។
ដប់ប្រាំបីទាក់ទងរាល់អាត្មា ត្រូវធ្វើកិច្ចការណាដែលមិនខុស
នឹងច្បាប់ហាមប្រាមត្រូវមានសន្តោស ការងារដូច្នោះជាសុខសួស្តី។
ដប់ប្រាំបួនវៀរពីការធ្វើបាប ខិតខំបន្សាបអធម៌ឱ្យខ្ចី
ម្ភៃវៀរចាកពីសុរាមេរ័យ អ្នកប្រុងស្មារតីកាន់យកឱ្យបាន។
ម្ភៃមួយរស់នៅកុំបីប្រមាទ ក្នុងធម៌ស្អាងស្អាតសោះតែនឹងខាន
ម្ភៃពីររស់នៅគោរពសន្តាន ដោយការរាប់អានញាតិមិត្តស្រីប្រុស។
ម្ភៃបីរស់នៅបន្ទាបខ្លួនល្អ ម្ភៃបួនមានក្រឱ្យចេះសន្តោស
ម្ភៃប្រាំភាវៈអ្នកដឹងត្រូវខុស មិនសាងកំហុសលើជនប្រុសស្រី។
ម្ភៃប្រាំមួយខិតខំស្តាប់ធម៌តាមកាល មិនឱ្យបណ្តាលបាត់បង់ស្មារតី
ម្ភៃប្រាំពីរអត់ធន់អ្នកត្រូវខាត់ដុស យកខន្តីកោសពួជក្រោធឱ្យឆ្ងាយ។
ម្ភៃប្រាំបីត្រូវតែដាក់មានះ អ្នកជួបប្រទះមិនសួរខ្វល់ខ្វាយ
គេប្រដៅងាយទាំងចិត្តទាំងកាយ អ្នកប្រាជ្ញទាំងឡាយមានរាល់វេលា។
ម្ភៃប្រាំបួនការបានជួបប្រទះ សមណៈប្រឹងលះកម្ចាត់វេរា


www.elibraryofcambodia.org

សាមសិបគាប់ជួនបានសន្ទនា ទូវកងធម្មាទៅមកតាមកាល។
សាមសិបមួយគឺផុតបាបឱ្យអស់ ធម៌ខ្មៅឱ្យខ្សោះកុំឱ្យរាលដាល
ម្យ៉ាងមិនពេញចិត្តឬត្រេកត្រអាល អធម៌បណ្ដាលអាចមានទុក្ខព្រួយ។
សាមសិបពីរប្រព្រឹត្តធម៌ប្រសើរ រស់នៅគ្រាន់បើបានជាជំនួយ
អប់រំកាយចិត្តឱ្យនឹងតែមួយ កុំឱ្យរលួយដោយអកុសល។
សាមសិបបីឃើញអរិយសច្ច ដើម្បីកាត់ផ្ដាច់វដ្តៈនាំខ្វល់
បានដល់ធម៌ពិតកម្ចាត់ចម្ងល់ ជាអកុសលកុំឱ្យកើតមាន។
សាមសិបបួនបានធ្វើឱ្យជាក់ច្បាស់ នូវធម៌ល្អល្អះគឺព្រះនិព្វាន
ដែលជាមាគ៌ានៃព្រះទ្រង់ញាណ ព្រះអង្គទូន្មានជាគោលព្រះធម៌។
សាមសិបប្រាំចិត្តបុគ្គលណា ដែលលោកជ្រះថ្លាហើយមិនញាប់ញ័រ
សរសើរលាភយសសុខប្រៀបដូចជ័រ ឈ្មោះថាលោកធម៌មិនជាប់ជំពាក់។
សាមសិបប្រាំមួយអ្នកមិនសោយសោក ម្យ៉ាងមិនចាញ់បោកធម៌ជាអន្ទាក់
សាមសិបប្រាំពីរអ្នកគ្មានរាគៈ ជាអរិយៈផុតទុក្ខអស់ហើយ។
សាមសិបប្រាំបីចិត្តអ្នកក្សេមក្សាន្ត លោកមិនរំខានដល់អ្នកផ្សេងឡើយ
លោកបានឆ្លងផុតឬបានដល់ត្រើយ ធម៌ទាំងនេះហើយជាសុខសួស្ដី។
ពេលដែលបានស្ដាប់ធម៌ព្រះសម្ដែង ភ្លឺច្បាស់ចិព្ចែងដោយពាក្យបាលី
ពន្យល់ប្រាប់ដល់មនុស្សសត្វប្រុសស្រី អំពីអត្ថន័យមង្គលពិតហោង។

*សូមអនុមោទនា !!!*

ដោយសាមណេរ សា ចាន់រ៉ាត់



www.elibraryofcambodia.org

## ២៥_ស្នេហ៍កប់ព្រលឹង

| | |
|---|---|
| កំណើតជាមនុស្ស | ច្រើនដោយសម្បត្តិ |
| មិនដូចជាសត្វ | រស់ខ្វះអាហារ។ |
| ស្រុកស្រែស្ងប់ស្ងាត់ | មិនដូចនៅផ្សារ |
| អ្នកមានហ៊ឺហា | អ្នកក្រភ័យព្រួយ។ |
| អ្នកជួបក្ដីទុក្ខ | ត្រូវការអ្នកជួយ |
| អ្នកត្រូវការភ្ជួយ | ព្រោះតែរងា។ |
| បើរស់ម្នាក់ឯង | ចំបែងអត់គ្នា |
| បើមានពុកវា | មានម៉ែវាផង។ |
| រឿងរ៉ាវជីវិត | ស្នេហាអូនបង |
| វេញជាចំណង | ចងរឹតយ៉ាងតឹង។ |
| នេះគឺរឿងពិត | ប្រុសស្រីត្រូវដឹង |
| ស្នេហ៍កប់ព្រលឹង | នៃជនប្រុសស្រី។ |
| មានស្នេហ៍មានទុក្ខ | ទោះតូចធំក្ដី |
| ចូរប្រុងស្មារតី | គិតពិចារណា។ |
| ខន្ធប្រាំមានទុក្ខ | ថែមរែកស្នេហា |
| នាំខ្វល់ចិន្ដា | ជីវិតព្រួយភ័យ។ |



www.elibraryofcambodia.org

មានកូនមានចៅ ខន្តបូនជប់ម្តេ
ពេលនេះរីងរៃ ព្រោះលង់អាត្មា។
គិតថាមានស្នេហ៍ ជីវិតភ្លឺថ្លា
ដឹងអីសោកា ទុក្ខអញ្ជឹងសោះ។
ស្នេហ៍គ្រាដំបូង សន្យាថាស្មោះ
ចុងក្រោយក្រៀមក្រោះ ចប់គ្មានខ្លឹមសារ។
ដូច្នេះរស់នៅ ត្រូវខំសិក្សា
កុំឱ្យតណ្ហា ដឹកនាំជីវិត។
ស្នេហា១ អំពល់មែនពិត
ចាំចុះញាតិមិត្ត ស្នេហ៍នាំខកប្រាណ។
បើស្នេហ៍តាមធម៌ ជីវិតសុខសាន្ត
ស្នេហ៍គេមិនបាន កុំភ្លេចខ្លួនឯង។
តាមពិតស្រឡាញ់ ព្រះពុទ្ធសម្តែង
គ្មានស្មើខ្លួនឯង តែម្នាក់ឡើយណា។
ដូច្នេះមានស្នេហ៍ ត្រូវមានប្រាជ្ញា
ជីវិតភ្លឺថ្លា ដោយសារគំនិត។

*សូមអនុមោទនា !!!*

ហោយសាចណោរ សា ចាន់រ៉ាត់



www.elibraryofcambodia.org

# ២៦.មានជីវិតហើយគួរតែសិក្សា

ជំនួញជួញដូរធ្វើនៅទីផ្សារ ស្វែងរកប្រាជ្ញានៅសាលារៀន
អ្នកក្រភ័យព្រួយតែរឿងអត់ឃ្លាន រីឯអ្នកមានខ្វល់រឿងរកស៊ី។
សមុទ្រទាំងឡាយរលកព្រោះខ្យល់ ផ្លូវចិត្តកង្វល់ព្រោះទុក្ខញាំញី
រៀនអ្វីមិនចេះព្រោះមិនសំភី បានមួយខ្វះពីព្រោះលោភដឹកមុខ។
គ្រប់មនុស្សប្រុសស្រីដែលកើតក្នុងលោក តែងតែនាំមករឿងរ៉ាវក្តីទុក្ខ
ឧបសគ្គតូចធំដ៏សែនស្មាញស្មុគ រស់ដូចជាប់គុកនរកលោកិយ។
ម្យ៉ាងទៀតជីវិតប្រៀបដូចនាវា ជួបហើយព្រាត់គ្នាទុក្ខសោករីងរៃ
បើគ្មានប្រាជ្ញាពិតជាក្សិណក្ស័យ បញ្ហារាល់ថ្ងៃដោះពុំរួចដែរ។
ជីវិតប្រុសស្រីដែលបានកើតមក ដោយព្រះមានដោគពុកហើយនឹងម៉ែ
បើមិនដឹងគុណលោកទុក្ខឥតមានល្ហែ ទុក្ខរាល់ថ្ងៃខែព្រោះកូនឫស្យា។
ជីវិតនៅល្ងង់ច្រើនលង់ក្នុងខ្លួន ចិត្តមិនមាំមួនព្រោះខ្វះប្រាជ្ញា
ដឹងថាខ្លួនល្ងង់ត្រូវខំសិក្សា រៀនលេខអក្ខរាធម៌អាថ៌បាលី។
កុំអាងទ្រព្យធនលាភយសមុខមាត់ ពិតមិនទៀងទាត់ចាំចុះប្រុសស្រី
រៀនស្តាប់ធម៌ព្រះកុំខ្ជិលធ្វើហី ឆ្អៀតចុះគ្មានអីរស់ប្រាក់ឯណា។
ធម៌តាមវិទ្យុព្រះសង្ឃសម្តែង ប្រឹងស្តាប់ខ្លួនឯងស្វែងរកប្រាជ្ញា
តាមសច្ចៈធម៌ដែលព្រះទេសនា គ្រាន់ជួយអាត្មាស្វែងរកផ្លូវត្រូវ។
ម្យ៉ាងកុំអាងលើរូបរាងកាយ ដៃជើងទាំងឡាយធ្វេញបាក់សក់ស្កូវ



www.elibraryofcambodia.org

ភ្នែកប្រែងងឹតដើរមិនត្រូវផ្លូវ រៀនគិតមើលទៅក្រែងខ្ញុំពោលខុស។
ដោយសារពេលនេះវេលានៅខ្លី ខ្ញុំលាប្រុសស្រីអស់លោកសប្បុរស
បណ្តាំចុងក្រោយកុំភ្លេចឱ្យសោះ រៀនធម៌ដោយស្មោះចម្រើនប្រាជ្ញា។
ចូររក្សាសីលធ្វើបុណ្យដាក់ទាន កុំឱ្យអត់ឃ្លានគ្រប់ជាតិណា១
សូមជួបត្រ័យរតន៍កុំឃ្លាតឡើយណា សូមជួបសុខាលុះនិព្វានហោង។

*សូមអនុមោទនា!*

ហោយសាមណោរ សា ចាន់រ៉ាត់

**ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ**
**អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរា ។**

ពួកសប្បុរសរមែងប្រាកដក្នុងទីឆ្ងាយដូចភ្នំហិមពាន្តដូច្នោះពួកអសប្បុរស (ទុកជាឋិតនៅ) ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់ ។ (បកិណ្ណកវគ្គទី២១ បិឋកលេខ៥២)

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**
**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។**

អ្នកទាំងឡាយណានឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ។ ( ចិត្តវគ្គទី៣ បិឋកលេខ៥២)



www.elibraryofcambodia.org

# ២៧. បើសិនមានទ្រព្យកុំភ្លេចឱ្យទាន

សារធាតុជាភ្លើងឆេះមិនរើសមុខ ឈើខ្ចីមឈើពុកឆេះគ្មានប្រណី
ដាក់ច្រើនឆេះវែងដាក់តិចឆេះខ្លី ឆេះទាំងទឹកដីរូបធាតុទាំងឡាយ។
មានភ្លើងមួយនោះសាហាវខ្លាំងណាស់ ដុតទាំងក្មេងចាស់រៀងរាល់រូបកាយ
ដុតឱ្យគ្រាំគ្រាវិនាសអន្តរាយ គួរខ្ពើមជិនណាយគួរឱ្យតក់ស្លុត។
បើសិនមានភ្លើងឆាបឆេះក្នុងផ្ទះ ម្ចាស់តែងរួតរះយកទ្រព្យឱ្យផុត
មិនឱ្យឆេះបានក្លាហានបំផុត មិនឱ្យភ្លើងដុតទ្រព្យធនខ្ទេចខ្ទី។
ទ្រព្យណាដែលយកចេញពីផ្ទះហើយ ពិតមិនឆេះឡើយតែងបានប្រយោជន៍
មានដល់ម្ចាស់ផ្ទះតិចច្រើនដោយហោច មិនបង់ប្រយោជន៍តែងបានចំណេញ។
យ៉ាងណាសត្វលោកមានផ្ទះគឺកាយ ចូរគិតខ្វល់ខ្វាយជញ្ជូនទ្រព្យចេញ
ដោយការឱ្យទានធ្វើបុណ្យបំពេញ លះកំណាញ់ចេញឱ្យដោយជ្រះថ្លា។
ម្យ៉ាងបើមានទ្រព្យជាឱ្យទាន ឱ្យតាមធនធានព្រមដោយប្រាជ្ញា
ដោយមិនស្តាយក្រោយទើបបានផលា ឱ្យមិនពិចារណ៍ពិតមិនបានផល។
មែនហើយធ្វើបុណ្យសាងគុណដាក់ទាន យើងគួរតែរៀនគិតឱ្យបានដល់
កុំឱ្យធ្វើហើយចិត្តរឹតខ្វាយខ្វល់ ព្រោះចិត្តកង្វល់មិនបានសិក្សា។
ដូច្នេះបើសិនជាបានធ្វើទាន តាមព្រះទូន្មានទើបបានផលា
កុំតាមចិត្តឯងក្រែងខូចឥតការ ត្រូវស្តាប់ទេសនាពន្យល់អត្ថន័យ។


www.elibraryofcambodia.org

បើយើងនៅល្ងង់កុំលង់ខ្ជិលរៀន បើសិនយើងមានត្រូវឱ្យអភ័យ
ដល់ជនច្រើនគ្នាត្រូវចេះលកលៃ ទ្រព្យធនតិចក្តីឱ្យកុំបីខាន។
ដោយសារសង្ខារជួបហើយក៏ព្រាត់ ពិតមិនទៀងទាត់គ្រប់ៗសន្តាន
ត្រូវសាងកុសលធ្វើគុណឱ្យបាន ជីវិតថ្កើងថ្កានដោយបុណ្យអ្នកសាង។

*សូមអនុមោទនា !!!*

ដោយសាមណេរ សា ចាន់រ៉ាត់

អាទិត្តស្មឹ អគារស្មឹ យំ នីហរតិ ភាជនំ
តំ តស្ស ហោតិ អត្ថាយ នោ ច យំ តត្ថ ឌយ្ហតិ
ឯវមាទិត្តកោ លោកោ ជរាយ មរណេន ច
នីហរេថេវ ទានេន ទិន្នំ ហោតិ សុនីហតំ ៗ

កាលបើផ្ទះត្រូវភ្លើងឆេះ ជនជាម្ចាស់ផ្ទះតែងជញ្ជូនភាជន៍ណាចេញផុត (អំពីផ្ទះ) ឬទ្រព្យណាក្នុងផ្ទះនោះ (ដែលគេជញ្ជូនចេញហើយ) ភ្លើងឆេះមិនបាន ទ្រព្យនោះ រមែងបានជាប្រយោជន៍របស់គេ យ៉ាងណាសត្វលោកដែលត្រូវភ្លើង គឺជរា និងមរណៈឆាបឆេះ គួរប្រញាប់ជញ្ជូនទ្រព្យចេញឱ្យផុត (អំពីផ្ទះគឺរាងកាយ) ដោយការឱ្យទាន (ព្រោះថា) ទានដែលគេឱ្យហើយ ឈ្មោះថាបានជញ្ជូនដោយល្អក៏យ៉ាងនោះដែរ។



www.elibraryofcambodia.org

# ២៨.ជីវិតអ្នកក្រគឺយ៉ាងហ្នឹងឯង

ធ្វើការរកស៊ីក្រោមកម្ដៅថ្ងៃ ស្វែងរកកំរៃចិញ្ចឹមជីវិត
ព្រមទាំងគ្រួសារបងប្អូនញាតិមិត្ត លំបាកមែនពិតជីវិតអ្នកក្រ។
រាល់ថ្ងៃធ្វើការឥតមានទំនេរ ខ្លះធ្វើខ្ញុំគេរស់ទាំងត្រដរ
ហូបតែមួយពោះរស់តែមួយត ខ្លះធ្វើកម្មករគ្មានទំនេរទេ។
អ្នកមានព្រឹកឡើងជុំគ្នារកស៊ី អ្នកក្រមូលមីធ្វើការជូនគេ
បានប្រាក់ខែខ្លះពុំសូវទំនេរ សងជំពាក់គេបំណុលចាស់ថ្មី។
អ្នកផ្សាររាល់ថ្ងៃធ្វើការលក់ដូរ អ្នកស្រែថ្ងូចថ្ងូរមិនដឹងធ្វើអ្វី
នៅរដូវប្រាំងទឹករីងស្ងួតដី ខ្លះឃ្វាលក្របីគោតាមវាលស្រែ។
អ្នកខ្លះកាប់ឈើជីកក្ដួរជ្រោយដី ខិតខំឃ្មាតខ្មីឥតមានពេលល្ហែ
អ្នកខ្លះដាំស្រូវឆ្លៀតដាំបន្លែ លក់ជាហូរហែលើកស្ទួយគ្រួសារ។
ចំណែកក្មេងៗមិនសូវបានរៀន ព្រោះខ្លះធនធានរស់ឆ្ងាយសាលា
ម្យ៉ាងផ្លូវលំបាកនាខែវស្សា ទឹកជន់កាលណាទៅមកមិនបាន។
ស្ដីពីគ្រួសារមិនសូវជាចេះ ព្រោះខ្វះចំណេះមិនខំរុញច្រាន
ឱ្យកូនធ្វើអ្វីតាមចិត្តសន្ដាន និយាយថ្មើម៉ានបានរឿងតែម្ដង។
ម្យ៉ាងផ្ទះសម្បែងគ្មានសណ្ដាប់ធ្នាប់ ធ្វើតាមទម្លាប់ខ្វះគ្មានរបង
ពេលបាត់របស់ឈ្លោះអស់ប្អូនបង រឿងតូចចម្លងទៅជារឿងធំ។


www.elibraryofcambodia.org

មួយទៀតអ្នកក្រដោយសារតែល្ងង់ កូនទើបជំទង់ឬទើបក្រមុំ
ឱ្យមានគ្រួសារចាប់គ្នាផ្សំផ្គុំ ខ្លះវាយគ្នាយំគ្មានដែលលោះថ្ងៃ។
ពេលដែលមានកូនមិនសូវដឹងការណ៍ កូនយំកាលណាវាយគ្មានសំចៃ
គ្រួសារក្រីក្រឈ្លោះគ្នារញៃ បាត់អស់តម្លៃនៅក្នុងគ្រួសារ។
ជីវិតអ្នកក្រគឺយ៉ាងហ្នឹងឯង រស់នៅដូចផ្សែងព្រោះខ្វះប្រាជ្ញា
បានសុខខ្លះដែរតាមកម្មវាសនា រស់ទាំងខ្លោចផ្សាជីវិតអ្នកក្រ។

*សូមអនុមោទនា !!!*

ហោយសាចណេរ សោ ចាន់រ៉ាត់

**ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា**
**អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា ។**
**ឯតមត្ថវសំ ញត្វា សីលសំវុតោ**
**និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។**

កាលបុគ្គល ត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយមិនមានដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងញាតិផៅ ក៏មិនមានដើម្បីជាទីពឹងឡើយ ទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ ជម្រះផ្លូវជាទីទៅកាន់ព្រះនិព្វានឱ្យបាន។ ( **មគ្គវគ្គទី២០ បិដកលេខ៥២**)



www.elibraryofcambodia.org

## ២៩.រូបកាន់តែចាស់ ចិត្តកាន់តែក្មេង

បែខុនចង់ដែសម្លេងភ្លេងការ ឮច្បាស់កាលណានិរាព្រួយភ័យ
នឹកឃើញកាលខ្លួនអាយុជាងម្ភៃ ចិត្តគិតលក់លែចង់ការម្តងទៀត។
ខ្លួនកាន់តែចាស់មិនរៀនធម៌អាថ៌ ភ្នែកពាក់វ៉ែនតាមិនគិតខំឆ្លៀត
ក្បត់ប្រពន្ធខ្លួនលាក់ពូនចោលមៀ្រត ល្បិចកលសិកសៀតក្នុងល្បែងស្រីស្រា។
និយាយពីកូនប្រហែលមួយតៅ និយាយពីចៅរាប់ភ្លេចហើយណា
ខ្លួនឯងចាស់សោះស្នេហ៍តែកញ្ញា គេហៅខ្លួនតាឱ្យនាងហៅបង។
ពួកនាងបានលុយប្រចុយហៅតាម ដោយសារញៀនញាំមលុយកាក់បាតង
មិនខ្មាសកូនចៅញាតិមិត្តអ្នកផង ប្រព្រឹត្តកន្ទងតាមតែតណ្ហា។
ខារាអូខេច្រៀងរាំឆ្លើយឆ្លង ស្រីញីអូនបងផឹកស៊ីតាមចា
កណ្តាលអធ្រាត្រស្រែកច្រៀងឡូឡា មកផ្ទះកាលណាបានរឿងតែម្តង។
បើប្រពន្ធស្តីរឹងរូសមិនស្តាប់ ម្តងនោះជិតស្លាប់បើកបុករបង
ប៉ូលីសទៅជួយខ្មាសគេកន្លង កូនយំរំពងចៅៗសើចតា។
ម្យ៉ាងទៀតបើសិនយាយបើកវិទ្យុ ដូចចាប់ដាក់គុកចិត្តមិនជ្រះថ្លា
បើឮចម្រៀងពីរឿងស្នេហា មុខរីកដូចផ្កាលង់តាមបទភ្លេង។
ចំណែកអ្នកខ្លះគេក៏ល្អដែរ ធ្វើបុណ្យរាល់ខែតាំងពីនៅក្មេង
ចិត្តគេនឹងធឹងមិនបានវង្វេង ឬគិតអ្វីផ្សេងក្រៅពីធម៌អាថ៌។


www.elibraryofcambodia.org

រីឯយាយខ្លះមិនដែលទៅវត្ត មើលតែចៅគាត់គ្មានខ្វល់នរណា
ខ្វល់តែការផ្ទះនិងកន្ត្រកស្លា ភ្លឺឡើងកាលណាមើលកូនជូនគេ។
នេះហើយរស់នៅដោយខ្វះប្រាជ្ញា កើតទាន់សាសនាមិនគិតរិះរេ
មិនខំសាងគុណធ្វើបុណ្យទុកទេ ខឹងអីអាងជេរដូចនៅកុមារ។
ដឹងថាខ្លួនចាស់ម្តេចមិនសាងចិត្ត ធ្វើតែទុច្ចរិតដឹងចាំកាលណា
ប្រយ័ត្នស្លាប់ទៅវង្វេងទុក្ខសោកា សមដូចលោកថារូបចាស់ចិត្តក្មេង។

*សូមអនុមោទនា !!!*

ដោយសាមណេរ សា ចាន់រ៉ាត់

យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយគេមិនប្រមាទវិញ បុគ្គលនោះឈ្មោះថា ញ៉ាំងខន្ធាទិលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតចាកពពក។

អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ
សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្តាជនទាំងនេះ ជនតិចគ្នាដែលឃើញច្បាស់ (ខន្ធាទិលោកនេះដោយអំណាចអនិច្ចលក្ខណៈជាដើម) ។

( លោកវគ្គទី១៣ បិដកលេខ៥២)



www.elibraryofcambodia.org

# ៣០-កុំអាងខ្លួនចាស់ មិនស្តាប់គេក្មេង

មានះរឹងត្អឹងមិនស្តាប់គេខ្លះ ដោយអាងខ្លួនចាស់ប្រកាន់អាត្មា
ក្មេងប្រាប់ណែនាំគ្មានយកជាការណ៍ អួតខ្លួនឯងថាយើងដឹងអស់ហើយ។
ពេលខ្លះខ្លួនល្ងង់មិនដឹងមែនពិត តែក្នុងគំនិតគ្មានចាញ់គេឡើយ
បើក្មេងបង្រៀនធ្វើឫកតោះតើយ ខ្លះសួរមិនឆ្លើយឫកធំអស្ចារ្យ។
នេះហើយគេហៅមនុស្សដូចផ្លែល្ហុង រឹងក្រៅទន់ក្នុងជូរដូចក្រូចឆ្មា
ពីតូចដល់ធំគ្មានផ្អែមម្តងណា ចិត្តខ្លាំងជាងខ្លាចាស់ដូចផ្លែត្នោត។
កាលគាត់នៅក្មេងគេថាបានខ្លះ ឥឡូវប្រែផ្លាស់ចេះគ្មានគេកោត
រស់កាន់តែយូររៀនរឹតតែឆោត អាយុរាប់កោដិឱ្យក្មេងថាបាន។
គេក្មេងមែនពិតតែរៀនបានខ្ពស់ គួរតែពិគ្រោះសួរគេកុំខាន
គំនិតនៅល្ងង់ចាស់តែខ្លួនប្រាណ ពោលឡើងថ្មើមានដូចគ្មានបានការណ៍។
រឿងចាស់ឬក្មេងអាស្រ័យលើវ័យ ល្ងង់ឬឈ្លាសវៃអាស្រ័យប្រាជ្ញា
បើរស់មិនរៀនល្ងង់លុះមរណា ក្មេងមែនសិក្សាគេចេះជាងហើយ។
អ្នកខ្លះខ្លួនចាស់អាងទ្រព្យធនធាន មិនគិតខំរៀនគំនិតតោះតើយ
ពេលក្មេងណែនាំធ្វើឫកកន្តើយ ជិតស្លាប់ទៅហើយនៅតែអស្ចារ្យ។
មែនហើយបើចាស់សូមចាស់គំនិត តែបើធំពិតសូមធំប្រាជ្ញា
ស្តាប់អស់គេឯងកុំអួតអាត្មា ស្តាប់ក្មេងផងណាកុំខ្ជិលធ្វើហី។



www.elibraryofcambodia.org

ចាស់ខ្លះធ្វើអ្វីអាងបទពិសោធន៍ ក្មេងថាមិនកោតល្ងង់ដូចក្របី
អាងវ័យខ្លួនចាស់ស្គាល់អស់ទឹកដី តែគំនិតខ្ចីដូចជនពាលា។
ការពោលយ៉ាងនេះមិនមែនទាំងអស់ តិចតួចប៉ុណ្ណោះគិតចុះមីងមា
បើដឹងខ្លួនហើយកែទាំងអស់គ្នា ដើរតាមមាគ៌ាព្រះពុទ្ធទើបល្អ។
បើដាក់មានះចំណេះកើតឡើង បើលើកតម្កើងភាពល្ងង់ជាន់ក
ព្រមស្ដាប់គេខ្លះជារឿងមួយល្អ ជីវិតបវរដោយចេះស្ដាប់គេ។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**

**អប្បមាទោ អមតំបទំ បមាទោ មច្ចុនោ បទំ**
**អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។**

សេចក្ដីមិនប្រមាទ ជាផ្លូវនៃសេចក្ដីមិនស្លាប់ សេចក្ដីប្រមាទ ជាផ្លូវនៃសេចក្ដីស្លាប់ ជនទាំងឡាយដែលប្រមាទហើយ ទុកដូចជាស្លាប់ទៅហើយ។

**បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា**
**អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។**

ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយៗនូវសេចក្ដីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្ដីមិនប្រមាទ ដូចទ្រព្យយ៉ាងប្រសើរ។



www.elibraryofcambodia.org

## ៣១. បើសិនបានល្អជួយគេផងណា៎

ខ្លួនមានសក្តិយសរស់បានថ្កុំថ្កើង ជួយលើកតម្កើងអស់ញាតិកា
មនុស្សធ្វើរបងគ្រាន់ជាងបន្លា ជួបប្រាប់ស្តីថាការពារយប់ថ្ងៃ។
មែនហើយទ្រព្យធនសម្បត្តិនានា រកស៊ីធូរធារស់មានតម្លៃ
ដោយសារមានញាតិឧបត្ថម្ភរាល់ថ្ងៃ បានសុខពេកក្រៃដោយញាតិប្រុសស្រី។
ស្តីពីឋានៈតែងមានទាបខ្ពស់ ខ្លះមានសក្តិយសហួសនឹងពោលស្តី
បើសិនប្រៀបធៀបដូចមេឃនិងដី មនុស្សក្នុងលោកិយខុសគ្នាស្រឡះ។
ប្រុសស្រីបានរស់ដោយពុកនិងម៉ែ ចិញ្ចឹមថ្នមថែចិត្តលោកល្អល្អះ
ខ្លួនបានសុខហើយចូរគិតឱ្យច្បាស់ អ្នកមានគុណចាស់ត្រូវថែរក្សា។
មនុស្សលោកឥឡូវពេលខ្លួនសុខហើយ គិតមិនឃើញឡើយមាតាបិតា
អ្នកជួយជ្រោមជ្រែងតាំងពីកុមារ ដល់ធំកាលណាកុំភ្លេចស្មារតី។
បើសិនបានរស់គាប់ប្រសើរហើយ មិនគួរភ្លេចឡើយបុព្វការី
គួរតបគុណចាស់សាងបុណ្យជាថ្មី ជីវិតប្រិមប្រិយដោយបុណ្យអ្នកសាង។

*សូមអនុមោទនា !!!*

**ដោយសាចណោរ សា ចាន់ភ័ត្**



www.elibraryofcambodia.org

## ៣២. រៀនចុះភាសាបរទេសកុំភ្លេចរៀនភាសាខ្មែរ

សម័យModernភាសាច្រើនណាស់ Good atខ្លាំងណាស់ភាសាសម័យ
ជាពាំងអង់គ្លេសចិនឡាវនិងThai ត្រៀមOrganizeឱ្យមនុស្សសិក្សា។
និយាយម្តងៗFastស្តាប់មិនទាន់ Languagesរយពាន់ស្តាប់មិនយល់ការណ៍
Helloពុកម៉ែសុទ្ធតែភាសា Wordsខ្មែរធម្មតាមិនព្រមពោលស្តី។
Speaksយូរៗទៅដូចស្តាប់មិនបាន Hearsហើយថ្មើម៉ានគំនិតខើចខ្ចី
Don't knowពាក្យខ្មែរសំស្ក្រឹតបាលី Tryចុះប្រុសស្រីកុំភ្លេចខ្មែរយើង។
In fact ពាក្យខ្មែរគួររៀនឱ្យច្បាស់ Thinksឱ្យល្អល្អះមិនមែនកាន់ជើង
ថា Words khmerល្អធ្វើបូកពើតពឹង Ideasទំនើងថាគេខុសទេ។
Sinceខ្ញុំកើតមកនិយាយតែខ្មែរ Liveក្នុងស្រុកស្រែគ្មានពេលទំនេរ
Studyបានតិចគ្រាន់តែប្រាប់ទេ Give youរិះរេស្វែងរកប្រាជ្ញា។
បើlifeនៅមានខំសិក្សាទៅ Handsចាំសៀវភៅអានពិចារណា
searchឱ្យបានច្រើនកុំខ្លាចគេថា ផ្ទៀតស្តាប់Dhammaព្រះពុទ្ធសម្តែង។
បើសិនមិនរៀនពិតជាFoolish ទោះរៀនEnglishខិតខំប្រឹងប្រែង
Don't understantងងឹតដូចផ្សេង Dhammaចិញ្ចៀងគួរស្តាប់គ្រប់គ្នា។
មែនហើយForeignsគួរតែសិក្សា ទាក់ទងកិច្ចការផ្លាស់ប្តូរIdeas
ភាសាកូរ៉េជប៉ុនIndia រៀនទាំងអស់គ្នាកុំបីLazy។



www.elibraryofcambodia.org

ម្យ៉ាងទៀតអង់គ្លេសImportaintណាស់ គួររៀនឱ្យច្បាស់កុំថាeasy
Grammerខ្មែរយើងចូរខំសំភី Studiesទាំងពីរប្រសើរអស្ចារ្យ។
ម្យ៉ាងទៀតបើសិនYou are clever ចូរប្រកាន់ជឿសិក្សាDhamma
ធ្វើបុណ្យដាក់ទានទៅPagoda If youសិក្សាកុំភ្លេចព្យាយាម។
One day to dayដូចលៀនអស្ចារ្យ គួរតែសិក្សាគ្រប់words idiom
ទោះwordsធម្មតារៀនកុំនៅស្ងៀម អ្នកត្រូវព្យាយាមចម្រើនwisdom។
រៀនចុះLanguagesគ្រប់សាសន៍ណាៗDon't forgetថារៀនខ្មែរផ្សំផ្គុំ
Cozយើងជាខ្មែរកុំបីសើចយំ ចំណែករូបខ្ញុំjustប្រាប់អ្នកទេ។
Childrenឥឡូវគេឆ្លាតខ្លាំងណាស់ All thingsប្រែផ្លាស់គ្មានពេលទំនេរ
គេរៀនរាល់ថ្ងៃSkillចិនកូរ៉េ គួរតែរិះរកStudyខ្មែរផង។

**ដោយសាមណេរ សា ចាន់រ៉ាត់**

**ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ**
**ខេមី អវេរី អភយោ បណ្ឌិតោតិ បវុច្ចតិ ។**

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា ឈ្មោះថាជាបណ្ឌិតដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលដែលមានសេចក្តីក្សេមមិនមានពៀរ មិនមានភ័យ ទើបហៅថាបណ្ឌិតបាន។ ( ធម្មបទគាថាទី១៩ បិដកលេខ៥២)


www.elibraryofcambodia.org

# ៣៣_កុំភ្លេចកំណើត

ស្រូវគ្រប់ប្រភេទបានពីស្រែ កូនកើតពីម៉ែគ្មានសង្ស័យ
រស់សាងទុច្ចរិតគ្មានតម្លៃ សាងទោសរាល់ថ្ងៃជួបបញ្ហា។
រស់នៅជាមនុស្សត្រូវសាងគុណ កុំសាងទារុណលើមាតា
ត្រូវតែគោរពក្នុងបិតា ព្រះនេះហើយណាប្រសើរក្រៃ។
គ្រប់ជាតិជាមនុស្សក្នុងលោកិយ ត្រូវមានស្មារតីសាងតម្លៃ
ត្រូវដឹងគុណគេទាំងយប់ថ្ងៃ ខិតខំកែខៃដោយប្រាជ្ញា។
កូនចៅកុំភ្លេចគុណឪម៉ែ ដែលលោកថ្នមថៃដោយមេត្តា
គួរឆ្លៀតតបគុណដោយគិតថា ខ្លួនធំកាលណាជួយពុកម៉ែ។
សម័យឥឡូវមានកូនខ្លះ មិនជួយម្ដាយចាស់រស់ស្រុកស្រែ
ខ្លួនមកទីក្រុងចិត្តប្រួលប្រែ ភ្លេចគុណពុកម៉ែភូមិកំណើត។
ទឹកដីទីក្រុងសែនស្រស់ស្អាត កូនខ្លះមិនឆ្លាតគំនិតឆើត
ភ្លេចអស់ពុកម៉ែអ្នកបង្កើត ពេលខ្លួនបានកើតភ្លេចស្រុកស្រែ។
ទឹកចិត្តពុកម៉ែនឹកកូនណាស់ កូនគាត់ផ្ដេសផ្ដាសគ្មានគិតម៉ែ
គាត់ផ្ដល់លុយកាក់រាល់ថ្ងៃខែ លក់ចម្ការស្រែឱ្យសិក្សា។
កាលនៅជនបទរៀនឆ្លាតណាស់ ដល់ក្រុងប្រែផ្លាស់បួកហ៊ុហា
ខ្លួនអ្នកស្រែសោះប្លុកបាតផ្សារ ចាយលុយដុល្លារញើសឈាមម៉ែ។


www.elibraryofcambodia.org

គ្រួសារឯណោះសង្ឃឹមថា កូនវិលកាលណាលោកល្ហើយល្ហែ
រំពឹងក្នុងចិត្តអរផងដែរ ដឹងអីកូនម៉ែគ្មានបានការណ៍។
មែនហើយទីក្រុងសែនស្រស់ស្អាត គួរតែសង្វាតខំសិក្សា
ស្វែងរកវិជ្ជាជួយអាត្មា ព្រមទាំងខេមរាជាតិថ្កើងថ្កាន។
ដូច្នេះប្រុសស្រីកុំភ្លេចឡើយ ខិតខំឱ្យហើយគ្រប់ៗប្រាណ
ស្វែងរកវិជ្ជាកុំបីខាន ពេលសុខថ្ងៃមាន់ជួយជាតិយើង។

**ដោយសាចណោរ សា ចាន់រ៉ាត់**

## ៣៤.រវល់ណាស់តែភ្លេចស្លាប់

រាត្រីត្រជាក់ដេកក៏មិនលក់ ចិត្តខ្វល់វិរក់ផ្ដើមតែងអត្ថា
ជាចំណងដៃទុកជូនយាយតា គ្រាន់ពិចារណាក្នុងឆាកជីវិត។
ពាក្យកាព្យមួយនេះស្ដីពីរវល់ រឿងរ៉ាវអំពល់តែងមានពិតៗ
នឹងពោលត្រង់ៗមិនបានប្រឌិត ស្ដីតាមគំនិតដែលជួបហេតុការណ៍។
ស្ដីពីពួកមនុស្សទាំងអស់ប្រុសស្រី កើតក្នុងលោកិយត្រូវធ្វើកិច្ចការ
រកទ្រព្យសម្បត្តិចិញ្ចឹមអាត្មា ព្រមទាំងគ្រួសារឱ្យសុខសប្បាយ។
រឿងទ្រព្យធនធានពិតសំខាន់ណាស់ តែសូមក្មេងចាស់គិតកុំរសាយ
មិនមែនមានទ្រព្យផុតទុក្ខទាំងឡាយ ចូរអ្នកខ្វល់ខ្វាយសាងគុណធម៌ចុះ។
មានជនពួកខ្លះធ្វើការរកស៊ី ខែមួយខែពីរទាំងស្រីទាំងប្រុស


www.elibraryofcambodia.org

បានមួយខ្វះពីរព្រោះមិនសន្តោស ខ្លះរកស៊ីខុសក្នុងច្បាប់មាត្រា។
មើលអ្នករកស៊ីភ្ញីឡើងមិនទាន់ ទៅមករយពាន់មិនដឹងទៅណា
ខ្លះទៅឆ្ងាយជិតខ្លះថាទៅផ្សារ អ្នកខ្លះឡូឡាដណ្តើមម៉ូយគ្នា។
នៅតាមដងផ្លូវមនុស្សមីដេរដាស តូចធំក្មេងចាស់ទៅធ្វើការងារ
មិនសូវនៅផ្ទះគ្មានលោះវេលា ដោយសារទ្រព្យាខំគ្រប់អាត្មា។
ស្តីពីបុណ្យទានមិនសូវបានសាង ខ្លះពោលសំអាងថាខ្ញុំជាប់ការ
មិនសូវមានពេលទៅវត្តទៅវ៉ា ចាំបុណ្យកាលណាទៅធ្វើបានម្តង។
រីបុណ្យចូលឆ្នាំឬបុណ្យខែភ្ជុំ ថាចាំជួបជុំមីងមាប្អូនបង
បើធ្វើម្នាក់ឯងគេថាកន្លង ប្អូនធំជាងបងទាស់ចិត្តមេបា។
ពីព្រឹកដល់ល្ងាចរវល់ខ្លាំងណាស់ ពីក្មេងដល់ចាស់ធ្វើស្រែចម្ការ
មិនសូវធ្វើបុណ្យស្តាប់ធម៌ទេសនា ភ្លេចថ្ងៃមួយថាត្រូវស្លាប់ជាខ្មោច។
មែនហើយមុននឹងស្លាប់ចោលចាកលោក គួរសាងជម្រកគិតធ្វើប្រយោជន៍
គួរសាងកុសលតិចច្រើនដោយហោច កុំសាងអសោចិ៍នាំទុក្ខឥតអាក់។
បើសិនរវល់ខ្ញុំក៏មិនថា កុំភ្លេចធម៌អាថ៌យកចិត្តទុកដាក់
បើសិនមិនស្តាប់ងងឹតដូចខ្វាក់ ពិតជាប់ចំពាក់ក្នុងវដ្តសង្សារ។
នេះគ្រាន់តែជាគំនិតខ្ញុំទេ គិតចុះកុំជេរគ្រាន់ពិចារណា
កុំឱ្យរវល់លុះដល់មរណា គួររៀនធម៌អាថ៌ទើបបានទីពឹង។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ៣៥-ដូចខ្វះរឿងនិយាយ

រឿងរ៉ាវល្អៗ មិនចេះត្រេកអរ យកមកនិយាយ
បើទោសគេវិញ រែកពុនវេចស្លាយ មាត់ស្ដីរីករាយ
គ្មានពិចារណា។

ស្ដីពីទោសគេ ខ្លួនគ្មានខុសទេ ធ្វើបូកអស្ចារ្យ
ជុំគ្នាម្ដងៗ ពោលស្ដីចរចា អួតតែអាត្មា
ខ្លួនមិនដែលខុស។

មានជនពួកខ្លះ គំនិតផ្ដេសផ្ដាស មើលតែកំហុស
រឿងល្អមិនស្ដី មិនមានសន្ដោស ចាំចុះស្រីប្រុស
មនុស្សគ្មានបានការណ៍។

មនុស្សយើងកើតមក រស់នៅក្នុងលោក គ្រប់ជាតិណាៗ
មិនចង់ជួបសោះ និន្ទាស្ដីថា ចង់ជួបសុខា
និងពាក្យល្អៗ។

មនុស្សក្នុងលោកិយ មុននឹងស្រដី គួរគិតបន្ត
ក្រែងមានខុសឆ្គង គន្លងធម៌ស ស្លាប់ទៅកំជរ
នរកអវិចី។


www.elibraryofcambodia.org

គ្រប់ជនស្រីប្រុស តែងមានកំហុស ជាប្រក្រតី
កុំទាន់អាលអួត ថាខ្លួនមិនអី គួរគិតប្រណី
អ្នកធ្វើខុសផង។

ខ្លះមានទោសទណ្ឌ ព្រោះគំនិតភ័ន្ត និយាយសារសង
ស្តីមិនបានគិត ពោលខុសម្តង១ រឿងរ៉ាវប្អូនបង
គិតតែនិន្ទា។

គួរអនិច្ចា គ្រប់ៗសង្ខារ គួរមេត្តាគ្នា
បានជាមនុស្សហើយ គួរកុំសាងពៀរ នាំតែគ្រាំគ្រា
ក្នុងវដ្តសង្សារ។

នេះគឺរឿងពិត មិនបានប្រឌិត ពោលពាក្យមុសា
គឺពិតជាមាន នៅក្នុងលោកា មិនចេះតែថា
សង្កេតមើលចុះ។

រស់នៅសាងបុណ្យ ខិតខំសាងគុណ ទាំងស្រីទាំងប្រុស
គួរពោលសច្ចៈ ទើបផុតកំហុស ខិតខំបណ្តុះ
ពូជនិព្វានហោង។

*សូមអនុមោទនា !!!*

**ដោយសាចណោរ សា ចាន់រ៉ាត់**


www.elibraryofcambodia.org

# ៣៦.វទល់សាងស្នេហ៍ភ្លេចគុណម៉ែឳ

ក្មេងទាន់សម័យគេហ៊ុហា　　មិនស្ដាប់មេបាប្រៀនប្រដៅ
ធ្វើអ្វីតាមចិត្តគ្មានគោលដៅ　　ព្រោះតែល្ងង់ខ្លៅគំនិតខ្វី។
ស្លីពីស្លៀកពាក់មិនសមសោះ　　មុខមាត់ស្រស់បស់ទាំងប្រុសស្រី
មើលទៅខោអាវដឹងម៉ូដស្អី　　ហួសនឹងពោលស្ដីថ្លែងវាចា។
កាលនៅតូចៗស្រួលស្ដីប្រាប់　　ធំឡើងសែនយ៉ាប់ខុសតម្រា
ម្ដាយឱ្យទៅរៀនគេចសាលា　　វិវក់ស្នេហាភ្លេចស្មារតី។
មួយថ្ងៃៗថារៀនឈ្នួល　　ចិត្តសែនប្រែប្រួលមិនឃ្លាតខ្វី
រៀនមិនឆ្លាតល្ងង់ដូចក្របី　　ជាប់ល្បែងស្រីគេមផ្ដេសផ្ដាស។
និយាយពីរៀនគ្មានស្ដាប់គ្រូ　　ស្លីមាត់រអ៊ូធ្វើមុខក្រាស់
ដៃវវាមត្រចៀកពាក់កាស　　ចិត្តគិតផុងបាសពីយប់មិញ។
គ្រូដាក់លំហាត់ធ្វើមុខស្ពុយ　　ធ្វើទាំងប្រថុយគិតមិនចេញ
មិនខំរៀនមាត់ស្វូត្រទន្ទេញ　　ចាំតែគេដេញទើបម្នីម្នា។
និយាយពីពុកហើយនឹងម៉ែ　　រស់ឯស្រុកស្រែសែនវេទនា
រកប្រាក់ឱ្យកូនរៀនវិជ្ជា　　បែកញើសគយារទាំងថ្ងៃយប់។
ការងារស្រាលធ្ងន់មានទូលរែក　　មិនសូវបានដេកគ្មានពេលឈប់
ក្រែងលោកូនគាត់ចាយមិនគ្រប់　　គាត់ខំប្រឹងទប់ជួយគ្រួសារ។



www.elibraryofcambodia.org

ស្ដីពីកូនគាត់គំនិតឆើត | រៀនសូត្រមិនកើតជាប់ស្នេហា
ភ្លេចអស់ស្រុកស្រែបូកដូចផ្សារ | ជួបម៉ែកាលណាធ្វើបូកធំ។
អ្វីៗម៉ែពឹងលើកូនហើយ | កូនបែរកន្ដើយហើយមាសមុំ
ពុកម៉ែឈឺចិត្តស្រែកទូញយំ | ប្រៀបដូចជាភ្នំបាក់សង្កត់។
បើកូនបានសុខម៉ែមិនថា | ក្រែងកូនសោកាម៉ែខំអត់
ព្យាយាមជួយកូនមិនគិតហត់ | ទោះក្ដៅជូរចត់ម៉ែមិនថា។
មានកូនពូកខ្លះគំនិតខ្ចី | រវល់ជាប់ស្រីញៀនស្នេហា
មិនខំស្វែងរកជោគវាសនា | ឬខំសិក្សាជួយជាតិឡើយ។
កំហុសកើតឡើងអ្នកត្រូវកែ | គិតរាល់ថ្ងៃខែកុំកន្ដើយ
ម៉ែឪមានគុណតបឱ្យហើយ | ឱ្យលោកបានស្បើយពីទុក្ខហោង។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**

**តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ នរំ**
**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

មច្ចុ គឺសេចក្ដីស្លាប់ តែងនាំយកនរជន អ្នកស្រវឹងជ្រប់ក្នុងកូន និងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗនោះ ដូចជំនន់ទឹកធំនាំយកអ្នកស្រុកកំពុងដេកលក់។ (មគ្គវគ្គទី២០ ចិតកលេខ៥២)



www.elibraryofcambodia.org

# ៣៧-សាលាខ្ញុំរៀន

សាលាឈើទ្រើងខ្ញុំសម្លឹងឆ្ងាយ ពេលនេះឃ្លាតកាយចិត្តសែនស្រណោះ
ជញ្ជាំងក៏ចាក់កណ្ដៀរស៊ីអស់ គួរឱ្យអាឡោះសាលាខ្ញុំរៀន។
ជាងដប់ឆ្នាំឆ្ងាយអ្វីៗប្រួលប្រែ ចាកចេញពីស្រែដែលធ្លាប់អត់ឃ្លាន
មករស់ទីក្រុងជាមួយអ្នកមាន គួរឱ្យខ្មាសអៀនជីវិតអ្នកក្រ។
កាលនៅស្រុកស្រែគោក្របីព្រាត ដល់ក្រុងនឹកញាតិសិក្សាបន្ត
សាលាគេខ្ពស់សាងពីឥដ្ឋថ្ម គេស្លៀកពាក់ល្អចាយវាយហ៊ុំហា។
ពេលចេញពីផ្ទះមកស្នាក់ក្នុងវត្ត ចិត្តមិនដែលភ្ញាត់ពីការសិក្សា
ខ្លួនរៀនពូកែព្រោះគុណវត្តវ៉ា ព្រមទាំងសាលាគ្រូបង្រៀនផង។
កាលនៅឯផ្ទះដើរឃ្វាលក្របី ដល់ក្រុងចិត្តថ្មីរៀនល្អឥតហ្មង
ដោយមានគុណគ្រូទើបបានប្រឡង ជាប់ដូចបំណងឡើងថ្នាក់រាល់ឆ្នាំ។
ឱ!ភូមិកំណើតពេលនេះឃ្លាតពិត តែក្នុងគំនិតនៅតែចងចាំ
សាលាធ្លាប់រៀនគ្រូធ្លាប់ផ្ដែផ្ដាំ ទំនេរពលកម្មសំអាតទីធ្លា។
កន្លែងសិក្សានៅសាលាមែន តែរឿងពិតមែនគឺគ្រូគ្រប់គ្នា
ព្យាយាមបង្រៀនសិស្សគ្រប់អង្គា ឱ្យមានវិជ្ជាចំណេះភ្លឺថ្លា។
យប់នៅឯផ្ទះម៉ែខំបង្រៀន មកសាលារៀនគ្រូប្រាប់ស្ដីថា
តែពេលឥឡូវឃ្លាតឆ្ងាយអស្ចារ្យ រស់នៅឯកាចិត្តសែនរងា។


www.elibraryofcambodia.org

ទីក្រុងស្រស់ស្អាតសាលាធំហួស	គេរៀនថ្នាក់ខ្ពស់ឆ្លាតគ្រប់ៗគ្នា
ខ្លួនមកពីស្រែកម្សត់ទ្រព្យា	រស់ទាំងកំព្រាចិត្តមិនសុខទេ។
ពេលចេញពីផ្ទះបានគុណវត្តវ៉ា	ស្នាក់នៅសិក្សាមិនចាច់ជួលគេ
ឆ្លៀតជួយវត្តខ្លះនៅពេលទំនេរ	ពេលខ្លះសរសេរកំណាព្យជូនញាតិ។
នេះគឺរឿងពិតនៃជីវិតខ្ញុំ	ពីតូចដល់ធំរស់ទាំងចង្អៀត
ពីដើមជួបជុំឥឡូវត្រូវឃ្លាត	គ្រួសារព្រោងព្រាតព្រោះតែសិក្សា។
ឱ!សាលារៀនមានគុណតេជះ	ខ្ញុំចេះជ្រៅជ្រះហើយមានប្រាជ្ញា
គុណនេះធំណាស់ហួសនឹងវាចា	គុណគ្រូអាចារ្យអ្នកបង្ហាញផ្លូវ។
មួយទៀតគុណដែលធំហួសគណនា	ត្រូវតបគ្រប់គ្នាគឺម៉ែនឹងឪ
គាត់មានជីវិតធ្វើឱ្យហើយទៅ	ទើបផុតហ្មងសៅក្នុងជីវិតអើយ។

ដោយសាមណេរ សា ចាន់រ៉ាត់

**អសជ្ឈាយមលា មន្តា	អនុដ្ឋានមលា ឃរា**
**មលំ វណ្ណស្ស កោសជ្ជំ	បមាទោ រក្ខតោ មលំ ។**

មន្តទាំងឡាយមានការមិនស្វាធ្យាយ ជាមន្ទិល ផ្ទះទាំងឡាយមានការមិនថែទាំ ជាមន្ទិល សេចក្តីខ្ជិល ជាមន្ទិលរបស់សម្បុរ សេចក្តីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា។ (មលវគ្គទី១៨ បិដកលេខ ៥២)


www.elibraryofcambodia.org

# ៣៨-ពេលជួបបញ្ហា ទើបស្រែករកម៉ែ

ត្រីក្រៀមស្រកាស្វែងរកគង្គា
យប់គ្មានចន្ទ្រាងងឹតខ្លាំងណាស់
ស្តីពីក្មេងៗធ្វើអ្វីផ្តេសផ្តាស
មិនសូវស្តាប់ចាស់ទូន្មានស្តីថា។
ឱ្យធ្វើខាងជើងទៅធ្វើឯត្បូង
មិនតាមគន្លងមាតាបិតា
ធ្វើតាមចិត្តឯងគ្មានស្តាប់មេបា
សប្បាយហ៊ឺហាមិនសូវដឹងអី។
ប្រាប់ឱ្យធ្វើបុណ្យមិនសូវចេះសោះ
បើល្បែងឡេះឡោះមិនបាច់ហាស្តី
ខ្លួននៅក្មេងៗគួរតែឃ្មាតខ្មី
ខំប្រុងស្មារតីសិក្សាវិជ្ជា។
ពេលខ្លួនសប្បាយច្រើនភ្លេចម៉ែឪ
តែពេលយូរទៅទើបវេទនា
រស់ឆ្ងាយម៉ែឪជីវិតកំព្រា
បីដូចនាវាកណ្តាលសមុទ្រ។
ម៉ែឪមានគុណធ្ងន់ជាងប្រឹថពី
គួរតែសំភីគុណថ្លៃបរិសុទ្ធ
គួរតបគុណខ្លះទើបបានរួចផុត
នរកមិនដុតទើបមិនសោកា។
កូនខ្លះស្រស់ស្អាតចម្រើនដោយវ័យ
ម៉ែឪព្រួយភ័យខ្វល់ក្នុងចិន្តា
កាលកូននៅតូចព្រួយជាធម្មតា
កូនធំកាលណាទុក្ខមួយជាពីរ។
ដូច្នេះកូនចៅទាំងតូចទាំងធំ
អ្នកចូរស្តាប់ខ្ញុំកុំភ្លេចសំភី
ស្តាប់ម៉ែឪខ្លះទើបបានដល់ទី
ទុក្ខគ្មានញាំញីព្រោះដឹងគុណម៉ែ។

ដោយសាមណេរ សា ចាន់រ៉ាត់



www.elibraryofcambodia.org

## ៤៩- បើសិនចង់មានត្រូវលះបើសិនចង់ឈ្នះត្រូវចុះចាញ់

ធម្មតាអ្នកឈ្នះ តែងជួបប្រទះ នូវពៀរវេរា
អ្នកចាញ់មិនសុខ ក្នុងចិត្តគ្រាំគ្រា រស់ទាំងវេទនា
គុំកួនវែងឆ្ងាយ។

វីអ្នកចង់មាន លះទ្រព្យឱ្យទាន កប់ទុកគ្រាន់ចាយ
ជីវិតស្លាប់ពិត តែបុណ្យទាំងឡាយ ពិតជួយខ្វល់ខ្វាយ
ឱ្យផលមិនដាច់។

ពេលបុណ្យឱ្យផល ផុតក្តីកង្វល់ ខ្លះបានជាស្តេច
ខ្លះជាមន្ត្រី បុណ្យអ្នកសម្រេច ថែមទាំងកាត់ផ្តាច់
វាលវដ្តសង្សារ។

បើចង់ឈ្នះគេ គួរគិតរិះរេ យកឈ្នះអាត្មា
គឺឈ្នះចិត្តបាប កាត់ផ្តាច់តណ្ហា ទើបមានឈ្មោះថា
ឈ្នះមួយជីវិត។

រឿងក្រឬមាន អាស្រ័យធនធាន នេះគឺរឿងពិត
ឆ្លាតឬល្ងង់ខ្លៅ អាស្រ័យគំនិត អ្នកមានទ្រព្យពិត
គឺអរិយទ្រព្យ។

ឈ្មោះថាអ្នកមាន គឺចេះធ្វើទាន ទើបប្រសើរគាប់


www.elibraryofcambodia.org

បើមិនដូច្នោះ ពិតជាត្រូវជាប់ ធម៌ខ្មៅញីកញាប់
គឺការកំណាញ់។
មិនតែប៉ុណ្ណោះ ចាំចុះស្រីប្រុស រឿងឈ្នះឬចាញ់
គ្មានរសជាតិទេ កុំគិតថាឆ្ងាញ់ បើជាប់ស្រឡាញ់
ពិតត្រូវទុក្ខសោក។
មនុស្សលោកដោយច្រើន មាសប្រាក់ចម្រើន ច្រើនតែចាញ់បោក
កិលេសខ្លួនឯង ព្រោះគំនិតថោក មិនផុតទុក្ខសោក
ព្រោះគំនិតខ្លី។
ពេលមានជីវិត គួររៀនធម៌ពិត កុំខ្ជិលធ្វើហី
ឆ្លៀតស្តាប់ធម៌ខ្លះ គ្មានខាតបង់អី គួរតែឃ្លាតខ្ចី
ទើបជួបសុខពិត។

**ដោយសាមណេរ សា ចាន់រ៉ាត់**

**សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**
**ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ៕**

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះ ទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្តីសុខ។



www.elibraryofcambodia.org

## ៤០_កុំទាន់អាលអួត

ខ្លួនបានខ្ពង់ខ្ពស់សម្បូណ៌ទ្រព្យធន មានប្ដីប្រពន្ធដីស្រែចម្ការ
ផ្ទះធំកែវកងមាសប្រាក់ដុល្លារ ចាយវាយហ៊ឺហាមិនសូវខ្វល់ខ្វាយ។
ចំណីអាហារហូបចុកមិនខ្វះ ដោយសារបុណ្យចាស់រស់សុខសប្បាយ
ខ្លួនមានទ្រព្យហើយមិនគិតចំណាយ ដាក់ទានរាល់កាយធ្វើបុណ្យទុកទេ។
សម័យឥឡូវមានហើយអួតគ្នា ភ្លេចថាជរាមិនគិតរិះរេ
មិនផ្ទៀតស្ដាប់ធម៌សុខចិត្តទំនេរ ខឹងអ្វីអាងជេរអួតខ្លួនអ្នកមាន។
ពេលមានជីវិតគួរតែខំប្រឹង ប្រុសស្រីត្រូវដឹងធ្វើបុណ្យដាក់ទាន
កុំខ្ជិលច្រអូសនាំអន្តរធាន ស្លាប់ទៅអត់ឃ្លានខ្សត់ខ្សោយជាតិមុខ។
មានបុណ្យយសសក្តិកុំភ្លេចស្មារតី គួរតែឃ្មាតខ្មីសន្សំបុណ្យទុក
បានផលប្រយោជន៍គឺសេចក្ដីសុខ កុំអាងម៉ែពុកមានទ្រព្យសម្បត្តិ។
រីទឹកជំនន់មានឡើងមានស្រក បីដូចជាចកតាមទឹករសាត់
ចំណែកលាភយសស្ទើរឃើញស្ទើរបាត់ មនុស្សប្រែជាសត្វព្រោះកម្មអ្នកចារ។
អ្នកមានបូកធំកុំទាន់អាលអរ អ្នកតូចក្រីក្រកុំគ្រាន់អស្ចារ្យ
កុំទាន់អាលអួតតម្កើងអាត្មា ថ្ងៃមួយមរណាមានគ្រប់ៗគ្នា។
នេះគឺរឿងពិតមិនបានមុសា ចូរពិចារណាកុំទាន់និន្ទា
គួរគិតឱ្យច្បាស់តាមព្រះធម្មា រកសុខគ្រប់គ្នាឆ្ពោះនិព្វានហោង។

ដោយសាចណោរ សា ចាន់រ៉ាត់



www.elibraryofcambodia.org

# ៤១_កុំស្អប់ខ្លួនឯង

ខឹងអ្នកដទៃឬកខ្ចក់ខ្ចាញ់ តែបើស្រឡាញ់មុខស្រស់ថ្លា
បើក្រោធកើតឡើងមាត់ឡូឡា ប្រទេចផ្តាសាគ្មានប្រណី។
បើស្អប់ខ្លួនឯងមិនអីទេ តែបើស្អប់គេខឹងជេរស្តី
ខ្លះវាយដំកូនប្រពន្ធប្តី ព្រោះខ្វះខន្តីអាណិតគ្នា។
ចិត្តក្រោធកើតឡើងមិនសុខទេ ក្តៅចិត្តហើយជេរពោលនិន្ទា
មុខមាត់ស្អាតបាតចិត្តដូចមារ រស់ទាំងវេទនាព្រោះចិត្តខឹង។
តែទោះយ៉ាងណាទាំងស្រីប្រុស ចូរលះក្រោធចុះអ្នកខំប្រឹង
ទោសនេះធំណាស់អ្នកត្រូវដឹង បើក្តៅម៉្លឹងៗគួរជិនណាយ។
រឿងស្រឡាញ់ស្អប់ក្នុងចិន្តា ព្រួយឬសោកាសុខសប្បាយ
ជារឿងធម្មតារាល់រូបកាយ ចូរអ្នកខ្វល់ខ្វាយសាងធម៌ស។
បើស្អប់គេកុំភ្លេចខ្លួនឯង ចូរខំប្រឹងប្រែងដោយធ្វើល្អ
កុំបណ្តោយខ្លួនបាបជាន់ក ហើយកុំត្រេកអរធ្វើបាបកម្ម។
បណ្តាំចុងក្រោយកុំស្អប់ខ្លួន ធ្វើល្អផ្ទួនៗជាប្រចាំ
ទើបមិនសោយទុក្ខរយខែឆ្នាំ ចូរអ្នកចងចាំកុំស្អប់ខ្លួន។

ដោយសាមណេរ សា ចាន់រ៉ាត់



www.elibraryofcambodia.org

# ៤២. សប្បាយដល់ក

អ្នកមានហ៊ឺហា លុយឡានវិឡា ចាយវាយមិនខ្វះ
ចំណីអាហារ ខោអាវថ្មីចាស់ អ្វីៗប្រែផ្លាស់
តាមសម័យថ្មី។
ផ្ទះថ្មសែនធំ ខ្ពស់ប្រៀបដូចភ្នំ ស្រស់ស្អាតប្រិមប្រិយ
របងបិទជិត ក្នុងស្រះមានត្រី ព្រមទាំងមានដី
រាប់រយហិចតា។
ស្ដីពីធនធាន មិនដែលអត់ឃ្លាន ចាយសុទ្ធដុល្លារ
ពេលល្ងាចដើរលេង នៅតាមសួនច្បារ ជួបជុំគ្រួសារ
រីករាយឥតហ្មង។
អ្នកខ្លះកាលក្រ ចិត្តគាត់នៅល្អ ហៅរកប្អូនបង
ដល់ពេលខ្លួនមាន បូកធំកន្លង មិនស្ដីសារសង
ភ្លេចអស់ញាតិមិត្ត។
កាលនៅស្រុកស្រែ ដឹងគុណពុកម៉ែ ចេះគោរពពិត
ពេលរស់ទីក្រុង ផ្លាស់ប្ដូរគំនិត មិត្តភ័ក្ដិជិតស្និទ្ធ
ក៏ចាំមិនបាន។
ប្រាក់រៀលដុល្លារ ចេញពីធ្វើការ ជិះម៉ូតូឡាន



www.elibraryofcambodia.org

ស៊ីផឹកតាមចា ដឹងយប់ថ្ងៃម៉ាន ឡូឡារំខាន
ច្រៀងរាំផ្តេសផ្តាស។
ស្តីពីបុណ្យទាន មិនសូវប្រិតប្រៀន ថាចាំខ្លួនចាស់
ជាប់ការងារច្រើន រវល់ខ្លាំងណាស់ ពិតគ្មានឱកាស
ធ្វើបុណ្យស្អីទេ។
នេះហើយចាស់ថា អ្នកស្រែចូលផ្សារ ច្រើនគំនិតវេ
សីលទានមិនសាង អាងមិនទំនេរ ទូខ្មៅយពូកគ្រែ
ប្រើប្រាស់ហូរហៀ។
ស្តីពីធម៌អាថ៌ មិនសូវជ្រះថ្លា មិនស្តាប់ធម្មា
រវល់ញៀនទ្រព្យ ជាប់ល្បែងស្រាបៀរ គំនិតពាលា
ភ្លេចបុណ្យកុសល។
ពីដើមធ្លាប់ក្រ រស់ទាំងត្រដរ គ្មានអ្នកណាដល់
ឥឡូវមានហើយ មិនសូវខ្វាយខ្វល់ សាងមគ្គសាងផល
ថារឿងធម្មតា។
សប្បាយដល់ក ពីដើមខ្លួនក្រ បាច់ជួយនរណា
ក្រែងពេលស្លាប់ទៅ ខូចខាតឥតការណ៍ តាមព្រះទេសនា
ថាស៊ីបុណ្យចាស់។
សូមអភ័យទោស អស់លោកសប្បុរស កុំប្រែក្រឡាស់
សង្កេតមើលចុះ ពិតជាឃើញច្បាស់ ខ្ញុំឃើញច្រើនណាស់


www.elibraryofcambodia.org

សម័យឥឡូវ។

ពោលមកប៉ុណ្ណេះ ទុកជាចំណេះ កុំឱ្យអាស្រូវ

បើដឹងខុសហើយ ចូរកែតម្រូវ ស្វែងរកផ្លូវត្រូវ

តាមធម៌ព្រះពុទ្ធ។

*សូមអនុមោទនា!*

**ដោយសាចណោរ សា ចាន់រ៉ាត់**

## ៤៣_ខ្ញុំចេះពីអ្នក

សូរិយារះឡើងពន្លឺចិញ្ចែង ដែលចាប់ផ្ដើមតែងកាព្យជូនយាយតា

ជាចំណងដៃគ្រាន់ពិចារណា ខ្ញុំស្លាប់កាយាទឹកចិត្តរស់នៅ។

ខ្ញុំតែងកាព្យនេះមិនបានប្រឌិត ស្ដីតាមការពិតធ្វើជាសៀវភៅ

រីឯអត្ថន័យមានរាក់មានជ្រៅ រៀនគិតមើលទៅក្រែងខ្ញុំពោលខុស។

សម្រាកពីរៀនខំប្រឹងសរសេរ សង្កេតសួរគេទាំងស្រីទាំងប្រុស

អ្នកខ្លះចិត្តល្អមានក្ដីសន្ដោស ខ្លះក៏ប្រាប់ខុសអំពីហេតុការណ៍។

ការតែងកាព្យនេះតាមទង្វើអ្នក ដែលបានឃើញជាក់ច្បាស់នឹងនេត្រា

គ្មានចេះអំពីព្រះឥន្ទអង្គណា ឬពីទេវតាណាបង្រៀនឡើយ។

យប់ហើយនឹងថ្ងៃចេះពីអ្នកប្រាប់ រៀបរាប់សារស័ព្ទបំភ្លឺចម្លើយ

បើគ្មានអ្នកទេពិតជាសូន្យហើយ អ្នកកុំកន្តើយជួយទៀតចុះណា។



www.elibraryofcambodia.org

សៀវភៅក្បួនច្បាប់ថ្លៃឥតប្រមាណ កាន់មើលឬអានតែងបានប្រាជ្ញា
បើសិនគ្មានទេពិតជាមោហា គ្មានអ្វីសិក្សាងងឹតលុះក្ស័យ។
សៀវភៅជាគ្រូបង្ហាញផ្លូវច្បាស់ ពិតប្រាកដណាស់សិក្សារាល់ថ្ងៃ
បើគ្មានក្បួនច្បាប់គ្មានអ្វីកែច្នៃ រស់គ្មានតម្លៃព្រោះអវិជ្ជា។
គ្រប់ជនប្រុសស្រីកើតឡើងក្នុងលោក មិនដែលនាំមកសម្បត្តិទ្រព្យា
កើតមកតែខ្លួនទទេគ្រប់គ្នា បុណ្យសក្តិនានាមកជាមួយទេ។
ម្យ៉ាងទៀតប្រាជ្ញាចំណេះចេះដឹង ត្រិះរិះរំពឹងគ្មានពេលទំនេរ
ម្នាក់ៗខំណាស់ទាំងយើងទាំងគេ ដៃជើងទាំងទ្វេធ្វើការឥតឈប់។
តាមពិតសរសេរបានពីការគិត រៀបរាប់រឿងពិតទាំងឡាយសព្វគ្រប់
ដែលកើតមានឡើងទាំងថ្ងៃទាំងយប់ បកស្រាយបង្គ្រប់អត្ថន័យទូលាយ។
សរសេរកាព្យនេះលំបាកខ្លះដែរ អស់ពេលរាប់ខែជារឿងមិនងាយ
ទុកគ្រាន់ជាកេរ្តិ៍ធ្វើការវេចស្លាយ ឆ្លងបរលោកនាយគំនិតភ្លឺថ្លា។
ចំណេះពេលខ្លះបានពីខ្លួនឯង ខ្លះគ្រូសម្តែងប្រាប់ឱ្យសិក្សា
ខ្លះបានពីមិត្តជួយប្រាប់ស្តីថា ខ្លះបានដោយសារគាប់ជួនតាមកាល។
វេលានៅខ្លីស្តីមិនបានយូរ កុំមាត់រអ៊ូជេរស្តីរាលដាល
បញ្ចប់ខ្លីចុះកុំឱ្យបណ្តាល ខ្ញុំមិនផ្លាញ់ផ្លាលចេះពីអ្នកទេ។

**ដោយសាចណោរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ៤៤_ស្គាល់តែមុខតែមិនស្គាល់ចិត្ត

មុខមាត់ស្រស់ស្អាតគួរឱ្យគយគន់ នៃអស់មហាជនចាប់ចិត្តស្នេហា
ដៃជើងល្វិនល្វន់សម្បុរសថ្លា រាងរៅសង្ហាសម្ដីពីរោះ។
ចេញដើរម្ដងៗតែងខ្លួនហ៊ឺហា កាបូបវ៉ែនតាមើលទៅស្អាតហួស
ទំនងអ្នកធំមានបុណ្យសក្ដិខ្ពស់ ហើយមានលាភយសដូចអ្នកធ្វើការ។
មើលទៅខោអាវមិនមានចាក់ភ្លី សាកសមគ្មានពីរបួកធំអស្ចារ្យ
តាំងខ្លួនអ្នកធំរស់នៅទីផ្សារ ពោលពាក្យមុសាអួតអាងមានខ្នង។
ខ្លួនមានវ័យចាស់ស្នេហ៍តែស្រីក្មេង លួកប្រលែងលេងថាដូចប្អូនបង
មិនយូរប៉ុន្មានបែកការណ៍តែម្ដង ប្ដីងផ្ដល់ឱ្យសងរឿងរ៉ាវស្រីញី។
ឯអ្នកខ្លះទៀតធ្វើបួកខ្នក់ខ្នាញ់ គួរឱ្យស្រឡាញ់សមជានារី
ពេលដឹងប្រវត្តិប្ដីមួយប្ដីពីរ មិនខំរកស៊ីគិតតែតែងខ្លួន។
អ្នកខ្លះបួកពាដូចសុភាពណាស់ រូបក្មេងចិត្តចាស់ប្រាជ្ញាមាំមួន
ពេលសួរមែនទែនអ្នកប្រាជ្ញខុសក្បួន ធ្វើបាបផ្ទួនៗល្អតែមុខគេ។
ឃើញដើរត្រុកៗស្មានតែស្លូតពិត តែក្នុងគំនិតខឹងអ្វីអាងជេរ
គ្មានការងារធ្វើខ្ជិលដេកលើគ្រែ មានពេលទំនេរស៊ីផឹកស្រីស្រា។
ពាក្យចាស់ពោលថារឹងត្រៅទន់ក្នុង ឬហៅមនុស្សល្ហុងបានតែស្ដីថា
ក្នុងខ្លួនគ្មានខ្លឹមចិត្តកាចដូចខ្លា មាត់ធុំសុភអួតមានសីលប្រាំ។
ពេលមានបុណ្យទានតែងខ្លួនមុខមាត់ ស្មានតែទៅវត្តច្រៀងរាំរបាំ


www.elibraryofcambodia.org

អ្នកថាចេះធម៌សីលប្រាំមិនចាំ ខ្ញុំគេរាប់ឆ្នាំបួកចៅហ្វាយនាយ។
ស្គាល់តែមុខមាត់តែមិនស្គាល់ចិត្ត ខ្លួនកំណាញ់ស្អិតអ្នកថាទូលាយ
មុខមាត់រឹងប៉ឹងតែទាស់ចិត្តងាយ ខឹងស្អប់អាងវាយអ្នកកម្លាំងបាយ។
ដូច្នេះអស់លោកដែលជាសប្បុរស ក្មេងចាស់ទាំងអស់ចូរអ្នកខ្វល់ខ្វាយ
កុំទុកចិត្តគេនាំឱ្យអន្តរាយ ព្រោះមនុស្សទាំងឡាយស្គាល់ចិត្តមិនបាន។
ពោលមកប៉ុណ្ណេះចង់ឱ្យភ្ញាក់ខ្លួន កុំឱ្យជាប់ជួននាំតែខកប្រាណ
បើបានដឹងហើយចូរវិលវិញថ្កាន កែខ្លួនឱ្យបានកុំទុកចិត្តគេ។

*សូមអនុមោទនា!!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**

**ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ**

**ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។**

បុគ្គល មិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់។ ( **បណ្ឌិតវគ្គទី៦ បិដកលេខ៥២**)



www.elibraryofcambodia.org

## ៤៥_រៀនស្គាល់ខ្លួនឯង

ចង់ដឹងទម្ងន់ត្រូវលើកថ្លឹង    បើសិនចង់ដឹងត្រូវសាកសួរ
បើត្រូវការញាតិគប្បីគួរ    រិះរកសំណួរសួរតាមកាល។
បើចង់ដឹងរសត្រូវតែភ្លក្ស    ធ្លាញ់រកអន្ទក់កុំបណ្ដាល
បើធ្ងន់ដាក់ចុះទើបបានស្រាល    ចង់បានកណ្ដាលកុំលំអៀង។
ចេះមកពីរៀនមានពីរក    គ្រប់អស់សត្វលោកពិតមិនទៀង
បើសាងទុច្ចរិតពិតជាឃ្លាង    ក្ដីទុក្ខច្រើនជាងនៅវងចាំ។
ការស្គាល់អ្នកផ្សេងនៅងាយពិត    តែនៅត្រង់ចិត្តយូរខែឆ្នាំ
ស្គាល់បានតែមុខតាមចំណាំ    ឯទង្វើកម្មស្គាល់មិនបាន។
ការស្គាល់ព្រៃភ្នំដ៏ច្រើនទៀត    ឬស្គាល់ធម្មជាតិទាំងប៉ុន្មាន
អាចស្គាល់ទាំងអស់មិនខកខាន    និងស្គាល់ខ្លួនប្រាណបានងាយទេ។
រៀនស្គាល់ខ្លួនឯងមិនងាយសោះ    ខ្លះក្បត់ខ្លះស្មោះឥតទំនេរ
ដូច្នេះរឿងនេះគួររិះរេ    ទាំងយើងទាំងគេដោយប្រាជ្ញា។
ពាក្យថាស្គាល់ខ្លួនបានដល់ចិត្ត    ដែលតែងប្រព្រឹត្តពីរប្រការ
ទីមួយប្រព្រឹត្តអនាចារ    ដែលព្រះទេសនាឱ្យវៀរចាក។
ទីពីរបានដល់ការធ្វើល្អ    គប្បីត្រេកអរធ្វើកុំស្រាក
ព្រោះមានកុសលជាវិបាក    គួរកុំឆ្ងាយចាកចូរខំប្រឹង។


www.elibraryofcambodia.org

គ្រប់ជាតិជាមនុស្សដែលកើតមក រស់នៅក្នុងលោកត្រូវតែដឹង
អំពើបាបបុណ្យចេះថ្លៃងថ្លឹង បើល្ងង់ម្ល៉ឹងៗត្រូវរៀនសូត្រ។
ម្យ៉ាងទៀតស្គាល់ខ្លួនគឺកំណើត ដែលខ្លួនបានកើតសុខរហូត
គិតហើយគិតទៀតកុំរបូត តាំងពីប្រសូតដល់ពេលស្លាប់។
ស្គាល់ថាខ្លួនឯងមកពីណា រស់នៅទីណាយូរឬឆាប់
ត្រូវធ្វើអ្វីមុនដែលប្រញាប់ រស់គោរពច្បាប់ឬមួយអត់។
ឥឡូវខ្លួនមានឬមួយក្រ អាក្រក់ឬល្អចូរកំណត់
កុំចេះតែធ្វើនរកកត់ ព្រោះតែចិត្តក្បត់ពីខ្លួនឯង។
រៀបរាប់មកនេះចង់ឱ្យល្អ រស់តាមព្រះធម៌ព្រះសម្តែង
កុំឱ្យតែលតោលប្រៀបដូចផ្សែង រៀនស្គាល់ខ្លួនឯងទើបស្ងប់ហោង។

*សូមអនុមោទនា!*

**ដោយសាមណេរ សា ចាន់រ៉ាត់**

**អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ**
**សុទន្តោ វត ទមេថ អត្តា ហិ កិរ ទុទ្ទមោ ។**

បុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឱ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មានបានពេកណាស់។ (**អត្តវគ្គទី ១២ បិដកលេខ៥២**)


www.elibraryofcambodia.org

# ៤៦-ធំខ្ពស់ហួសញាតិ

រលកធំៗព្រោះខ្យល់បក់បោក សប្បាយរីករាយព្រោះចិត្តស្រឡាញ់
តាំងខ្លួនអ្នកលេងទើបមានឈ្មោះចាញ់ ស្វែងរកម្ហូបឆ្ងាញ់ព្រោះរសតណ្ហា។
ភ្នំស្រែមិនសព្វព្រោះខុសគន្លង រឿងរ៉ាវខុសឆ្គងព្រោះខ្វះប្រាជ្ញា
កូនចៅរឹងត្អឹងសាមាន្យឫស្យា ព្រោះមិនស្តាប់បាទូន្មានប្រដៅ។
រុក្ខជាតិពេលខ្លះស្លាប់ព្រោះមានផ្លែ កូនមិនស្តាប់ម៉ែព្រោះភាពល្ងង់ខ្លៅ
ធ្វើអ្វីតាមចិត្តមិនស្តាប់ញាតិផៅ មានរឿងសោកសៅតាំងបន្ទោសគេ។
ពេលខ្លះបើប្រាប់ចិត្តរឹងមានះ ចិត្តខ្លាំងជាព្រះគ្មានដឹងទិសទេ
ពេលជួបទុក្ខធំទើបខំរិះរេ ស្រវាំរកគេឱ្យជួយអាត្មា។
ជនខ្លះយកញាតិធ្វើជារបង អ្នកខ្លះនោះហោងគេយកបន្លា
កូនខ្លះចិត្តធំច្រើនឥតខាន់ស្លា មិនស្តាប់មេបាព្រោះតាមមិត្តភ័ក្តិ។
រាប់អានដំបូងស្មោះប្រែគ្មានពីរ ពេលបានញាំញីចិត្តជាប់អន្ទាក់
ចាប់ផ្តើមរករឿងវាយកាប់ទាត់ធាក់ ទឹកភ្នែកហូរធ្លាក់ព្រោះមិនស្តាប់ម៉ែ។
កូនប្រុសស្រីខ្លះមករស់ទីផ្សារ ឫកពាហ៊ឺហាភ្លេចញាតិនៅស្រែ
មិនខំធ្វើការសន្សំប្រាក់ខែ រវល់ជាប់ស្នេហ៍ភ្លើងពណ៌ផ្តេសផ្តាស។
ស្តីពីម៉ែឪស្មានកូនគ្រាន់បើ ខំអួតសរសើរប្រាប់អស់ក្មេងចាស់
កូនខ្ញុំឥឡូវមុខមាត់ស្អាតណាស់ ស្តីពីប្រាក់កាសក៏សម្បូរដែរ។



www.elibraryofcambodia.org

កាលនៅស្រុកស្រែខ្មៅមិនសូវស្អាត តែឥឡូវឆ្លាតជុល្លារហូរហែ
ដឹងអីកូនគាត់ជាប់ប្រុសមានស្នេហ៍ សូម្បីប្រាក់ខែក៏លែងជូនញាតិ។
ម៉ែឪឯណោះខំរំពឹងថា កូនវិលកាលណាលែងលំបាកទៀត
តាមពិតកូនគាត់គំនិតចោលម្សៀត ពពោះចង្អៀតឱ្យម៉ែដុតភ្លើង។
រីឯកូនប្រុសគាត់ក៏ដូចគ្នា គំនិតពាលាថែមចិត្តទំនើង
ស្លីប្រាប់ឯត្បូងទៅធ្វើងជើង សក់វែងសឹងម៉ុងដឹងកាត់ទៅណា។
កូនប្រភេទនេះធំខ្ពស់ហួសញាតិ កើតមកចង្អៀតនៅក្នុងលោកា
ពេលស្លាប់ទៅវិញពិតជាសោកា មិនដឹងថ្ងៃណាកើតជាមនុស្សឡើយ។
សម្តែងមកនេះមិនមែនទាំងអស់ តិចតួចប៉ុណ្ណោះដូចអ្នកជ្រាបហើយ
គ្រាន់តែជាស់តឿនព្រែងលោចានស្បើយ បើខុសលោកអើយសូមអភ័យទោស។
តទៅជាតិមុខសូមកុំមានពៀរ ជូនបុណ្យគ្រប់គ្នាទាំងស្រីទាំងប្រុស
ពិសេសអ្នកស្តាប់អស់លោកសប្បុរស សូមរួចរំដោះទុក្ខសោកទៅហោង។

*សូមអនុមោទនា!*

**ដោយសាចណោរ សា ចាន់រ៉ាត់**

**អត្តនត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ**
**អត្តនត្ថមភិញ្ញាយ សទត្ថបសុតោ សិយា ។**

បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឱ្យវិនាស ព្រោះអាស្រ័យប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន (នោះ) ។(អត្តវគ្គទី១២ បិថកលេខ៥២)



www.elibraryofcambodia.org

## ៤៧.ក្មេងទាន់សម័យ

ក្មេងទាន់សម័យ ស្លាប់ច្រើនពេកក្រៃ ព្រោះគំនិតផ្តាស
មិនយល់ការពិត សាងទុច្ចរិតក្រាស់ ឬមិនស្តាប់ចាស់
ទូន្មានប្រដៅ។

ឱ្យទៅសាលា មុខមិនស្រស់ថ្លា ក្នុងចិត្តសោកសៅ
មិនសូវស្តាប់ម៉ែ តែជឿអ្នកក្រៅ ឱ្យតែគេហៅ
ទៅមិនដែលខាន។

រីឯការងារ មិនខំស្ទុះស្ទា រៀបចំប៉ុន្មាន
មួយថ្ងៃៗ ខំតែងតែប្រាណ ខ្លួនធំថ្មើម៉ាន
ទារប្រពន្ធប្តី។

មើលចុះស្លៀកពាក់ ឃើញហើយចង់ញាក់ ស្មើរភ្លឹកស្មារតី
ស្លៀកពាក់ខើចស្តើង បង្ហាញសាច់ខ្ចី គ្មានចេះធ្វើអ្វី
ស្អាតតែរាងរៅ។

មើលទៅបូកពា ម៉ូកម្ញក់លីលា គំនិតមិនជ្រៅ
ចេញដើរម្តងៗ ស្លៀកខើចដល់ភ្លៅ រៀនគិតមើលទៅ
ក្រែងខ្ញុំពោលខុស។



www.elibraryofcambodia.org

ក្មេងសម័យដើម គំនិតល្អផ្ញើម ទាំងស្រីទាំងប្រុស
គេធ្វើល្អច្រើន មានចិត្តសន្តោស ដឹងត្រូវដឹងខុស
ផ្សេងពីឥឡូវ។

ពីដើមធ្វើអ្វី តែងគិតរំពៃ គំនិតគេជ្រៅ
រៀនបានតិចមែន មិនចេះតែទៅ ចិត្តមិនឃោរឃៅ
សុភាពរាបសា។

ឥឡូវប្លែកណាស់ ក្មេងធំជាងចាស់ ចិត្តខ្មៅឫស្យា
ធ្វើអ្វីតាមចិត្ត គ្មានស្តាប់នរណា សង្គមសោកា
ព្រោះក្មេងអប្រិយ។

បើសិននិយាយ មាយាទន់ជ្រាយ មិនសមគប្បី
ចេញដើរក្មេងក្អាង ចិត្តធំពេញដី មិត្តភ័ក្តិប្រុសស្រី
គ្មានដឹងបាបបុណ្យ។

ប្អូនៗជាន់ក្រោយ ចូរកុំបណ្តោយ កុំសាងទារុណ
ត្រូវភ្ញាក់ខ្លួនឡើង ខិតខំសាងគុណ អ្នកកុំរែកពុន
ពូជអបាយឡើយ។

*សូមអនុមោទនា!*

**ដោយសាមណេរ សា ចាន់រ៉ាត់**


www.elibraryofcambodia.org

## ៤៨.ទឹកស្នាមញញឹម

ស្វរិយាបំភ្លឺលើផែនដី ត្រាច់តាមវិថីរបស់ខ្លួន
ដំណើរយឺតៗតែមាំមួន មើលទៅសមសួនពិតអស្ចារ្យ។
រីឯព្រះចន្ទក៏ដូចគ្នា រះលើមេឃាពន្លឺថ្លា
គួរឱ្យគយគន់គ្រប់នេត្រា ជួបហើយកាលណាតែងលួចស្នេហ៍។
យ៉ាងណាទឹកចិត្តអ្នកមានគុណ ចិត្តខ្ពស់សែនធ្ងន់គឺពុកម៉ែ
លោកបង្កើតកូនបីថ្នមថែ រៀងរាល់ថ្ងៃខែគ្មានចន្លោះ។
កូនកើតមកភ្លាមជាទារក ដុសលាងជញ្ជក់កូនដោយស្មោះ
មិនមានខ្ពើមល្អើមមុខស្រស់បស់ ឱ្យកូនចៅដោះរៀងរាល់ថ្ងៃ។
កូនបើកភ្នែកហើយឃើញព្រះភ័ក្ត្រ មុខម៉ែល្អជាក់ស្រស់ចរណៃ
ញញឹមរកកូនទាំងយប់ថ្ងៃ បីថ្នមផ្ទាល់ដៃលើកកូនភ្លា។
ចំណីអាហារមានសព្វមុខ លោករៀបចំទុករាល់វេលា
បញ្ចុកកូនតូចស្រស់ពុំងា ឱ្យមានជន្មាដល់ពេញវ័យ។
ឃើញស្នាមញញឹមកូនបានស្បើយ ពុកម៉ែនេះហើយកូនមានន័យ
តាំងពីកូនកើតមិនដែលភ័យ លោកចេះលកលៃទាំងចិត្តកាយ។
ពីតូចជួបជុំក្រុមគ្រួសារ កូនធំកាលណាឃ្លាតមកឆ្ងាយ
ឃ្លាតពីបងប្អូនព្រាត់ពីម្តាយ ចិត្តកូនខ្វល់ខ្វាយគិតអ្នកណាស់។


www.elibraryofcambodia.org

នឹកស្នាមញញឹមដ៏ស្រស់ស្អាត    គំនិតវៃឆ្លាតម៉ែពុកចាស់
ស្ម័គ្រស្មោះនឹងកូនមិនប្រែផ្លាស់    សមដូចពាក្យចាស់ថាព្រះព្រហ្ម។
ម៉ែអើយពុកអើយកូនសែនស្ដាយ    ឥឡូវឃ្លាតឆ្ងាយអ្នកភិរម្យ
ពេលនឹកដល់អ្នកចិត្តទូញយំ    ពីតូចដល់ធំឥតឃ្លាងឃ្លាត។
ក្នុងរាត្រីខ្លះកូនស្រមៃ    ឃើញអ្នកម្ដាយថ្លៃចិត្តចង្អៀត
ក្នុងយប់បន្ទាប់ឃើញពុកទៀត    ចិត្តមិនរវាតនឹកអ្នកណាស់។
ណាមួយព្រួយចិត្តមិននៅក្បែរ    រស់ឆ្ងាយពុកម៉ែមានវ័យចាស់
កាយកូនសុខមែនចិត្តទុក្ខក្រាស់    ឈឺគ្មានថ្ងៃសះពីចិត្តនឹក។
យប់នឹកស្រមៃថ្ងៃកូនគិត    បួងសួងក្នុងចិត្តទាំងល្ងាចព្រឹក
សូមឱ្យម្ដាយខ្ញុំសុខសន្តិក    ដោយចិត្តកូននឹករតនត្រ័យ។
សូមបុណ្យទាំងឡាយកូនបានសាង    ធ្វើជាភស្តុតាងគ្មានសង្ស័យ
ជូនពុកជូនម៉ែកុំមានថ្ងៃ    ឧបទ្រពចង្រៃកុំបីមាន។
សូមឱ្យអាយុជាងរយឆ្នាំ    រួចពីបាបកម្មធ្វើចេះធ្វើទាន
តទៅជាតិមុខកុំអត់ឃ្លាន    លុះដល់និព្វានកុំបីខាន។
ពិសេសលោកអ្នកដែលបានស្លាប់    សូមឱ្យរួចឆាប់ទុក្ខក្នុងប្រាណ
សូមបានកុសលទាំងប៉ុន្មាន    ដល់អមតៈស្ថានគឺនិព្វាន។

*សូមអនុមោទនា !!!*

**ដោយសាចណេរ សា ចាន់រ៉ាត់**


www.elibraryofcambodia.org

# ៤៩.ឆាកល្ខោនជីវិត

រឿងភាគសម្ដែងបង្ហាញឈុតឆាក សប្បាយលំបាកជួបព្រាត់រងរ៉ៃ
ស្រេចលើអ្នកតែងលៃលកបំភ្លៃ រៀបចំអត្ថន័យហាក់ដូចរឿងពិត។
រឿងខ្លះសម្ដែងកម្សត់អន់ក្រ រស់ទាំងត្រដរព្រាត់ប្រាសស្នេហ៍ស្និទ្ធ
ខ្លះជាសេដ្ឋីជាស្ដេចយ៉ាងពិត ខ្លះក៏ជាមិត្តខ្លះបម្រើគេ។
ក្នុងរឿងមួយៗតែងមានវែងខ្លី មានប្រុសមានស្រីច្រើនគ្រប់កាំភ្លេ
ខ្លះដើរតួកាចត្រូវបានគេជេរ តួស្លូតទំនេរគេតែងអាណិត។
វីតួខ្លះទៀតផ្សៀតដើរតួចក្សត់ ខ្លះធ្វើកម្សត់ខំថ្លៃប្រឌិត
ធ្វើក្លែងក្លាយសោះហាក់ដូចជាពិត អ្នកមើលខ្លោចចិត្តអ្នកខ្លះសោកា។
តួអ្នកសម្ដែងគេដឹងទាំងអស់ មិនមានចន្លោះយល់សព្វកិច្ចការ
ព្រោះមានអ្នកប្រាប់អ្នកតែងស្ដីថា សាកសមអស្ចារ្យដូចរឿងពិតៗ។
នេះគឺរឿងល្ខោនដែលគេតាក់តែង ហើយរៀបសម្ដែងប្រាប់ពីជីវិត
ត្រៀមហើយដើរតួមើលទៅជិតស្និទ្ធ ខ្លះគេឱបរឹតយ៉ាងសមសោភា។
យ៉ាងណាជីវិតទាំងអស់ប្រុសស្រី កើតក្នុងលោកិយក៏មានដូចគ្នា
មានជួបមានព្រាត់ខ្លះក៏កំព្រា លំបាកវេទនាគ្មានដែលលោះថ្ងៃ។
រឿងរ៉ាវឧបសគ្គមានគ្រប់កន្លែង វិលវល់ដូចផ្សេងទុក្ខសោកពេកក្រៃ
ទឹកភ្នែកស្រក់ហូរគ្មានដែលសំចៃ ឧបទ្រពចង្រៃគ្មានស្រាកម្ដងណា។



www.elibraryofcambodia.org

នេះហើយបញ្ហាក្ដីនៃយើងគ្រប់ប្រាណ មិនយូរប៉ុន្មានត្រូវចោលឥតការណ៍

រស់នៅសុខៗត្រូវស្លាប់មរណា ចោលស្រែចម្ការផ្ទះប្រពន្ធប្ដី។

ជីវិតប្រៀបដូចជាការសម្ដែង រៀបចំចាត់ចែងនៅក្នុងភពបី

អ្នកតែងតិកម្មគ្មានត្រាប្រណី អ្នកក្រសេដ្ឋីចាត់មិនរើសមុខ។

ពេលខ្លះឱ្យធំមានបុណ្យសក្ដិយស ឋានៈខ្ពង់ខ្ពស់ខ្លះដូចជាប់គុក

ពេលខ្លះឱ្យសុខខ្លះក៏ឱ្យទុក្ខ ខ្លះជួបនឹពុកព្រាត់ប្រាសពីម៉ែ។

ខ្លះស្លាប់ពីក្មេងខ្លះរស់ដល់ចាស់ ខ្លះមានប្រាក់កាសចាយជាហូរហែ

ខ្លះនៅទីក្រុងអ្នកខ្លះនៅស្រែ ខ្លះទុក្ខឥតល្ហែអ្នកខ្លះសុខសាន្ត។

តាមពិតជីវិតបីដូចឆាកល្ខោន ប្រសើរអាប់ឱនមានគ្រប់សព្វប្រាណ

បើខ្លួនបានខ្ពស់សាងគុណកុំខាន រៀងចប់ថ្មើមានបានបុណ្យជាគ្នា។

បើខ្លួននៅក្រឱ្យក្រទៅចុះ ឱ្យតែចិត្តស្មោះព្រមស្ដាប់ធម្មា

គង់មានថ្ងៃមួយអាចរួចចាកពៀរ ឡើងជិះនាវាផុតទុក្ខវិបរិត។

អស់លោកសប្បុរសជាទីស្នេហា ស្ដាប់គិតចុះណាឆាកល្ខោនជីវិត

កុំលង់ចាញ់បោកកិលេសនៃបនិត្យ ចូរស្ដាប់ធម៌ពិតនៃព្រះជិនស្រី។

*សូមអនុមោទនា !!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ៥០-កូនឥតខាន់ស្លា

ទឹកនៅក្នុងស្ទឹងរលកខ្យល់បក់ រឿងរ៉ាវអាក្រក់កើតពីទង្វើ
ធ្វើអ្វីខុសឆ្គងព្រោះល្ងង់ល្ងើ បានក្រោមខ្វះលើព្រោះលោភជាន់ក។
ថ្ងៃឃើញសូរិយារះលើមេឃា យប់ក្រោមឃើញចន្ទ្រារះជាលម្អ
ជីវិតលំបាកព្រោះគ្មានរបរ ធ្វើអ្នកកំដរតែងត្រូវគេថា។
ចាំចុះពូជស្រូវគេបានពីស្រែ កូនមិនស្តាប់ម៉ែច្រើនឥតខាន់ស្លា
ក្បត់ប្រពៃណីព្រោះតែតណ្ហា ល្ងចមានសង្សារហួសញាតិប្រដៅ។
មើលសក់ក្រហមឬវែងហាយឡាយ ហិចហើរសប្បាយដូចក្អែកតាវៅ
ការងារថ្ងៃច័ន្ទថាចាំថ្ងៃសៅរ៍ មុខមាត់លាបម្សៅត្រាំឡេសថ្លា។
បើរាប់សង្សារប្រហែលមួយតៅ មិត្តភ័ក្តិក្នុងក្រៅដឹងមកពីណា
យប់ឡើងដើរលេងស៊ីផឹកតាមបា ស្រែកច្រៀងឡូឡាខានគេឯង។
បើជិះម៉ូតូជ្រេពេញតែផ្លូវ ក្មេងខ្លះសក់ស្កូវគេលាបចាត់ចែង
ស្រវឹងម្តងៗស្រែកហៅក្តែងៗ ភ្លេចអស់ខ្លួនឯងថាជាស្រីខ្មែរ។
ស្តីពីគ្រួសារមិនសូវធូរធា មើលចុះឫកពាដូចសេដ្ឋីដែរ
ឯផ្ទះតូចមួយសង់ជាហួរហែ ឬនៅក្បែរៗផ្លូវគួរសង្វេគ។
មនុស្សខ្វះមាយាទដូចស្រូវខ្វះទឹក ធ្វើតាមចិត្តនឹកចង់តាមតម្រេក
មិនអាណិតម៉ែពុកខំទូលរែក យប់ថ្ងៃអត់ដេកព្រោះកូនប្រុសស្រី។



www.elibraryofcambodia.org

មិនអាណិតម៉ែគួរស្រណោះខ្លួន　　មិនគួរជាប់ជួនហួសញាតិពោលស្ដី
ក្នុងការរកគូគីប្រពន្ធប្ដី　　គួរណាស់តែស្រីស្ដាប់លោកមេបា។
បើសិនជាខុសមានគេដឹងឮ　　កូនខ្លះបញ្ឈឺឱ្យម៉ែសោកា
ពេលគេបោកចិត្តស្រក់ទឹកនេត្រា　　ម៉ែឪស្ដីថាអាងសម្លាប់ខ្លួន។
ពាក្យចាស់លោកពោលកូនឥតខាន់ស្លា　　មិនស្ដាប់មេបាស៊ីលាក់បំពួន
ច្រើនតែរងកម្មទឹកភ្នែកផ្ទួនៗ　　កូនគ្រប់ចំនួនទើបបានរៀបការ។
ដូច្នេះបងប្អូនជាតិខ្មែរទាំងឡាយ　　ចូរកុំសប្បាយធ្វើតាមតណ្ហា
គួរតែកែខ្លួនតាមពង្សាវតា　　ដែលធ្លាប់ល្បីថាពូជខ្មែរថ្កើងថ្កាន។
រៀបរាប់មកនេះមិនមែនមើលងាយ　　ឬមួយពេបជ្រាយបៀតបៀនខ្លួនប្រាណ
មិនបានតិះដៀលស្ដីថាសន្ដាន　　គ្រាន់តែចង់បានធ្វើឱ្យសមរម្យ។
ជាចុងបញ្ចប់ខ្ញុំសូមអភ័យ　　អស់លោកប្រុសស្រីទាំងតូចទាំងធំ
តាមក្រុងចម្ការស្រែច្បារនិគម　　សូមកុំខឹងខ្ញុំរៀនគិតចុះណា។
បើខ្ញុំពោលខុសសូមអ្នកត្រូវផ្លូវ　　បើខ្ញុំពោលត្រូវសូមអ្នកភ្ជីថ្វា
បើអ្នកស្អប់ខ្ញុំសូមស្ដាប់មេបា　　ពេលនោះខេមរាជាតិយើងថ្កើងថ្កាន។

*សូមអនុមោទនា!!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

# ៥១. ចិត្តផ្លេកបន្ទោរ

ធម្មជាតិជាស្វានៅមិនស្ងៀម ដៃជើងវវាមគ្មានទំនេរ
ឃើញមនុស្សដើរក្បែរមាត់ប៉ិនជេរ គ្មានដឹងទិសទេជាតិជាស្វា។
និយាយពីគោស៊ីតែស្មៅ ក្នុងចិត្តល្ងង់ខ្លៅគ្មានប្រាជ្ញា
ត្រូវមនុស្សទាក់ខ្នះភ្ជួរចម្ការ ចាស់ខ្លួនកាលណាគេលក់ចេញ។
រីឯចិត្តយើងគ្រប់ៗគ្នា តែលតោលវេរាទុក្ខទោម្នេញ
ដូចផ្លេកបន្ទោរដែលប្រដេញ ក្នុងមេឃរលេញពេលភ្លៀងធ្លាក់។
ខណៈនៃចិត្តដឹងមិនទាន់ ស្លាប់កើតរយពាន់ជាច្រើនវគ្គ
ពេលដឹងអារម្មណ៍ជាប់ជំពាក់ កិលេសក៏ទាក់នៅក្នុងចិត្ត។
ម្យ៉ាងទៀតចិត្តនេះតែងសន្សំ ពពួកអារម្មណ៍ល្អប្រណីត
អារម្មណ៍ថ្ងាំងថ្នាក់ទុក្ខពិតៗ ក៏ក្នុងគំនិតតែងទន់ទោ។
ធម្មជាតិនៃចិត្តមិនទៀងទាត់ ប្រៀបដូចបន្ទាត់ផ្លេកបន្ទោរ
ខ្លះលិចក្នុងបាបខ្លះបុណ្យទ្រ ខ្លះលង់ក្នុងមោហ៍គ្មានរួចខ្លួន។
ចង់ឱ្យចិត្តស្ងប់ឬបានឈ្នះ ត្រូវស្តាប់ធម៌ព្រះឱ្យមាំមួន
ស្តាប់ដោយប្រយ័ត្នអានតាមក្បួន ទើបបានគាប់ជួនសុខពិតហោង។

*សូមអនុមោទនា!!!*

ដោយសាចណោរ សា ចាន់រ៉ាត់



www.elibraryofcambodia.org

# ៥២-មនុស្សបានតែមាត់

សម្ដីរួសរាយ មុខស្រស់ពព្រាយ គួរឱ្យស្នេហា
និយាយម្ដងៗ ហាក់ដូចអស្ចារ្យ ស្ដាប់យូរកាលណា
រឹតតែទុកចិត្ត។

គេស្ដីថ្នមស្រាល ជាហេតុបណ្ដាល ឱ្យលង់គំនិត
ចាប់ផ្ដើមស្ដាប់ហើយ កាន់តែជិតស្និទ្ធ រស់ជុំយូរពិត
ទើបដឹងសម្ដី។

ស្ដាប់ព្ទវាចា ចង់ឃើញភ័ក្ត្រា ដ៏ស្រស់ប្រិមប្រិយ
អន្ទង់អន្ទោច ស្មើរភ្លឹកស្មារតី ទាំងប្រុសទាំងស្រី
ចាប់ចិត្តស្នេហា។

ឮពាក្យរ៉ាយរ៉ាប់ ស្ដីតាមទូរស័ព្ទ ដូចសារិកា
ឮតាមវិទ្យុ ផ្ដោះផ្ដងចរចា ខ្លះលួចពោលថា
ខ្ញាញ់ណាស់ណោកអើយ។

អ្នកខ្លះគេឆាប់ ស្នេហ៍តាមទូរស័ព្ទ សាកសួរចម្លើយ
មិនយូរប៉ុន្មាន រួមរស់គៀកគើយ ខ្លះលង់ខ្លួនហើយ
ទើបបានរៀបការ។



www.elibraryofcambodia.org

ខ្លះជួបហើយព្រាត់ ចិត្តមិនទៀងទាត់ បោកប្រាសស្នេហា
បានខ្លួនបានប្រាណ ក្បត់អនុសារ អ្នកខ្លះសោកា
បន្សល់កូនតូច។

ស្នេហ៍កាំរន្ធះ ឮហើយរួតរះ ចង់គ្មានអ្វីដូច
ខ្លះថាមិនបាន សតិស្មើរខូច ខ្លះយំអេចអួច
ទារប្រពន្ធប្តី។

នេះព្រោះគិតភ្លាត់ ស្អាតតែមុខមាត់ ល្អតែសម្តី
រូបរាងសមរម្យ ដួងចិត្តអប្រិយ បោកចិត្តស្រីៗ
ឱ្យនាងគ្រាំគ្រា។

នេះគ្រាន់តែថា រៀនគិតចុះណា មិនបាននិន្ទា
កុំចេះតែជឿ វាទៈនានា ព្រោះមនុស្សគ្រប់គ្នា
ទុកចិត្តមិនបាន។

*សូមអនុមោទនា!!!*

**ដោយសាចណោរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ៥៣-ខ្ញុំសូមអង្វរ

គយគន់ព្រឹក្សាធម្មជាតិព្រៃភ្នំ សមុទ្រសែនធំដាច់កន្ទុយភ្នែក
ទេសភាពវាលស្រែស្រស់ល្អចំឡែក សត្វច្រើនអនេកគួរឱ្យស្នេហា។
មនុស្សមីដេរដាសគ្រប់ទីកន្លែង ហួសនឹងថ្លាថ្លែងគ្រប់ជាតិណា១
ម្នាក់១ខំណាស់ប្រកបកិច្ចការ ចិញ្ចឹមអាត្មាប្រាថ្នាចង់សុខ។
ឆ្លៀតពេលទំនេរពីការសិក្សា គិតតែងអក្សរាខំទាំងសម្រុក
សរសេររៀបរាប់ទាំងចិត្តស្មាញស្មុគ ជូនញាតិគ្រប់ស្រុកគ្រាន់ពិចារណា។
តាមពិតពាក្យនេះខ្ញុំតែងអង្វរ សូមសេចក្ដីល្អជូនជាតិខេមរា
កុំឱ្យមានទុក្ខស្គាល់តែសុខា ជួបជុំគ្រួសារកុំឱ្យមានហ្មង។
សូមអស់ម្ចាស់ស្រុកបាតស្ដឹងសង្កែ ខិតខំមើលថែក្រុងបាត់ដំបង
ទោះស្លាប់ថ្មី១ឬយូរកន្លង ភូមិកំពង់ឆ្នាំងស្របតាមមាត់ស្ទឹង។
សូមភ្នំដងរែកថែព្រំសីមា ប្រាសាទដូនតាឈរស្រស់យ៉ាងរឹង
សូមឱ្យប៉ៃលិនអ្នកខិតខំប្រឹង ហោយប៉ែតត្រូវដឹងច្រកធំខេមរា។
ឥឡូវភ្នំពេញមើលទៅស្រស់ស្អាត សូមមនុស្សខ្មែរឆ្លាតគ្រប់១អាត្មា
ចាស់មានធម៌ព្រះក្មេងមានប្រាថ្នា រស់ចេះមេត្តាដល់គ្នានិងគ្នា។
សូមភ្នំគូលេនអ្នកមានបារមី ម្ចាស់ទឹកម្ចាស់ដីសូមរំដោះពៀរ


www.elibraryofcambodia.org

ស្រុកមោងឫស្សីថ្មគោលវាលទ្រា ស្លាកែតនរាសូមជួយដឹងឮ។
ដោយចិត្តនឹកដល់ព្រះរតនត្រ័យ សូមឱ្យចង្រៃរោគាជម្ងឺ
ជៀសចេញឱ្យឆ្ងាយអន្តរាយនោះគឺ ជួបតែពន្លឺព្រះពុទ្ធសាសនា។
អ្នកតាបាណន់ម្ចាស់ភ្នំសំពៅ និងម្ចាស់អូរជ្រៅអ្នកភូមិផ្កាស្លា
សូមជួយគ្រប់គ្រងកូនចៅផងណា ទាំងក្រុងចម្ការព្រៃឈើវាលស្រែ។
វព្វកនឹកឃើញអាងកំពីងពួយ សូមឱ្យលោកជួយបីបមថ្នមថែ
ឃុំអូរតាគីភូមិពពាលខែ ម្ចាស់ស្រុកសង្កែសូមប្រសិទ្ធិ។
សេកសកអូរដារព្រៃភ្នំទឹកជ្រោះ សូមជួយដោះគ្រោះទុក្ខសោកញាំញី
អ្នកថៃទឹកដីម្ចាស់វត្តសូភី វត្តពោធិ៍ទាំងពីរសូមជួយថ្នមបី។
សូមនឹកដល់គ្រូលោកអ្នកមានគុណ សូមរួចទារុណទាំងប្រុសទាំងស្រី
ជួបតែក្តីសុខស្រួលប្រពន្ធប្តី ហើយមានស្មារតីស្រឡាញ់ធម៌អាថ៌។
នេះគឺគ្រាន់តែការគិតស្រមៃ ធ្វើបុណ្យរាល់ថ្ងៃក្នុងចិត្តជ្រះថ្លា
សូមជូនបងប្អូនគ្រប់ជនខេមរា សូមបានសុខាលុះនិព្វានហោង។

*សូមអនុមោទនា!!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ៥៤. អាណិតព្រះសង្ឃ

*សង្ឃជាសាវ័កនៃព្រះពុទ្ធ* | *ខ្ពង់ខ្ពស់បំផុតពីរប្រការ*
បង្គំនឹកគុណដោយជ្រះថ្លា | សូមឱនសិរសាដោយគោរព។
ព្រះសង្ឃអ្នកបួសលះបង់ផ្ទះ | បួសរៀនធម៌ព្រះទាំងថ្ងៃយប់
បាបកម្មទាំងឡាយលោកបញ្ឈប់ | ជ្រោកក្រោមតែម្លប់រតនត្រ័យ។
ព្រះសង្ឃមកពីទីផ្សេងគ្នា | ព្រមស្តាប់ធម្មាគ្មានសង្ស័យ
*លះកាត់តណ្ហាឱ្យក្សិណក្ស័យ* | *អាសវៈចង្រៃកុំឱ្យមាន។*
ព្រះសង្ឃបួសហើយព្យាយាមណាស់ | ស្តាប់ពុទ្ធតម្រាស់ព្រះទ្រង់ញាណ
ថ្ងៃលោកស្តាប់ធម៌យប់ខំរៀន | ព្រមទាំងទូន្មានកាយវាចា។
ពេលខ្លះព្រះសង្ឃសែនវេទនា | ត្រូវគេនិន្ទាឬស្តីថា
បុគ្គលខុសសោះពោលមុសា | នាំមានបញ្ហាដល់ព្រះសង្ឃ។
មានជនទុច្ចរិតជំពូកខ្លះ | ប្រព្រឹត្តផ្ដេសផ្ដាសដើរគ្មានបង្ហ
ពោលបញ្ឆោតលោកជាព្រះសង្ឃ | បព្វជិតគ្រប់ព្រះអង្គឱ្យអន្តរាយ។
ព្រះសង្ឃលោកខំសង្រួមណាស់ | រៀនបិដកក្រាស់ខំរាល់កាយ
យប់ឆាន់តែទឹកព្រឹកឆាន់បាយ | ចិត្តមិនខ្វល់ខ្វាយសែនប្រសើរ។
គ្រហស្ថពួកខ្លះគំនិតថោក | ឱ្យលោកចាញ់បោកគឺគេប្រើ
យកលោកធ្វើឈ្នាន់គ្រាន់ជាន់ដើរ | ឬជាជណ្ដើរគេជាន់ឆ្លង។


www.elibraryofcambodia.org

ព្រះសង្ឃស្មោះណាស់នឹងសាសនា ឃ្លាតឆ្ងាយមាតានិងប្អូនបង
រៀនធម៌ព្រះពុទ្ធល្អឥតហ្មង ព្រះសង្ឃចងក្រងជាបិដក។
អាណិតព្រះសង្ឃអង្គសាមណេរ មិនដែលខ្ជិលទេខំតក់ៗ
លោកលះបង់ហើយខោអាវសក់ អំពើអាក្រក់លោកជៀសវាង។
បពិត្រអស់លោកជាសប្បុរស ក្មេងចាស់ទាំងអស់ចូរកុំឃ្លាង
អំពីគុណសង្ឃលោកធំជាង សូមអស់អ្នកនាងកុំប្រមាទ។
បើសិនមិនយល់ពិតខកប្រាណ រស់មិនសុខសាន្តបុណ្យនោះខាត
កាយវាចាចិត្តក៏មិនស្អាត ធ្លាក់វិនិបាតច្រើនខែឆ្នាំ។
ម្យ៉ាងទៀតព្រះសង្ឃរៀនធម៌អាថ៌ បន្តសាសនាជាប្រចាំ
សូម្បីព្រះពុទ្ធក៏ទ្រង់ផ្តាំ ធម៌ដូចជាថ្នាំសង្ឃមើលថែ។
បើសិនអស់លោកបានយល់ហើយ គួរកុំកន្តើយគួរណាស់តែ
ធ្វើបុណ្យកុសលរាល់ថ្ងៃខែ នឹកគុណផងដែរព្រះសង្ឃថ្លៃ។
បូជាព្រះសង្ឃបានធនធាន បានដល់និព្វានគ្មានសង្ស័យ
ឬសូមនឹកឃើញរតនត្រ័យ សូមអាសវៈក្ស័យសុខទៅហោង។

*សូមអនុមោទនា!!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ៥៥-គ្រាន់តែប្រាប់ទេ!

រៀបរាប់ស្ដីប្រាប់ ឱ្យត្រូវតាមច្បាប់ កុំខុសតម្រា
ព្រមស្ដាប់គេខ្លះ ទើបកើតប្រាជ្ញា បើខ្ជិលកាលណា
ភាពល្ងង់ជាន់ក។

ពេលបានស្ដាប់គេ ត្រូវគិតរិះរេ ស្វែងរកផ្លូវល្អ
កុំចេះតែជឿ ព្រោះពួត១ សង្កេតបន្ត
ទើបច្បាស់ហេតុការណ៍។

រឿងរ៉ាវសព្វគ្រប់ កើតមិនដែលឈប់ មានរាល់កាយា
ខ្លះត្រូវគេស្ដី បន្ទោសឡូឡា ខ្លះយំសោកា
ព្រោះពាក្យនិន្ទា។

ខ្លះពេលគេប្រាប់ មុខបែរទ្រង់យ៉ាប់ រឹងត្អឹងពាលា
គេជួយខ្លួនសោះ ថាគេផ្ដន្ទា មិនចេះស្ដាប់គ្នា
ទៅជារឿងក្ដី។

ម្នាក់ថាម្នាក់ខឹង តើទាំងពីរហ្នឹង មានគ្រាន់បើស្អី
បានត្រឹមរឿងរ៉ាវ ឈ្លោះប្រកែកស្ដី ព្រោះគំនិតខ្វី
មិនស្ដាប់គេខ្លះ។



www.elibraryofcambodia.org

អ្នកខ្លះក្មេងក្អាង ពិតទ្រូងសំអាង ថាខ្លួនអញចាស់
ឯងនៅក្មេងទេ កុំពោលតែផ្តាស អញយល់ច្បាស់ណាស់
ឬដឹងអស់ហើយ។

គ្រាន់តែស្តីថា មានៈអស្ចារ្យ ពោលប្រាប់ចម្លើយ
អាងគ្មានគោលដៅ ឬកធំកន្តើយ គ្មានល្ងង់ម្តងឡើយ
ចេះគ្មានគេកោត។

បើត្រូវមិនថា ឬពោលចរចា មិនចេះតែចោទ
តាមពិតឃើញខុស គំនិតអ្នកឆោត ទាំងត្រូវនោះសោត
គួរណាស់ស្តាប់គេ។

ខ្ញុំសូមអភ័យ រាល់អត្ថន័យ មិនបានស្តីជេរ
គ្រាន់តែពោលប្រាប់ គ្រាន់គិតរិះរេ ចង់ឱ្យល្អទេ
អស់លោកអ្នកអើយ។

*សូមអនុមោទនា!!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ៥៦-ខ្ញុំគ្មានអ្វីទេ

ធម្មជាតិជាភ្លើងមិនឆ្អែតដោយឧស  រីឯកំហុសមិនស្កប់ជនពាល
តណ្ហាកើតឡើងនាំក្តៅរោលរាល  ថ្ងៃជ្រេរសៀលគង់តែលិចបាត់។
អ្នកមានទ្រព្យធនចូលចិត្តហ៊ឺហា  អ្នកស្តាប់ធម៌អាថ៌ចូលចិត្តទីស្ងាត់
ខ្យល់បក់ទឹកគួចទើបបានរសាត់  ខ្ចីព្រោះតែកាត់មិនតឱ្យវែង។
បានមិនចេះគ្រប់ព្រោះលោភក្នុងចិត្ត  ភ្នែករងស្តមពិតព្រោះមិនបានគេង
ចង់ឈ្នះចាញ់គ្នាត្រូវតែប្រជែង  ចង់ផុតវង្វេងត្រូវរៀនធម៌អាថ៌។
សង្ខារទាំងឡាយកើតហើយរលត់  ជួបហើយប្រាសព្រាត់រឿងរាល់រូបា
គេចមិនផុតឡើយនៅក្នុងលោកា  ត្រូវស្លាប់មរណាទៀងប្រាកដណាស់។
តាំងពីកើតមកមានបានសប្បាយ  មិនសូវខ្វល់ខ្វាយពីក្មេងដល់ចាស់
ដល់ពេលស្លាប់ទៅចោលដីស្រឡះ  គ្មានយកបានខ្លះបានតែតួកម្ម។
កើតមកដៃក្តាប់ប្រកាន់កន្លង  ថាលោកនេះហោងនៃខ្ញុំត្រូវចាំ
ដល់ពេលស្លាប់ទៅលាតទាំងឆ្វេងស្តាំ ថែមទាំងផ្ទៀតផ្តាំខ្ញុំគ្មានអ្វីទេ។
ស្តាប់ចុះរឿងនេះទាំងស្រីទាំងប្រុស  អស់លោកសប្បុរសចូរគិតរិះរេ
កុំឱ្យស្លាប់ទៅបាតដៃទទេ  ធ្លាក់ទៅនិរយេឬអបាយជ្រៅ។
ចូរខំធ្វើបុណ្យរក្សាសីលទាន  ដៅផ្តោះនិព្វានផុតទុក្ខអាស្រូវ
កុំឱ្យស្តាយក្រោយថាខ្ញុំខុសផ្លូវ  គិតឱ្យត្រឹមត្រូវពីពេលនេះហោង។

**ដោយលោកលោក សា ចាន់រ៉ាត់**



www.elibraryofcambodia.org

# ៥៧-តើឱ្យពុកម៉ែពឹងលើអ្វីទៅ?

ទូកពឹងច្រវាលើផ្ទៃសាគរ ក្តោងពឹងវាយោបក់បោករសាត់
ទៅកាន់ត្រើយនាយស្វែងរកសម្បត្តិ សុខឬវិបត្តិមានរាល់វេលា។
ពុកម៉ែខ្លួនចាស់នឹកពឹងរកកូន បីដូចជាក្បូនដ៏ល្អសោភា
រស់នៅពឹងកូនចៅគ្រប់អង្គា ក្រែងផុតវេរាពេលខ្លួនចាស់ទៅ។
សេចក្តីប៉ុនប៉ងបានត្រឹមខកចិត្ត កូនចៅមានពិតតែដើរខុសផ្លូវ
ខំចិញ្ចឹមកូនសក់ខ្មៅដល់ស្កូវ តែពេលឥឡូវកូនប្រែក្រឡាស់។
ទ្រព្យធនម៉ែមានចែកកូនមិនស្តាយ ឱ្យរាល់រូបកាយទោះមានឬខ្វះ
ឱ្យតែកូនសុខម៉ែអរខ្លាំងណាស់ ពេលពុកម៉ែចាស់គ្រាន់រស់នៅផង។
ឥឡូវដល់ហើយអ្វីដែលគិតទុក ម៉ែហើយនិងពុកធ្លាក់ខ្លួនសៅហ្មង
ទៅពឹងកូនប្អូនគេឱ្យទៅបង ប្រកែកឆ្លើយឆ្លងឈ្លោះគ្នាវិញ។
ពុកម៉ែកំព្រារស់នៅផ្ទះខ្ទម រាងកាយទ្រុឌទ្រោមព្រួយចិត្តរាល់ថ្ងៃ
ខ្វះម្ហូបអាហារអង្ករត្រីប្រៃ ឱ!កូនម្តាយថ្លៃហេតុអ្វីដូច្នោះ។
ថាកូនស្រីទៅគ្នានៅស្រុកឆ្ងាយ ចុះចៅរាល់កាយហេតុអ្វីគិតខុស
កូនស្រីមិនកើតគួរណាស់តែប្រុស ប្រណីសន្តោសចិញ្ចឹមម៉ែផង។
គេមានផ្ទះថ្មសសរឥដ្ឋធំ ហេតុអ្វីមាសមុំឱ្យម៉ែសៅហ្មង
កូនពៅមិនជាហេតុអ្វីកូនបង ប្រព្រឹត្តកន្លងឱ្យម៉ែកំព្រា។



www.elibraryofcambodia.org

មើលចុះអាហារគេហូបមិនខ្វះ ខោអាវថ្មីចាស់សម្បូណ៌ហូរហៀ
កូនសប្បាយមែនតែម៉ែគ្រាំគ្រា រស់នៅវេទនាស្ទើរបែកឱរ៉ា។
ឱ!កូនសម្លាញ់មាសម្តាយអើយ មិនគួរសោះឡើយគ្មានមេត្តា
ខ្លួនម្តាយចាស់ហើយពឹងនរណា ខោអាវអាហារធ្វើបុណ្យទាន។
បើខ្លួនកូនក្រពុកម៉ែមិនថា កូនមានហ៊ុហាតែម៉ែអត់ឃ្លាន
ចៅក៏ដូចគ្នាសុទ្ធតែអ្នកមាន លុយកាក់រាប់លានគួរតែជួយម៉ែ។
បើកូនសុខហើយម៉ែត្រេកអរណាស់ តែកម្មម៉ែក្រាស់លំបាកឥតល្ហែ
កាលផុតសង្គ្រាមម៉ែខំធ្វើស្រែ រៀងរាល់ថ្ងៃខែពុំសូវទំនេរ។
ស្ដីពីតាវ៉ាគាត់ក៏ខំណាស់ កាប់ព្រៃជីកស្រះទុកគ្រាន់ជាកេរ្តិ៍
ខំតាំងពីព្រឹកថ្ងៃលិចទន់ទេរ ហត្ថាទាំងទ្វេដល់ផ្ទះឱបកូន។
ឥឡូវប្លែកណាស់រស់នៅក្រៀមក្រោះ កូនចៅធំអស់រសាត់ដូចក្បូន
ពីដើមមានណាស់ឥឡូវធ្លាក់សូន្យ មើលចុះដីដូនក៏ធ្លាក់ខ្លួនឈឺ។
ស្ដីពីថ្នាំពេទ្យក៏គ្មានក្នុងផ្ទះ គ្មានទាំងប្រាក់មាសឬក៏ស្រែភ្លឺ
ទៅប្រាប់កូនចៅវាធ្វើមិនឮ រឹតតែបញ្ឈឺពោលស្ដីឡូឡា។
ឱ!កូនសម្លាញ់នៃពុកម៉ែអើយ ម៉ែជិតលាហើយណាកូនកនិដ្ឋា
បើកូនភ្លេចម៉ែពុកក៏មិនថា ម៉ែសូមផ្ដាំថាម្ដងម្នាក់ទេកូន។
ពេលនេះម្ដាយចាស់ជិតស្លាប់ទៅហើយ មិនទាមទារឡើយចូរមើលថៃប្អូន
កុំទាស់ទែងគ្នានាំងធីតសូន្យ ម៉ែសូមលាកូនទៅទាំងអាល័យ។
ឈប់ស្នេះត្រឹមនេះអស់លោកសប្បុរស ក្មេងចាស់ទាំងអស់ច្បាស់គ្មានសង្ស័យ


www.elibraryofcambodia.org

នៅក្នុងលោកនេះក៏ឃើញរាល់ថ្ងៃ ខ្ញុំមិនកាឡៃពោលពាក្យមុសា។
ពុកម៉ែគេផ្សេងក៏ដូចម៉ែខ្ញុំ ឃើញហើយចិត្តយំសង្វេគចិន្តា
នឹកឃើញដូច្នេះទើបតែងអក្ខរា គ្រាន់ពិចារណានៃកូនប្រុសស្រី។
រៀបរាប់មកនេះមិនមែនទាំងអស់ តិចតួចប៉ុណ្ណោះមានចិត្តអប្រិយ
មិនតបគុណគាត់បែរខ្នងធ្វើហី គិតចុះប្រុសស្រីមិនចេះតែថា។
សរសេរមកនេះនៅចុងបញ្ចប់ សូមលើកម្រាមដប់អភ័យទោសា
ក្រែងមានប៉ះពាល់ខុសឆ្គងយ៉ាងណា ខ្ញុំគ្មានចេតនាបៀតបៀនគ្រប់គ្នា។
បើខ្ញុំពោលទៅក្រែងមានកំហុស សូមអស់សប្បុរសគំនិតល្អជា
បើខ្ញុំពោលត្រូវដឹងគុណគ្រប់គ្នា ពុកម៉ែជរាក្នុងផ្ទះនោះឯង។
ប្រការមួយទៀតខំឆ្លៀតជូនបុណ្យ គ្រប់អស់មហាជនសូមភ្ជិចិញ្ចែង
ដោយអំណាចនៃធម៌ព្រះសម្តែង សូមអស់គម្តែងបានសុខសួស្តី។
សូមដឹងគុណឡើងរៀនស្តាប់ធម៌អាថ៌ ចម្រើនប្រាជ្ញាទើបផុតអវិចី
បើបានដឹងហើយចូរអ្នកឃ្នាតខ្មី ចម្រើនបារមីរៀងរាល់វេលា។
បើអ្នកដឹងគុណពុកហើយនិងម៉ែ ថែរាល់ថ្ងៃខែគាត់ចាស់ជរា
ពេលអ្នកស្លាប់ទៅកើតក្នុងសួគ៌ា ផុតទុក្ខនានាលុះនិព្វានហោង។

*សូមអនុមោទនា!!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

# ៦៨-ចូរស្ដីថាវទេចំពោះបាបកម្ម

ឮពាក្យថាទេ ពីរោះម៉្លេះទេ សាកសមអស្ចារ្យ
គឺមិនធ្វើបាប តាមព្រះទេសនា ប្រព្រឹត្តធម៌អាចី
តាមព្រះជិនស្រី។

ការពោលដឹកនាំ ធ្វើបាបភក់ជ្រាំ គួរតែធ្វើហី
កុំប្រព្រឹត្តតាម ទើបមានសិរី មិនធ្លាក់អវិចី
ជួបតែផ្លូវព្រះ។

កាយវាចាចិត្ត ធ្វើឱ្យសុចរិត ទើបយើងបានឈ្នះ
អំពើបាបកម្ម ត្រូវតែខំលះ ម្យ៉ាងគួររូតរះ
សន្សំមគ្គផល។

បុណ្យទុកជាស្ពាន សទ្ធាជាយាន សីលជាផ្លូវថ្នល់
ព្យាយាមខន្តី ស្មារតីតម្កល់ ស្មើបានមគ្គផល
ដល់ទីផុតទុក្ខ។

ទីមួយគឺកាយ ចូរកុំខ្វល់ខ្វាយ សម្លាប់ទៅមុខ
គឺសត្វតូចធំ បៀតបៀនអាយុ គួរណាស់តែទុក
ជីវិតទាំងអស់។



www.elibraryofcambodia.org

ទីពីរកុំលួច របស់តិចតួច កុំធ្វើឱ្យសោះ
អំពើមិនល្អ ជួរចត់ឥតខ្ចោះ ចូរខំរំដោះ
កុំសាងនិរយេ។

ទីបីអ្នកកុំ ទាំងតូចទាំងធំ គឺរឿងកាមេ
កុំលួចស្នេហ៍ស្និទ្ធ ប្រពន្ធកូនគេ ចូរអ្នកវិះវេ
កុំធ្វើបំពាន។

កុំពោលមុសា ខុសពីហេតុការណ៍ រឿងដែលមិនមាន
នាំឱ្យគេស្អប់ ពោលតាមចិត្តហ៊ាន ឈ្មោះថាសាងស្ពាន
ទៅឋានផ្សាក្តៅ។

កុំញុះញង់គេ គួរតែវិះវេ សាងគុណក្នុងក្រៅ
កុំពោលបំបែក បងប្អូនកូនចៅ ឬមួយញាតិផៅ
ឱ្យគេគ្រាំគ្រា។

កុំស្តីចាក់ដោត ពោលពាក្យបញ្ឆោត នាំពៀរវេរា
ស្លាប់ទៅនរក ច្រើនជាន់នានា ព្រោះល្ងង់ពាលា
ព្រោះចាក់ដោតគេ។

រឿងរ៉ាវមួយទៀត អ្នកកុំបីឆ្វៀត រឿងមិនបានការណ៍
កុំពោលឱ្យសោះ បើពោលកាលណា អប្បឥតប្រាជ្ញា
មិនបានសុខទេ។


www.elibraryofcambodia.org

ម្យ៉ាងទៀតកុំចង់ ឬមានចំណង់ ទ្រព្យធនធានគេ
គួរកុំចង់បាន ទ្រព្យមិនស្ថិតស្ថេរ ហត្ថាទាំងទ្វេ
គួរខំខ្លួនឯង។

អ្នកកុំគុំគួន ចិត្តបាបក្នុងខ្លួន ត្រូវចេះកោតក្រែង
គំនិតបៀតបៀន កុំផ្ដុំជាផ្សែង ដុតរោលខ្លួនឯង
នាំតែបាបកម្ម។

មិច្ឆាទិដ្ឋិ រស់គ្មានសតិ គិតខុសរាប់ឆ្នាំ
ដើរតាមផ្លូវមារ ផ្លូវព្រះមិនចាំ ធ្លាក់ក្នុងក្រញាំ
ការយល់ខុសហើយ។

វេលាមានខ្ចី ខំពោលស្រដី មិនបានវែងឡើយ
ចុងបញ្ចប់នេះ ជូនបុណ្យឱ្យហើយ សូមអ្នកបានស្បើយ
ផុតទុក្ខទៅហោង។

*សូមអនុមោទនា!!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

# ៥៩.ព្រួតែគុណម៉ែ ម្ដេចមិនព្រួគុណឪ?

ឱ!ព្រះគុណអើយពុកហើយនឹងម៉ែ លោកខំឥតល្ហែគ្មានគិតហៀយហត់
ចិញ្ចឹមកូនតូចដោយក្ដីអំណត់ ទោះមានឬខ្សត់តែងមានមេត្តា។
មានកូនពូកខ្លះព្រួតែគុណម៉ែ រៀងរាល់ថ្ងៃខែដែលលោកទេសនា
មិនព្រួគុណឪដឹងធំប៉ុណ្ណា ខ្លះក៏សង្កាសួរគេរាល់ថ្ងៃ។
ស្ដីពីអ្នកម្ដាយគាត់ខំពពោះ ឪអនុគ្រោះទឹកចិត្តសែនថ្លៃ
ប្រពន្ធពពោះទឹកចិត្តអរក្រៃ ខំគ្មានសំចៃធ្វើការរកស៊ី។
ទឹកចិត្តឪពុកស្នេហ៍ម៉ែមែនពិត ពិសេសគំនិតស្នេហ៍កូនជីវី
ចង់ឃើញកូនណាស់ធ្វើការសំភី ខែមួយខែពីរព្រោះកូនកនិដ្ឋា។
កាលនៅកម្លោះឪមិនសូវព្រួយ ជិតបានកូនមួយលំបាកចិន្ដា
រកស៊ីឆ្ងាយជិតធ្ងន់ស្រាលមិនថា រិះរកយ៉ាងណាថែកូនពុំងា។
ភ្លឺឡើងមិនទាន់ឪងើបចេញទៅ ផ្ដាំកូនពាលពៅប្រពន្ធស្ងួនភ្ងា
ធ្វើស្រែចម្ការជួញដូរព្រៃឡា ឪខ្លះវេទនាត្រូវគេបោកប្រាស។
ទឹកភ្លៅត្រជាក់ពេលឆ្លងទន្លេ ពុំសូវទំនេរលោកគិតខ្លាំងណាស់
ស្វែងរកគ្រូពេទ្យមិនប្រហែសផ្ដាស គុណនេះធំណាស់លើកូនប្រុសស្រី។
អ្នកផ្ដើមគំនិតពង្រឹងគ្រួសារ ឪនេះឯងណាតែងប្រុងស្មារតី
ថែទាំចិត្តកាយព្រមទាំងសម្ដី ទឹកចិត្តប្រិមប្រិយតែងផ្ដល់សុខា។



www.elibraryofcambodia.org

មើលចុះខោអាវមិនសូវមានថ្មី ជូនគ្មានជាវីអង្គុយសំកុក
ខ្វះម្ហូបអាហារត្រីប្រៃប្រហុក គ្មានអ្វីហូបចុកឪខំរិះរេ។
ពេលខ្វះក្រពេកកម្សត់ទ្រព្យា ស្វែងរកការងារនៅឯស្រុកគេ
ធ្វើការរាល់ថ្ងៃពុំសូវទំនេរ ឱ!ស្ងួនមាសមេនឹកកូនប្រពន្ធ។
កាប់គាស់លីសែងភ្ជួររាស់ស្រែដាំស្រូវ ស្រេចលើរូបឪការងារស្រាលធ្ងន់
ពុកខិតខំណាស់មិនមានទម្រន់ ចិត្តឪទោទន់រកកូនថ្លើមថ្លៃ។
តាមពិតឪពុកក៏មានគុណដែរ មិនមែនតែម៉ែទេណាចរណៃ
ការងារសព្វគ្រប់គាត់ធ្វើផ្ទាល់ដៃ បែកញើសរាល់ថ្ងៃដើម្បីកូនភ្ញា។
ដូច្នេះកូនចៅទោះតូចធំអើយ ម៉ែឪនេះហើយដែលជាព្រហ្មា
ចូរអ្នកតបគុណរៀងរាល់វេលា ទើបរួចវេរាលុះបរលោកនាយ។

*សូមអនុមោទនា!!!*

**ដោយសាចណោរ សា ចាន់រ៉ាត់**

**បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ**
**អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តោ កុតោ ធនំ ។**

ជនពាលតែងព្រួយលំបាក ដោយសេចក្តីសម្គាល់ថា កូនទាំងឡាយរបស់អញ មាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណង់បើកូនទាំងឡាយ នឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា មាន អំពីណាបាន។ (**ពាលវគ្គទី៥ បិដកលេខ៥២**)



www.elibraryofcambodia.org

## ៦០-មានក៏មាននៅខ្ញុំមានថាស្តី!

ធម្មតាអ្នកមានផ្ទុយពីអ្នកក្រ ខ្លួនឯងបានល្អស្អប់អ្នកអាក្រក់
ពួកចោរទាំងឡាយចូលចិត្តលួចឆក់ ពួកអ្នកកុហកចូលចិត្តបោកប្រាស។
ត្រីរស់ក្នុងទឹកឡើងតាមទម្លាប់ រីឯត្រីងាប់មិនដែលឡើងច្រាស
ជាតិមនុស្សចិត្តពាលគិតអ្វីតែផ្តាស គិតមិនល្អល្អះច្រើនមើលងាយគេ។
ផ្ទះថ្មសែនធំអួតខ្លួនអ្នកមាន មិនដែលធ្វើទានកំណាញ់កើតទ្វេ
ក្នុងផ្ទះតុទូខោអាវខ្មៀយគ្រែ មាត់មិនទំនេរពីពាក្យនិន្ទា។
ស្តីពីភ្លើងធាតុមិនឆ្អែតដោយឧស ធម្មតាស្រីប្រុសតែងជួបគ្រប់គ្នា
គឺការមើលស្រាលពីជនពាលា ដែលតែងចងពៀរមិនដែលលោះថ្ងៃ។
មែនហើយមានទ្រព្យគួរមានសទ្ធា មិនគួរអួតគ្នាគួរសាងតម្លៃ
ដោយសារមានះនាំឱ្យចង្រៃ គុណធម៌ក្សិណក្ស័យព្រោះតែនៅល្ងង់។
បើសិនដាក់ខ្លួននាំឱ្យប្រសើរ ធ្វើខ្លួនគ្រាន់បើខ្ពស់ដូចដងទង់
តាំងខ្លួនអ្នកមានលាភយសច្រើនលង់ ធ្លាក់ក្នុងអន្លង់មានះតណ្ហា។
បើបានដឹងហើយគួរតែកែប្រែ ធ្វើល្អផងដែរស្តាប់ធម៌ទេសនា
រក្សាសីលទានចម្រើនប្រាជ្ញា លះបាបកាលណាឃើញសច្ចហោង។

*សូមអនុមោទនា!!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ៦១.ឆ្លេវពីអ្នកថា

កំហុសតែងមានចំពោះអ្នកធ្វើ អ្នកអង្គុយមើលចាំតែស្តីថា
បើត្រូវថាល្អសប្បាយចិន្តា បើខុសកាលណានិន្ទាគ្មានឈប់។
មនុស្សលោកឥឡូវការងារច្រើនណាស់ ធ្វើទាំងក្មេងចាស់ទាំងថ្ងៃទាំងយប់
មានខុសមានត្រូវយ៉ាងច្រើនលើសលប់ មិនត្រូវសព្វគ្រប់ល្អទាំងអស់ឡើយ។
តាមពិតឃើញខុសគួរតែអាណិត មិនគួរមានចិត្តគុំកួនឥតស្បើយ
គួរប្រាប់ណែនាំផ្លូវល្អឱ្យហើយ មិនគួរកន្តើយមើលតែបំណាំ។
និយាយស្តីអ្វីឱ្យគេស្តាប់ខ្លួន ចិត្តមិនមាំមួនគំនិតសាំញាំ
គេខុសមួយថ្ងៃថាគេរាប់ឆ្នាំ ចិត្តនេះចងចាំមិនចេះភ្លេចសោះ។
គេមិនស្តាប់ខ្លួនថាគេមនុស្សឆ្វេង ឬគំនិតផ្សេងមិនត្រូវទាំងអស់
តាមពិតខ្លួនខុសគំនិតឡេះឡោះ ចាំចុះសប្បុរសកុំយកជាគ្នា។
សេចក្តីប្រកាន់ថាខ្លួនត្រឹមត្រូវ តាមពិតខុសផ្លូវគំនិតពាលា
ធ្វើតាមចិត្តខ្លួនគ្មានដឹងធម្មា គិតតែនិន្ទាគ្មានយល់អ្វីល្អ។
ថាគេធ្វើខុសគេគិតខំកែ ខ្លួនខុសរាប់ខែមិនគិតលម្អ
គេមានអស់ហើយខ្លួននៅតែក្រ គេទៅជាសខ្លួននៅតែខ្មៅ។
ថាគេមនុស្សខូចខ្លួនឯងល្អជា គេចេះគ្រប់គ្នាខ្លួននៅតែខ្លៅ
គេរឹងខាងក្នុងខ្លួនឯងរឹងក្រៅ នេះហើយលោកហៅមនុស្សបានតែមាត់។


www.elibraryofcambodia.org

ស្តីពីកិច្ចការអួតចេះទាំងអស់ ស្គាល់គ្រឿងរបស់អួតថាចាំស្ទាត់
បើគេទៅជួយចាំមើលចុះគាត់ ស្តីឬហាមឃាត់គេជួយមិនបាន។
ស្តីថាម្តងៗថាគេអន់ណាស់ ខ្លួនទើបល្អល្អះធ្វើមានមូលដ្ឋាន
ខ្លួនជិះកង់សោះអួតថាមានឡាន ពោលឡើងថ្មើម៉ានគេលែងជឿអស់។
មែនហើយអស់លោកជាទីស្នេហា ស្តាប់គិតចុះណាខិតខំរំដោះ
កុំអួតខ្លួនឯងថាគេឱ្យសោះ ចូរកុំឡេះឡោះឆ្ងាញ់ពាក្យនិន្ទា។
តាមពិតកំហុសមិនមែនព្រោះថា តាមរឿងធម្មតាគឺមានគ្រប់គ្នា
មិនបាច់ពោលស្តីក៏ទុក្ខគ្រាំគ្រា ចាំចុះមីងមាគួរមានមេត្តា។
ជាចុងបញ្ចប់សូមអភ័យទោស រាល់ពាក្យដែលខុសឆ្គងពីអ្នកថា
សូមជូនបុណ្យនេះដល់ជាតិខេមរា មាតាបិតាសូមសុខទៅហោង។

*សូមអនុមោទនា!!!*

**ដោយសាចណោរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ៦២_ចាស់តែអាយុ

ធម្មតាឫស្សីរីងក្រៅរន្ធក្នុង
ប្រៀបដូចផ្លែល្ហុងគ្រាន់តែនៅខ្ចី
ដល់ទុំរលួយធ្លាក់ចុះដល់ដី
បានត្រឹមចំណីរូបធាតុទាំងឡាយ។
រីងប៉េងប៉ោងគ្រាន់តែមានខ្យល់
រឿងមិនកង្វល់គ្រាន់នៅសប្បាយ
សាងទុច្ចរិតកម្មទុក្ខមិនរសាយ
សង្ខារទាំងឡាយកើតហើយរលត់។
ស្តីពីគុណធម៌អាស្រ័យប្រាជ្ញា
ចង់បានសុខាធ្វើល្អមួយគត់
ចង់ល្អកុំស្មៀមប្រៀបដូចដង្កត់
ចង់លឿនត្រូវរត់ទើបដល់គោលដៅ។
ចំណេះចេះដឹងបានព្រោះឧស្សាហ៍
រៀនសូត្រអក្ខរាទើបផុតល្ងង់ខ្លៅ
កុំអាងទ្រព្យធនឬមួយញាតិផៅ
អាងកូនអាងចៅខុសក្បួនតម្រា។
បើសិននៅល្ងង់គួរខំរៀនសូត្រ
បើកាចត្រូវស្លូតកុំប្រើហឹង្សា
បើសិនខ្លួនចាស់សូមចាស់ប្រាជ្ញា
កុំឱ្យក្មេងថាយើងចាស់តែវ័យ។
រុក្ខជាតិពេលខ្លះចេញផ្លែស្លាប់ខ្លួន
មនុស្សមិនមាំមួនស្លាប់គ្មានអត្ថន័យ
រស់នៅយូរពិតមិនចេះលកលៃ
សាងតែអប្រិយរស់ប្រៀបដូចស្លាប់។
បើសិនចង់សុខរស់មានតម្លៃ
គួរតែកែច្នៃធ្វើខ្លួនតាមច្បាប់
កុំចាស់តែវ័យឱ្យក្មេងស្តីប្រាប់
គួរខំប្រញាប់សាងល្អទៅហោង។

*សូមអនុមោទនា!!!*

**ដោយសាចណោរ សា ចាន់រ៉ាត់**



www.elibraryofcambodia.org

## ៦៣-កូនខុសហើយម៉ែ!

ពេលមានជីវិតកូនមិនបានគិត ដល់ម៉ែក្ស័យពិតទើបកូនភ្ញាក់ខ្លួន
បម្រើស្រោលធ្ងន់លើម៉ែនឹមនួន ក៏កូនមាសស្ងួនមិនបានធ្វើដែរ។
ចំណីអាហារហូបចុកទាំងខ្វះ ខ្លួនម្ដាយសែនចាស់រស់នៅស្រុកស្រែ
កូនមិនដែលទៅសួរសុខទុក្ខម៉ែ គ្មានអ្នកមើលថែក៏កូនមិនខ្វល់។
ឱ! ព្រះម៉ែអើយកូនស្ដាយណាស់ ពីមុនល្ងង់ណាស់គ្មានដឹងខ្យល់
ពុកម៉ែនៅរស់មិនសាងមគ្គផល ព្រោះគិតមិនដល់គុណអ្នកម្ដាយថ្លៃ។
នឹកឃើញគ្រាមួយកាលកូននៅតូច ម៉ែថែប្រៀបដូចជាពេជ្រចរណៃ
យកសក់បាំងកូនយកខ្លួនបាំងថ្ងៃ កូនស្ថិតក្នុងដៃព្រះម៉ែថ្នមបី។
ធ្វើការរកស៊ីមិនមានចន្លោះ ឆ្លៀតឱ្យបៅដោះមិនមានខ្មាសអី
នៅមុខមហាជនមានប្រុសមានស្រី ក៏ម៉ែធ្វើហីឱ្យតែកូនឆ្អែត។
គុណធំយ៉ាងនេះរិះគិតមិនដឹង គុណល្អយ៉ាងហ្នឹងឃើញច្បាស់ក្រឡែត
គិតពីខែមគ្គថាចាំខែចែត្រ ធ្វើបុណ្យជាហេតុតបគុណម៉ែខ្លះ។
មិនទាន់ដល់ផងម៉ែលាកូនហើយ អ្នកម្ដាយគ្រាណត្រើយកូនខុសខ្លាំងណាស់
ព្រោះមិនស្ដាប់គ្រួយល់តែផ្ដេសផ្ដាស មិនថែម្ដាយចាស់ឱ្យនៅម្នាក់ឯង។
មើលចុះខ្ទមតូចស្ងៀមធ្វើមិនដឹង ខ្ញុំទុក្ខម៉្លឹងៗចិត្តវិលដូចផ្សេង
ទីកដីខ្ទមតូចដែលជាកន្លែង សូមជួយថ្វាថ្លែងរកម៉ែខ្ញុំផង។



www.elibraryofcambodia.org

ឱ!ម្ដាយសម្លាញ់ជាទីស្នេហា ម៉ែនៅឯណាម្ដេចស្ងាត់តែម្ដង
ពីដើមមកជួបម៉ែស្ដីឆ្លើយឆ្លង ពេលនេះឯងហោងឃើញតែទីតាំង។
ឃើញគ្រែកន្ទេលម៉ែធ្លាប់សម្រាន កូនទប់មិនបានព្រោះកូនខុសខ្លាំង
ឃើញក្រមាចាស់ម៉ែធ្លាប់បិទបាំង ឱ!អ្នកសច្ចំជួយរកម៉ែខ្ញុំ។
ពាងទឹកថ្នាំងបាយនិងខោអាវម៉ែ ពីរបីហូរហែកូនរឹតទុក្ខធំ
ម៉ែអើយពេលនេះកូនទុក្ខប៉ុនភ្នំ កូនចង់តែយំប្រាប់អស់ទេវតា។
ពេលនេះហួសហើយគ្មានត្រឡប់វិញ កូនទុក្ខទោម្នេញគ្មានពេលភ្លឺថ្លា
ម៉ែរស់ក្នុងខ្ទមកូននៅវិទ្យា សម្ដូចគេថាកូនដូចបក្សី។
មិនគួរសោះឡើយម៉ែអើយទៅណា កូនមកហើយណាំសូមម៉ែស្រដី
ម្ដេចនៅស្ងៀមឈឹងសំរានធ្វើហី កូនយកចំណីជូនម៉ែពិសា។
ពុទ្ធោម៉ែខ្ញុំគាត់ស្លាប់ទេដឹង ដៃជើងគាត់រឹងមិនស្ដីចរចា
ម៉ែអើយៗម៉ែសូមភ្ញាក់ឡើងណា កូនជូនអាហារកូនមកដល់ហើយ។
មើលចុះញាតិមិត្តគេធ្វើអ្វីទៅ អ្នកម្ដាយពាលពៅដេកធ្មេចកន្តើយ
ខ្លះវាយក្ដាររមឈូសពុទ្ធោម៉ែអើយ ម៉ែលាកូនហើយឱ្យកូនពឹងអ្វី។
អស់លោកប្រុសស្រីសូមជួយខ្ញុំផង សូមជួយចម្លងទៅជួបម្ដាយស្រី
គាត់នៅទីណាខ្ញុំសែនរឹងរៃ ពុទ្ធោម៉ែក្បែយកូនខុសខ្លួនហើយ។

*សូមអនុមោទនា!!!*

**ដោយសាចណោរ សា ចាន់រ៉ាត់**


www.elibraryofcambodia.org

# សិក្សាបទពិចារណា

១-បើចង់ឱ្យខ្លួនឯងបានល្អ កុំត្រដរពោលតែទោលគេ
បើចង់ឱ្យខ្លួនបានទំនេរ ត្រូវខំរិះរេធ្វើកុសល ។

២-អ្វីៗមិនមែនសុទ្ធតែបានដូចក្តីប្រាថ្នាទេ
លុះត្រាតែរិះរេហើយធ្វើទើបកើតឡើង។

៣-គ្មានអ្នកណាឆោតស្មើនឹងមនុស្សល្ងង់
គ្មានលង់អ្វីស្មើនឹងលង់គំនិត។

៤-អ្នករៀនតែងសន្សំពូជប្រាជ្ញា
ឯអ្នកជ្រះថ្លាតែងសន្សំបុណ្យ ។

៥-បើខ្លួននៅក្រកុំត្រដរធ្វើសេដ្ឋី
បើខ្លួនគំនិតខ្លីត្រូវសន្សំពូជប្រាជ្ញា ។

៦-អ្វីៗយើងអាចធ្វើបានមែន
តែរឿងដែលមែនទែនក៏មានគេធ្វើបានដែរ។

៧-បើចង់ឃើញអ្វីៗគ្រប់យ៉ាងកុំធ្មេចនេត្រា
បើសិនចង់បានពូជប្រាជ្ញាកុំសន្សំការខ្ជិលច្រអូស។

៨-ចង់ឈ្នះគេគឺចាញ់ខ្លួនឯង


www.elibraryofcambodia.org

ចង់ឱ្យគេកោតក្រែង លុះត្រាតែខ្លួនជាមនុស្សល្អ។

៩_បើសិនចង់បានល្អកុំប្រញាប់ខឹង

បើសិនចង់ដឹងកុំនិយាយកាត់សម្តីគេ។

១០_មនុស្សប្រសើរព្រោះមានប្រាជ្ញា

មនុស្សអស្ចារ្យព្រោះមានគុណធម៌។

១១_មនុស្សឆ្លាតមានប្រាជ្ញាជាគ្រឿងទ្រទ្រង់

ចំណែកមនុស្សល្ងង់មានមានះជាគ្រឿងគាំទ្រ។

១២_ពេលដែលមានភ័យបន់ស្រន់ទេវតា ពេលជួបទុក្ខាសូមឱ្យព្រះជួយ
ពេលខ្លួនបានសុខមិនដែលគិតព្រួយ សាងគុណជំនួយជាទីពឹងសោះ។

១៣_សន្សំមាសប្រាក់បានថ្នាក់សេដ្ឋី

សន្សំបារមីរមែងផុតទុក្ខ។

១៤_បើសិនធ្វើស្រែតែងបានស្រូវ

តែបើធ្វើត្រូវតែងបានល្អគ្រប់យ៉ាង។

១៥_បើសិនសាងល្អបានគុណជាគ្នា

សាងពៀរវេរាធនរករងចាំ។

១៦_រស់នៅសាងធម៌សុគតិប្រាកដ

រស់មានអំណត់ជីវិតបានសុខ។



www.elibraryofcambodia.org

១៧. បើខ្លួនបានល្អកុំត្រដររមើលងាយគេ

បើសិនជាទំនេរខិតខំធ្វើល្អទៀតទៅ។

១៨. មនុស្សល្អព្រោះសាងកម្មល្អ

រស់នៅកម្រព្រោះតែខ្វះបុណ្យ។

១៩. បើសិនចង់ដើរទៅមុខត្រូវតែឈាន

បើប្រាថ្នានិព្វានលុះត្រាតែប្រព្រឹត្តធម៌។

២០. បើសិនខ្លួនទាបឱ្យទាបទៅចុះ ស្រីប្រុសកុំតែនៅទាបគំនិត

បើកាយអាក្រក់មិនសមនែបនិត្យ ឱ្យតែផ្លូវចិត្តបានល្អប្រពៃ។

២១. អ្នកប្រាថ្នាទ្រព្យជាប់ឈ្មោះអ្នកមាន

អ្នកដែលឱ្យទានជាប់ឈ្មោះល្អក្រៃ។

អ្នកសាងទុច្ចរិតជាប់ឈ្មោះអវិចី

សាងបុណ្យបារមីជាប់ឈ្មោះនិព្វាន។

២២. មានអ្វីមិនស្មើនឹងមានគំនិត សុខអ្វីពិតមិនស្មើនឹងសេចក្តីស្ងប់។

២៣. សមុទ្រទាំងឡាយរលកព្រោះខ្យល់ចិត្តអកុសលព្រោះមានអវិជ្ជា។

២៤. សៀវភៅទាំងអស់ចេញពីគំនិត អ្នកសរសេរពិតរាល់រូបកាយ

ដូច្នេះអ្នកអានចូរខ្វល់ខ្វាយ កុំទាន់សប្បាយអានហើយគិតផង។



www.elibraryofcambodia.org

២៥. បើសិននៅខ្ញុំគេនៅគ្រាន់អស្ចារ្យ

តែបើខ្ញុំតណ្ហាទុក្ខគ្មានអ្វីប្រៀប។

២៦. បើសម្បុរខ្មៅឱ្យតែចិត្តស

តែបើខ្លួនក្រឱ្យតែមានអរិយទ្រព្យ។

២៧. បើគេថាខ្លួនខុសកុំប្រញាប់ខឹង

រឿងនោះត្រូវដឹងគិតពិចារណ៍។

ជួនកាលខុសមែនព្រោះមោហា

មានៈដូចខ្លាគេប្រាប់មិនបាន ។

២៨. បើខ្លួនមានភ័យចូរនឹកគុណព្រះ

បើមានប្រាក់មាសចូរគិតឱ្យទាន។

២៩. បើរពីសដៃរមែងផ្ដែផ្ដែត

តែបើរពីសខុសហេតុពិតជារងកម្ម។

៣០. បើគេថាយើងអន់មានអ្វីត្រូវរង្កៀស

តែរឿងដែលគួរឱ្យរង្កៀសគឺយើងអន់មែន។

៣១. រស់នៅមិនខិតខំធ្វើល្អ

ប្រៀបដូចស្ករគ្មានរសផ្អែម។



www.elibraryofcambodia.org

៣២_ល្អហើយនៅត្រង់ចេះស្ដីថា

តែរឿងដែលអស្ចារ្យគឺថាហើយធ្វើផង។

៣៣_ចូលព្រៃត្រូវប្រយ័ត្នបន្ទាមុត ពេលប្រយុទ្ធប្រយ័ត្នកម្លាំងទ័ព

ធ្វើទានប្រយ័ត្នកម្លាំងទ្រព្យ ពេលជិតងាប់ប្រយ័ត្នអត់ធម៌។

៣៤_អាយុមានតិចឱ្យតែចេះធ្វើល្អហើយតស៊ូ

កុំតែរស់យូរហើយមិនចេះធ្វើល្អ។

៣៥_ផែនដីល្អស្រស់ព្រោះដួងព្រះសូរិយា

មនុស្សល្អថ្លៃថ្លាព្រោះមានធម៌។

៣៦_រស់នៅគ្មានប្រាជ្ញា ប្រៀបដូចខ្លាគ្មានចង្កូម

រស់នៅធ្វើអ្នកសូម ចុងក្រោយទ្រមមិនចេះរក។

៣៧_បើកើតមកជាមនុស្សក្នុងលោកនេះ ហើយមិនសាងប្រយោជន៍

ស្លាប់ទៅជាខ្មោចពិតជាគ្មានន័យ។

៣៨_រកស៊ីលក់ដូរជារឿងអ្នកផ្សារ ធ្វើស្រែចម្ការរឿងកសិករ

រឿងធ្វើបុណ្យទានមានតែអ្នកល្អ នរកជាន់កមានតែអ្នកបាប។

៣៩_គិតហើយសឹមគូរ កុំគូរហើយគិត

រស់សាងសុចរិត ជីវិតថ្លៃថ្លា។



www.elibraryofcambodia.org

៤០_ការធ្វើអ្វីមួយមិនគួរខ្លាចគេថា ឯរឿងដែលគួរឱ្យពិចារណា
គឺគេថាព្រោះយើងធ្វើមិនកើតមែន។

៤១_បើគេមិនស្រឡាញ់ខ្លួនគ្មានអ្វីគួរឱ្យឆ្ងល់ទេ
បើមានពេលទំនេរគិតមើលថា
តើខ្លួននៅមានចំណុចអវិជ្ជាមានត្រង់ណា
ហើយធ្វើការកែប្រែសារជាថ្មីឡើងវិញ។

៤២_ពេលវេលាមិនរង់ចាំបុគ្គលណាមួយឡើយ
ហើយនៅតែមានតម្លៃជានិច្ចសម្រាប់អ្នកធ្វើល្អ
បើបានដឹងដូច្នោះ ស្រីប្រុសគួរបណ្តោយឱ្យពេលវេលា
កន្លងទៅដោយឥតប្រយោជន៍ឬ ?

៤៣_គេពោលពាក្យសម្តីពីរោះគួរតែជ្រះថ្លា
តែរឿងដែលមានខ្លឹមសារ គឺស្តាប់ហើយប្រតិបត្តិទៅបានប្រយោជន៍។

៤៤_មនុស្សដែលគ្មានសីលដូចជាអំបិលគ្មានជាតិប្រៃ
មនុស្សគ្មានតម្លៃព្រោះអាស្រ័យគ្មានគុណធម៌។

៤៥_ដើម្បីឱ្យដល់គោលដៅនៃជីវិតពិត
មិនគួរបណ្តោយចិត្តឱ្យឆ្ងាយពីព្រះធម៌។


www.elibraryofcambodia.org

៤៦.ធ្វើល្អឱ្យជាគំរូដល់អ្នកដទៃ

ពិតជាប្រពៃជាជាងនិយាយល្អជាគំរូដល់អ្នកដទៃ។

៤៧.ចង់បានល្អតែមិនខំសាងល្អ តើសូមអង្វរព្រះណាឱ្យជួយ

ខ្លួនឯងមិនដែលគិតមានចិត្តព្រួយ សូមតែជំនួយពិតជាមិនបាន។

៤៨.ស្រឡាញ់គ្នាផ្ដើមដោយមេត្តា

ប្រៀបដូចពិសាអំពៅពីចុងទៅរកគល់

បើស្រឡាញ់គ្នាទាំងមិនយល់

ប្រៀបដូចពិសាអំពៅពីគល់ទៅរកចុង។

៤៩.អ្នកធំអាងអំណាច អ្នកកោងកាចអាងកំហឹង

អ្នកល្ងង់អាងមិនដឹង អ្នកខំប្រឹងតែងបានសម្រេច។

៥០.បើសិនបានធ្វើធំសូមឱ្យធំគំនិត

តែបើបានជាគិតសូមគិតឱ្យបានត្រូវ។

៥១.ជីវិតរស់នៅដែលគ្មានគោលដៅ ដូចដំបៅគ្មានឱសថព្យាបាល

រស់ក្នុងសង្គមចេះជួយឈឺឆ្អាល ហេតុនោះបណ្ដាលទើបបានថ្កុំថ្កើង។

៥២.បើសិនជាចូលមករកគេ ចូររិះរេឱ្យគេអាណិត

បើសិនជាចេញទៅឆ្ងាយជិត ក៏សូមធ្វើខ្លួនឱ្យគេអាល័យ។



www.elibraryofcambodia.org

៥៣-បើសិនជាមានចំណេះដឹង ចូរខំប្រឹងជួយប្រាប់គេឯង
បើសិនជាចេះខំសម្តែង ចំណេះនោះឯងរឹតតែល្អ។

៥៤-អ្នកក្រដោយច្រើនស្លាប់ព្រោះតែភាពអត់ឃ្លាន
ក៏គង់តែពួកអ្នកមានស្លាប់ព្រោះទ្រព្យសម្បត្តិដែរ
ដូច្នេះរស់នៅទោះក្រុងឬស្រែ
គិតរាល់ថ្ងៃខែឆ្លៀតធ្វើបុណ្យខ្លះផងណា។

៥៥-ធម្មតាអ្នកជួញចង់បានចំណេញ រីឯអ្នកទិញចង់បានគុណភាព
អ្នកក្រខ្សត់ចង់បានលាភ ធម្មតាអ្នកទាបចង់បានខ្ពស់ ។

៥៦-បើសិនជាចង់ធ្វើចៅហ្វាយនាយលើអ្នកដទៃ
ចូរលកលៃធ្វើជាអ្នកបម្រើគេសិន ។

៥៧-បើល្ងង់ហើយអួតដូចមនុស្សឆ្កួតគ្មានដឹងខ្យល់
បើសិនចេះហើយធ្វើជាឆ្ងល់រឹតតែបានផលគិប្រាជ្ញា ។

៥៨-រស់នៅគ្មានវិន័យប្រៀបដូចជាក្របីគ្មានស្នែង
រស់នៅមិនគោរពគេឯង ប្រៀបដូចផ្សែងលើវេហាស៍។

៥៩-មនុស្សដែលល្ងង់តែងលង់ក្នុងពាក្យសរសើរ
មនុស្សគ្រាន់បើមិនសរសើរក៏ល្អដែរ
មនុស្សល្ងង់គេនិន្ទាកើតទុក្ខឥតល្ហែ ឯអ្នកចេះកែគេថារឹតតែសុខ។



www.elibraryofcambodia.org

៦០. មនុស្សដែលល្អគេចូលចិត្តធ្វើបុណ្យ វីឯទុជ៌នចូលចិត្តធ្វើបាប

កវីនិពន្ធចូលចិត្តតែងកាព្យ ចុះអ្នកស្ដាប់ចូលចិត្តអ្វី ?

៦១. អ្នកល្ងង់ព្យាយាមរៀនហើយ តែមិនចេះគួរឱ្យអាណិត

ប៉ុន្តែអ្នកឆ្លាតពិត ហើយខ្ជិលរៀនគួរឱ្យសង្វេគ

អ្នកក្ររកស៊ីខំទូលរែក ហើយក៏នៅតែមិនមាន

គ្រាន់បើជាងធ្វើខ្លួនជាអ្នកសូមទានអស់មួយជីវិត។

៦២. សេចក្ដីល្អទាំងឡាយ មានច្រើនណាស់នៅក្នុងលោកនេះ សម្រាប់ឱ្យធ្វើ មានតែមនុស្សដែលភ្លើទេតើ មិនចេះធ្វើសេចក្ដីល្អនោះ។

៦៣. មនុស្សដែលល្អធ្វើបុណ្យបានយ៉ាងសប្បាយ

ឯបាបទាំងឡាយវិញធ្វើបានដោយក្រ

មនុស្សអាក្រក់ធ្វើបុណ្យមិនចេះត្រេកអរ

ឯបាបជាន់កទើបដឹងថាសេចក្ដីទុក្ខនោះយ៉ាងណា។

៦៤. បើចង់បានទ្រព្យគាប់ចិត្តឱ្យទាន

ចង់បាននិព្វានត្រូវប្រព្រឹត្តធម៌។

៦៥. មនុស្សរស់នៅហើយខ្វះខន្តី ប្រៀបដូចដីរដែលគ្មានភ្លុក

បើសិនរស់នៅខ្លាចក្ដីទុក្ខ ចូរខំសម្រុកប្រព្រឹត្តល្អ។



www.elibraryofcambodia.org

៦៦_បើសិនជាអ្នកចេះញញឹមដាក់មុខអ្នកដទៃ ក្នុងបំណងល្អហើយមានមេត្តា ប្រៀបដូចអ្នកបានទទួលស្នេហា ឬការរាប់អានពីអ្នកដទៃ ៥០ភាគរយរួចមកហើយ។

៦៧_កុំធ្វើអ្វីតាមតែចិត្តខ្លួនឯង ត្រូវចេះកោតក្រែងចិត្តអ្នកដទៃ
បើមុនធ្វើអ្វីត្រូវគិតរំពៃ កុំឱ្យមានភ័យទើបរត់ឆ្វេឆ្វា។

៦៨_ទីស្ថាននរកតែងរងចាំអ្នកធ្វើបាបជារៀងរាល់វេលា
ឯស្ថានសួគ៌ាក៏នៅរងចាំអ្នកធ្វើបុណ្យជារៀងរាល់ថ្ងៃដែរ។

៦៩_គ្មានអ្វីស្រួលជាងថាហើយមិនធ្វើរាល់កិច្ចការ
ហើយក៏គ្មានអ្វីដែលលំបាកអស្ចារ្យ ជាជាងថាហើយធ្វើមិនកើតដែរ។

៧០_បើឃើញគេធ្វើខុសទាំងស្រីប្រុសស្ដីបន្ទោសគេហើយធ្វើបុកម្នេញ ចុះបើខ្លួនឯងធ្វើខុសវិញ ម្ដេចមិនស្ដីបន្ទោសឱ្យខ្លួនឯងផង ?

៧១_ជនជាញាតិជាប់សាច់សាលោហិត តែតាមការពិតមិនដឹងសុខទុក្ខរវាងគ្នានិងគ្នាទុកដូចអ្នកដទៃ រីឯអ្នកដទៃតែជួយគិតរំពៃវិញទុកដូចជាញាតិ។

៧២_បើសិនខ្លួនក្រទ្រព្យនៅគាប់ប្រសើរពិត
តែបើក្រគំនិតឬប្រាជ្ញាប្រៀបដូចស្វាបានផ្លែដូងទុំ។


www.elibraryofcambodia.org

៧៣_បើសិនរស់នៅខំធ្វើល្អ ទោះបីក្រមានគេអាណិត
បើសិនរស់សាងទុច្ចរិត ទោះមានមែនពិតគេនិន្ទា។

៧៤_បើតាំងខ្លួនឯងជាអ្នកធំ គឺត្រូវស្វែងរកអំណាច
តែបើតាំងខ្លួនឯងជាអ្នកកាច ចូរយកអំណាចសម្លាប់ក្តីក្រោធ។

៧៥_ពេលទំនេរសុខចិត្តអានសៀវភៅ ឬដេកលក់ទៅគ្មានជាប់ពៀរវេរានឹងអ្នកណា គ្រាន់បើហើយអស្ចារ្យជាជាងបបួលគ្នាផឹកស្រាហើយរំពៃទោសអ្នកដទៃឥតឈប់ឈរ។

៧៦_ម្ហូបនំចំណីឧបត្ថម្ភកាយា ឯពូជប្រាជ្ញាជំនួយផ្លូវចិត្ត
រស់នៅសាងល្អកំដរជីវិត សាងបាបទុច្ចរិតកំដរអបាយ។

៧៧_សេចក្តីសម្រេច ជាកម្មសិទ្ធិរបស់អ្នកព្យាយាមទាំងឡាយ
ការវិនាសអន្តរាយ ជាកម្មសិទ្ធិរបស់បុគ្គលប្រមាទធ្វេសប្រហែស។

៧៨_ខ្លួនក្រធ្វើមានឈ្មោះថាសាងស្ថានគឺ ពូជអំនួតអ្នកដែលកំពុងអួតគឺអសមត្ថភាព ឈ្មោះថាសាងស្ថានទៅកាន់ក្តីវិនាស។

៧៩_ឃើញគេធ្វើអ្វីបាន១ កុំគិតស្មានចង់បានហើយដូចគេ
បើយល់មិនច្បាស់ត្រូវចេះសួរគេ កុំគិតរិះរេតាំងខ្លួនជាអ្នកចេះ។

៨០_អ្នកបានធ្វើខុសទោះតូចឬធំ មិនគួរសើចយំឬស្តីបន្ទោស
គួរតែអាណិតមានក្តីសន្តោស ជួយកុំឱ្យខុសគឺធ្វើល្អវិញ។


www.elibraryofcambodia.org

៨១_គ្រហស្ថទាំងឡាយខ្វល់ខ្វាយរកស៊ី

ព្រះសង្ឃដូនជីខ្វល់ខាយធម៌អាថ៌

ពួកអ្នកនិន្ទាខ្វល់ខ្វាយរឿងថា

អ្នកមានប្រាជ្ញាគេថាកែខ្លួន។

៨២_ស្នេហាជាផ្នូរកប់ដួងព្រលឹង រឿងនោះត្រូវដឹងហើយប្រុងស្មារតី

មុននឹងសម្រេចយកប្រពន្ធប្ដី ចូរគិតលក់លៃថែមខន្ធប្រាំទៀត។

៨៣_ពេលមិនទាន់ឈឺអួតថាអស្ចារ្យ មិនពឹងនរណាមិនសូមជំនួយ

ខ្លួនមិនបានគិតថាមានថ្ងៃមួយ គឺមានគេជួយកប់ដុតខ្មោចខ្មី។

៨៤_និយាយថាអ្នកដទៃខុស ស្រីប្រុសមកពីខ្លួនឯងត្រូវ

និយាយពីគេតែរឿងអាស្រូវ ខ្លួនឯងនោះក្ជូវមិនដែលខុស។

៨៥_មានលុយហើយឱ្យគេខ្ចី ប្រុសស្រីជួនកាលបាត់បង់ពីរយ៉ាងគឺៈ

មួយគឺមិត្តភក្ដិដែលអ្នករាប់អាន អាចទាស់សន្ដានទៅជាបែកបាក់

ពីរគឺកែវកងមាសហើយនិងប្រាក់ មិនបានទុកដាក់សងអ្នកមកវិញ។

៨៦_ស្រួលណាស់នៅត្រង់ការនិយាយដូចអ្នកប្រាជ្ញ

តែរឿងដែលមិនអាចគឺ និយាយហើយធ្វើមិនកើត

ពេលនោះក៏នៅតែល្ងង់ដដែល។



www.elibraryofcambodia.org

៨៧_សៀវភៅជាប្រភពនៃចំណេះដឹង

ចូរអ្នកខំប្រឹងអានហើយគិតមើលផង។

៨៨_ចូរអ្នករៀនព្រមទាំងធ្វើខ្លួនឱ្យអ្នកដទៃស្រលាញ់

តែកុំរៀននិងធ្វើខ្លួនឱ្យជាអ្នកស្រលាញ់គេ

ដោយមិនបានគិតពីខ្លួនឯង។

៨៩_ក្មេងៗកុំទាន់មានស្រីក្នុងវ័យសិក្សា

តែត្រូវគិតថាអ្នកត្រូវមានស្នេហាក្នុងការរៀនសូត្រ។

៩០_កុំស្តីថាគេជាមនុស្សឆ្វេង មកពីខ្លួនឯងប្រកាន់ថាស្តាំ

ឃើញតែទោសគេនោះជាប្រចាំ ខ្លួនខុសរាប់ឆ្នាំម្តេចមិនថាផង ?

៩១_ធម្មតាអ្នកមានឋានៈទាបតែងចង់បានឋានៈខ្ពស់

តែបើចង់បានហួសអាចមានគ្រោះដោយសារតណ្ហា។

៩២_បើសិនជាចង់ឱ្យខ្លួនឯងបានស្អាត ចូរកុំសង្ងាតអំពើស្មោគគ្រោក

បើសិនជាចង់ឆ្លងផុតចាកលោក ចូរអ្នកចូលមកបដិបត្តិធម៌ព្រះពុទ្ធ។

៩៣_បើចាញ់បោកគេគង់នៅអស្ចារ្យ

តែបើចាញ់បោកអាត្មា នរណាក៏ជួយមិនបានដែរ។

៩៤_បើខ្លួនធ្វើខុសទោសប៉ុនទន្លេ បើមើលទោសគេធំប៉ុនសមុទ្រ

ចង់ឱ្យខ្លួនល្អតែជៀសមិនផុត ឥស្សានោះដុតឃើញតែទោសគេ។



www.elibraryofcambodia.org

៩៥_ចេះនិយាយល្អហាក់បីដូចជាប្រសើរហើយ

តែកុំភ្លេចឡើយនិយាយហើយត្រូវធ្វើល្អផង។

៩៦_ពាក្យសូមទោសសម្រាប់អ្នកធ្វើខុស អ្នកដែលអត់ទោសថាមិនអីទេ

ពាក្យអរគុណត្រូវចេះប្រើចំពោះគេ ចូរពិរៈអ្នកប្រើជាប្រចាំ។

៩៧_មនុស្សទូទៅស្អប់ទុក្ខស្រលាញ់សុខ ទោះព្រៃឬស្រុកនិគមនានា

ដូច្នេះរស់នៅមិនគួរសាងពៀរ គួរមេត្តាគ្នាសាងសុខអមតៈ។

៩៨_មនុស្សល្ងង់ពិចារណាអ្វីទាល់តែឃើញនឹងភ្នែក ឯអ្នកប្រាជ្ញលោក

ប្លែកមិនឃើញនឹងភ្នែក ក៏ពិចារណាឃើញបានដែរ។

៩៩_បើសិនចង់ដឹងត្រូវដាក់មានះ បើសិនចង់ឈ្នះយកឈ្នះខ្លួនឯង

បើខ្លួននៅតូចត្រូវចេះកោតក្រែង កុំឱ្យចំបែងដោយសារីរឹងត្អឹង។

១០០_កុំធ្វើអ្វីមួយទៅតាមទម្លាប់ មិនកាន់ច្បាប់ជាប់ទៅជាលីលា

ធ្វើអ្វីកុំធ្វើទៅតាមគ្នីគ្នា ធ្វើតាមធម្មាទើបបានត្រឹមត្រូវ។

**ដោយសាមណេរ សា ចាន់រ៉ាត់**

**ចប់ដោយបរិបូណ៌**



www.elibraryofcambodia.org

# នាមពុទ្ធបរិស័ទបរិច្ចាគប្រាក់ក្នុងការបោះពុម្ពសៀវភៅនេះ

-តាមរយៈញោមឧ.សិ.អ៊ូច ម៉ុន និង ឧ.សិ.អ៊ូច នៅភូមិប្រគាបឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ពុទ្ធបរិស័ទរួមគ្នា................៤៤១.១០០៛

-លោកយាយ សោម ផៃ និងញោម ទុំ ផល្លី និងភរិយា អ៊ុក សារ៉ាល់ ព្រមទាំងញាតិញោមនៅភ្នំធំខេត្តបន្ទាយមានជ័យ..................១០២.៥០០៛

- សាមណេរ សា ចាន់រ៉ាត់ និងញោមប្រុសស្រី +កញ្ញា ស្រីង៉ា..១០០.០០០៛

-ឧ.ស.ចក់ ប៊ីន និង ឧ.សិ.ថេត ឆាប +បុត្រ និងកូនចៅ........ ៩.២០០០៛

- ឧ.ស.វ៉ាន់ និងឧ.សិ.មុយព្រមទាំងបុត្រ........................ ៨០.០០០៛

- ឧ.ស.គីម សាយ និង ឧ.សិ.ព្រាប ញិប(ផ្សារណាត់ )......... ៨០.០០០៛

-តាមរយៈលោកម្ចាស់អតិវឌ្ឍនោ ស៊ឹម ប៊ុនរ័ត្ន................. ៧០.០០០៛

-អ្នកស្រី ស៊ុន សោភា និងស្វាមី ហ៊ាង ចុង ព្រមទាំងបុត្រ........៦០.៥០០៛

- ឧ.ស.ឆន ហួតនិង អ្នកគ្រូ ម៉ូវ សម្បត្តិ ព្រមទាំងបុត្រ...........៦០.០០០៛

- ឧ.សិ.អ៊ូច ម៉ុន ព្រមទាំងបុត្រ ( ភូមិប្រគាប )................... ៤០.០០០៛

- ឧ.សិ.យ៉ុាំ ឈីវបួយ (ភូមិល្វា ស្រុកបវេល)...................... ៤០.០០០៛

- ឧ.ស.ចាន់ ទូច និងឧ.សិ. ស៊ត វឌ្ឍនា........................ ៣៦.០០០៛

- ឧ.សិ.អៀម ពៅ និងស្វាមី ទន់ ចំណាន(សំរោងក្នុង).......... ២០.០០០៛

- ឧ.សិ.ហួត យន់ ព្រមទាំងបុត្រ និង ចៅ១...................... ២០.០០០៛



www.elibraryofcambodia.org

- ឧ.សិ.គូ ធារី និងស្វាមីព្រមទាំងបុត្រ.......................... ២០.០០០៛

- មណ្ឌលសុខភាពមោង..............................................២០.០០០៛

-លោកតាន់ ថា និង អ្នកគ្រូពេទ្យ យី នី ព្រមទាំងបុត្រ............២០.០០០៛

-លោកគ្រូពេទ្យ ហ៊ត ហេង និង ម៉ៅម៉ាឡាស៊ី..........................២០.០០០៛

-អ្នកគ្រូពេទ្យអៀង សុខ និង បុត្រ....................................២០.០០០៛

-បងសួស វិទ្យារ៉ាន់ឌី.......................................................២០.០០០៛

-ប្អូនប្រុស សួស វិទ្យា.....................................................២០.០០០៛

-ឧ.សិ.នូ សារី និងស្វាមី ព្រមទាំងបុត្រ............................២០.០០០៛

-ឧ.សិ.សោ ស៊ីវហាប់.......................................................១០.០០០៛

-ឧ.សិ.សោ ថងឌី...........................................................១០.០០០៛

-ប្អូនស្រី សួស ចន្ទរស្មី....................................................១០.០០០៛

-លោក ម៉ង់ ម៉ង់...............................................................១០.០០០៛

-ប្អូនឿន សុភាព (ភូមិថ្មី ឃុំតាម៉ិន ស្រុកថ្មគោល)............... ១០.០០០៛

-ឧ.សិ.ហាម ម៉េត(ទួលតាឯក)...........................................១០.០០០៛

-ឧ.សិ.សុខ ស៊ីម(ផ្សារថ្មី)...................................................១០.០០០៛

-ញោម ម៉ៅ វណ្ណី...............................................................១០.០០០៛

-ឧ.ស.ទូត អាង(អូស្ត្រាលី)..................................................១០.០០០៛

-ឧ.សិ.វិន ប៊ុក ព្រមទាំងបុត្រ.......................................... ១០.០០០៛



www.elibraryofcambodia.org

-ឧ.សិ. ទុយ មុច និងកូនចៅៗ(ភូមិល្វា).......................... ១០.០០០៛

-ឧ.សិ.អ៊ុម ហ៊ានផា........................................១០.០០០៛

-នាយិកា ធិន ផូរ៉ា និងស្វាមី ព្រមទាំងបុត្រ + ចៅៗ...............១០.០០០៛

-ឧ.សិ.កែវ សុគន្ធ ព្រមទាំងបុត្រ (ផ្សារលើ).......................១០.០០០៛

-លោកគ្រូ ធៀង អាន និងញោម ជុំ ស៊ីណា.......................១០.០០០៛

-ឧ.ស.សំនាង និងឧ.សិ.សេង មុំ(ភូមិល្វា ស្រុកបវេល)..........១០.០០០៛

-អ្នកគ្រូ លី សារឿត និងលោក អ៊ុយ សារុន ព្រមទាំងបុត្រ....... ៨.០០០៛

-លោក ស្រស់ សម្បត្តិ ជាងគំនូរឆពណ្ណរង្សី ប.ប................. ៨.០០០៛

-លោក ទូច ភ័ណ និងអ្នកស្រី សៀក ហ៊ុយចេង.................. ៨.០០០៛

-ឧ.សិ. មូរ គីមឡេង ព្រមទាំងកូនចៅ............................ ៥ក្បាល

-ឧ.ស. ធុន ធឿន និង ឧ.សិ. ទុំ បុប្ផ ព្រមទាំងបុត្រ............. ៥ក្បាល

-លោក ញ៉ុញ ពិសិដ្ឋ និងភរិយា ធិញ ព្រមទាំងបុត្រ............... ២ក្បាល

-បងស្រី ចន ណារី (ជាងកាត់ដេរ)................................ ៥.០០០៛

-ញោម ផាន់ សុវណ្ណ...................................... ៥.០០០៛

-ញោម អាពៅ........................................... ៥.០០០៛

-ញោម ទេព ណារ៉េត........................................ ៥.០០០៛

-ឧ.ស.ណាក់ និងឧ.សិ.ណាស់ ព្រមទាំងបុត្រ....................... ៥.០០០៛

-យុវជន តង តារាគិរី ...................................... ៥.០០០៛

-យុវនារី តង សោភា...................................... ៥.០០០៛



www.elibraryofcambodia.org

-ឧ.សិ.ហៃ ធាម ព្រមទាំងបុត្រ................................ ៥.០០០៛

-លោកគ្រូ ជ៉ាក់ មករា........................................... ៥.០០០៛

-បងប្រុស រឿន ចាន់ថូ និងភរិយា រឹម មករា (ផ្សារបឹងឈូក)... ៤.០០០៛

-លោកយាយ យឹម ជ៉ាច............................................. ៤.០០០៛

-ឧ.សិ.ប៊ិន វ៉េត ព្រមទាំងបុត្រ................................. ៤.០០០៛

-ឧ.សិ.ម៉ូវ បូ.................................................... ៤.០០០៛

-ឧ.សិ. ស ចន្ថា.................................................. ៤.០០០៛

-ឧ.សិ.ទុយ ស៊ីបេង.............................................. ៤.០០០៛

-ឧ.សិ.ទី វ៉េន..................................................... ៤.០០០៛

-ញោម ឧ.ស កា សុខា ព្រមទាំងភរិយា និងបុត្រ............... ១០ក្បាល

-ឧ.សិ.វត្តតាមិម រួមគ្នា.......................................... ៦ក្បាល

-ឧ.សិ.លៀង វិច្ឆិកា និងស្វាមី ព្រមទាំងបុត្រ.................... ៣ក្បាល

-លោក សែម សៅ និងអ្នកស្រី ប្លុង ផល្លា( ភូមិអូរតាគាំ២)..... ២ក្បាល

-លោក ផុងឈី.................................................... ១ក្បាល

-អ្នកស្រី កែវ សុគន្ធ............................................ ១ក្បាល

-ផុង សុជា......................................................... ១ក្បាល

-ផុង សុជាតិ...................................................... ១ក្បាល

-ផុង សុចិត្រា..................................................... ១ក្បាល

-ផុងសុផានិត..................................................... ១ក្បាល



www.elibraryofcambodia.org

-ជុំង សុផានុ........................................................ ១ក្បាល

-ជុំង រតនា........................................................ ១ក្បាល

-ជុំង រចនា........................................................ ១ក្បាល

-ផាន់ សុវណ្ណ........................................................ ១ក្បាល

-សោម មុត្តា........................................................ ១ក្បាល

-សោម មូនីកា........................................................ ១ក្បាល

-សោម សុផារី........................................................ ១ក្បាល

-កាឌុលកាន់ដារិទ្ធ........................................................ ១ក្បាល

-សុភាព ចេស្តា........................................................ ១ក្បាល

( ភូមិដុំបក្រសាំង ឃុំព្រែកតូច ស្រុកមោងឫស្សី ស្រុកមោងឫស្សី )

-ញោមផាន់សាន........................................................ ២០.០០០៛

-ញោម ថង........................................................ ១០.០០០៛

-ញោម ម៉ៅ ហ៊ុន........................................................ ១០.០០០៛

-លោកវរសេនីយ៍ត្រី អៀន អ៊ាន និងលោកស្រី........................ ១០.០០០៛

-ឧ.សិ.ផាម........................................................ ១០.០០០៛

-ឧ.សិ.ថាយ សោភ័ណ........................................................ ១០.០០០៛

-ឧ.សិ.ឡុង មោង........................................................ ៦.០០០៛

-ឧ.សិ.ខូវ........................................................ ៥.០០០៛

-ឧ.សិ.ជា ហ៊ុយ........................................................ ៥.០០០៛



www.elibraryofcambodia.org

-លោកយាយ យីន.......................................... ៥.០០០៛

-ញោម ព្រឿង ណូម...................................... ៥.០០០៛

-ឧ.ស.ធន់................................................. ៥.០០០៛

-ឧ.ស.សាន និងតាល់...................................... ៥.០០០៛

-ញោម អៀ សំអាត........................................ ៥.០០០៛

-ឧ.សិ.យ៉េត ឡាយ និងឧ.សិ.លុយ........................ ៥.០០០៛

-ឧ.ស.ប៊ុណ្ណវឌ្ឍន៍ និងឧ.សិ.ឈូន គីម ហ៊ាត.................. ៥.០០០៛

-ឧ.ស.ស ឈៀប និងឧ.សិ.ខួប.............................. ៥.០០០៛

-ឧ.សិ.ហិប.............................................. ៥.០០០៛

-អ្នកគ្រូ.ណៃត.......................................... ៥.០០០៛

-ឧ.ស.ខួយ និងឧ.សិ.យឿន................................. ៥.០០០៛

ឧ.សិ.វ៉ៃ សាវ៉ែន......................................... ៥.០០០៛

-នាង គីម ភន............................................ ៥.០០០៛

-ញោម ហុក ធឿយ......................................... ៥.០០០៛

-ឧ.ស.យិន សោន.......................................... ៥.០០០៛

-លោកវេត និងនាង ឆាយ.................................. ៥.០០០៛

-ញោម សាង ហួយ........................................ ៥.០០០៛

-ឧ.ស.យាន យូន.......................................... ៥.០០០៛

-ឧ.សិ.ពិន មោង.......................................... ៥.០០០៛



www.elibraryofcambodia.org

-ឧ.សិ.ឃីម........................................................ ៥.០០០៛

-លោកយាយ សែម................................................ ៥.០០០៛

-លោកយាយគីម ស្រ៊ិន.......................................... ៤.០០០៛

-ឧ.សិ.ខាំ.......................................................... ៤.០០០៛

ព្រមទាំងពុទ្ធបរិស័ទជាច្រើនរូបទៀត ដែលពុំបានរៀបរាប់ឈ្មោះអស់ អាស្រ័យហេតុនេះ សូមអភ័យទោសក្រែងមិនបានឃើញឈ្មោះព្រោះមិនបានសរសេរ ឬមានការបាត់បង់ឈ្មោះខ្លះៗដោយអចេតនា។

តទៅអនាគតជាតិ សូមឱ្យញាតិញោមបានជួបប្រសព្វតែនឹងសេចក្តីសុខចម្រើនក្នុងជីវិត ពិសេសសូមឱ្យបានរួចផុតអំពីវាលវដ្តសង្សារ ដល់អមតៈធម៌ គឺព្រះនិព្វានដែលជាទីអស់ទៅនូវអាសវក្កិលេសទាំងពួងកុំបីអាក់ខានឡើយ។

*សូមអនុមោទនា!!!*

**សព្វទានំ ធម្មទានំ ជិនាតិ ។**

ធម្មទាន រមែងឈ្នះអស់ទានទាំងពួង ។

**សព្វរសំ ធម្មរសោ ជិនាតិ ។**

រសនៃធម៌ រមែងឈ្នះអស់រសទាំងពួង។

**បញ្ជាក់:** សូមព្រះករុណាព្រះគុណម្ចាស់តាមដានអានសៀវភៅ ក្រោយៗទៀតដោយសេចក្តីរីករាយជ្រះថ្លា ក្នុងការចម្រើនប្រាជ្ញាដើម្បីបានជាមេរៀនអប់រំចិត្តក្នុងជីវិតរៀងៗខ្លួនផងចុះ *សូមអនុមោទនា* ។



www.elibraryofcambodia.org

# "មានជីវិតហើយអ្នកអើយគួរតែសិក្សា"

សៀវភៅជាមិត្តឥតកាត់ថ្លៃបាន
អានហើយគិតផងត្រិះរិះពិចារណា
បើវិជ្ជាមានតែក្នុងសៀវភៅ
បោះបង់ទុកចោលរប៉ាត់រប៉ាយ
នៅក្បែរជញ្ជាំងទុកសៀវភៅចោល
មិនគិតខំអានបើល្ងង់ម្លឹងៗ
រីឯធម្មទានមានផលអនេក
បិទសៀវភៅចោលចាក់សោផងណា
ពេលទទួលបានក្បួនច្បាប់សៀវភៅ
កុំយកទុកចោលអ្នកខ្លះដាក់ផ្កាប់
ពេលនេះយើងមានគម្ពីរក្បួនខ្នាត
អានហើយអានទៀតដោយប្រុងស្មារតី

កាន់អានថ្មើម៉ានតែងបានប្រាជ្ញា
ទើបបាត់មោហាខ្ទាតចេញទៅឆ្ងាយ ។
គំនិតមិនជ្រៅមិនសូវខ្វល់ខ្វាយ
មិនជីកកកាយរកចំណេះដឹង ។
ឆ្ងល់អ្វីអាងបោលស្រាវជ្រាវថ្លែងថ្លឹង
ថែមទាំងមិនប្រឹងស្តាប់លោកទេសនា ។
ទាស់តែមនុស្សប្លែកមិនខំសិក្សា
ពិតគ្មានបានការណ៍ល្ងង់ដល់ថ្ងៃស្លាប់ ។
បើកមើលខ្លះទៅអត្ថន័យសារស័ព្ទ
ទុកគ្មានសណ្តាប់មិនបានអានស្អី ។
ចូរខំសង្វាតទាំងប្រុសទាំងស្រី
ទើបមានសិរីបានប្រាជ្ញាហោង ។

*សូមអនុមោទនា!!!*

**ដោយសាមណេរ សា ចាន់រ៉ាត់**

9 789996 359309

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ សល្យ ពិសិទ្ធិ

មេសា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា**

www.elibraryofcambodia.org